# មេរៀន

# ស្តីពីការលែងលះ

រៀបចំដោយ

ក្រុមការងារបច្ចេកទេស

ដើម្បីអនុវត្តផែនការប្រតិបត្តិការ និងតារាងផែនការសកម្មភាព

នៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ ជំហានទី៦

បោះពុម្ពលើកទី១ ឆ្នាំ២០២៦

# អារម្ភកថា

សៀវភៅមេរៀនស្តីពី "ការលែងលះ" គឺជាសមិទ្ធផលដ៏មានសារៈសំខាន់ និងជាវណ្ណកម្មដំបូងមួយ ដែលត្រូវបានតាក់តែងឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) នៅក្នុងគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ជំហានទី៦ ហើយត្រូវបានរៀបចំឡើងដោយ ក្រុមការងារបច្ចេកទេសដើម្បីអនុវត្តផែនការប្រតិបត្តិការ និងតារាងផែនការសកម្មភាពនៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ជំហានទី៦ ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រសួងយុត្តិធម៌ លេខ ១២ កយ.សសរ/២៣ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ ២០២៣។ សៀវភៅមេរៀននេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងសម្រាប់ប្រើប្រាស់ជាឯកសារគោលដ៏សំខាន់ក្នុងការបណ្តុះបណ្តាលដំបូង របស់សាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញានៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ហើយសៀវភៅនេះនឹងក្លាយទៅជាឯកសារគំរូដែលនឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋាន ក្នុងការរៀបចំតាក់តែងសៀវភៅមេរៀនលើប្រធានបទផ្នែករដ្ឋប្បវេណីផ្សេងៗទៀត។

សៀវភៅមេរៀនស្តីពី "ការលែងលះ" នេះ នឹងធ្វើការពន្យល់លើទិដ្ឋភាពច្បាប់ ទាំងផ្នែកបញ្ញត្តិសារធាតុ ទាំងផ្នែកបញ្ញត្តិនីតិវិធី ទាំងច្បាប់ដែលមានការពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យរដ្ឋប្បវេណី ព្រមទាំងមានការពន្យល់បកស្រាយស៊ីជម្រៅ ភ្ជាប់ជាមួយនឹងករណីសិក្សា និងមានការចង្អុលបង្ហាញទៅបញ្ញត្តិច្បាប់ជាធរមាន ដោយបានឆ្លងកាត់នូវដំណាក់កាលសំខាន់ៗ ដូចខាងក្រោម៖

- ការជ្រើសរើសប្រធានបទដែលមានសារៈសំខាន់ មានភាពស្មុគស្មាញ និងជាមុខវិជ្ជានៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់សាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
- ការតាក់តែងរៀបចំប្លង់ និងមាតិកានៃសៀវភៅមេរៀន
- កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើខ្លឹមសារលម្អិតនៅក្នុងចំណុចនីមួយៗនៃមាតិកា
- ការប្រមូលចងក្រងនូវឯកសារគំរូនៅក្នុងរឿងក្តីរដ្ឋប្បវេណីជាក់ស្តែងពីសាលាជម្រះក្តី និងឯកសារដែលត្រូវបានផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ក្រសួងយុត្តិធម៌
- ការតាក់តែងនូវករណីសិក្សាជាក់ស្តែងពាក់ព័ន្ធនឹងប្រធានបទស្តីពី "ការលែងលះ" ដើម្បីដាក់ឱ្យអ្នកសិក្សាអាចធ្វើការវិភាគ និងដោះស្រាយចំណោទបញ្ហាតាមផ្លូវច្បាប់។

សៀវភៅមេរៀននេះ ត្រូវបានរៀបចំឡើងដោយបែងចែកជា ៤ ជំពូកធំៗ រួមមាន៖ ជំពូកទី១ គម្រោងមេរៀន, ជំពូកទី២ ករណីសិក្សា, ជំពូកទី៣ សំណួរស្រាវជ្រាវ និងជំពូកទី៤ ឯកសារគំរូ។

ដើម្បីអាចសម្រេចបានខ្លឹមសារប្រកបដោយភាពច្បាស់លាស់ និងមានសង្គតិភាពតាមច្បាប់ជាធរមាន សៀវភៅនេះត្រូវបានឆ្លងកាត់នូវកិច្ចប្រជុំពិនិត្យ ពិភាក្សា និងកែសម្រួលក្នុងក្របខណ្ឌក្រុមការងារបច្ចេកទេសដើម្បីអនុវត្តផែនការ



www.moj.gov.kh/kh/book-library

ប្រតិបត្តិការ និងតារាងផែនការសកម្មភាពនៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ជំហានទី៦ សរុបចំនួន ៤៩លើក ព្រមទាំងមានការចូលរួមផ្តល់យោបល់ ពីក្រុមអ្នកជំនាញការច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) ប្រចាំក្រសួងយុត្តិធម៌ជាប់ជាប្រចាំ រហូតឈានទៅដល់ការសម្រេចនូវខ្លឹមសាររួមសម្រាប់សៀវភៅនេះ។

យើងសង្ឃឹមជឿជាក់យ៉ាងមុតមាំថា សៀវភៅមេរៀនស្តីពី "ការលែងលះ" នេះ នឹងក្លាយទៅជាផ្នែកសមិទ្ធផលមួយដ៏សំខាន់ដែលនឹងចូលរួមចំណែកនៅក្នុងការផ្សព្វផ្សាយការយល់ដឹងផ្នែកច្បាប់ ហើយក៏នឹងអាចក្លាយទៅជាឯកសារជាមូលដ្ឋានដ៏រឹងមាំសម្រាប់អ្នកប្រកបវិជ្ជាជីវៈច្បាប់ សិស្សនិស្សិត និងប្រជាពលរដ្ឋ ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីបម្រើជាប្រយោជន៍ដល់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ ព្រមទាំងចូលរួមចំណែកក្នុងការលើកកម្ពស់ការយល់ដឹងផ្នែកច្បាប់រដ្ឋប្បវេណីនៅក្នុងសង្គមកម្ពុជាផងដែរ។

សៀវភៅនេះ បោះពុម្ពលើកទី១ នៅខែកុម្ភៈ ឆ្នាំ២០២៦

*សៀវភៅនេះរក្សាសិទ្ធិដោយក្រសួងយុត្តិធម៌ និង JICA*



www.moj.gov.kh/kh/book-library

ក្រុមការងារបច្ចេកទេស ដើម្បីអនុវត្តផែនការប្រតិបត្តិការ និងតារាងផែនការសកម្មភាពនៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ ជំហានទី៦ ដែលបានតាក់តែងសៀវភៅនេះ រួមមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម **គេង សុម៉ារិទ្ធ** | ប្រធាន | ២៦. លោកស្រី **និល ហ្វីលីប** | សមាជិក |
| ២. ឯកឧត្តមបណ្ឌិតរដ្ឋ **ឈន ព្រលឹង** | អនុប្រធាន<br>ប្រចាំការ | ២៧. លោកស្រី **សែម សែងខេថៃ** | សមាជិក |
| | | ២៨. លោក **ខ៉ូវ សាឡុង** | សមាជិក |
| ៣. លោកជំទាវ **ខៀវ សុផានី** | អនុប្រធាន | ២៩. លោក **ភាន់ សុទ្ធប៉ូលីន** | សមាជិក |
| ៤. លោកជំទាវ **អ៊ឹង រីណា** | អនុប្រធាន | ៣០. លោកស្រី **សឿ ច័ន្ទវាសនា** | សមាជិក |
| ៥. លោកជំទាវ **ម៉ៅ តិរុណា** | អនុប្រធាន | ៣១. លោក **សូ សុខហុង** | សមាជិក |
| ៦. លោកស្រី ITO Mizuki | អនុប្រធាន | ៣២. ឯកឧត្តម **ស៊ិន សុវណ្ណារ័ត្ន** | សមាជិក |
| ៧. ឯកឧត្តម **យ៉ម ផារ៉ូត** | សមាជិក | ៣៣. លោកស្រី **ថ្លាង ផាណែត** | សមាជិក |
| ៨. ឯកឧត្តម **ម៊ុនយ៉េ ណារិន** | សមាជិក | ៣៤. លោក **កេត សុជាតិ** | សមាជិក |
| ៩. ឯកឧត្តម **សេង នាង** | សមាជិក | ៣៥. លោក **ឆៃ វីរៈ** | សមាជិក |
| ១០. ឯកឧត្តម **គង់ តារាឆាត** | សមាជិក | ៣៦. លោក **ឈាង ឈន** | សមាជិក |
| ១១. លោកជំទាវ **ចាំង ស៊ីណាត** | សមាជិក | ៣៧. លោក **ឈាង រិទ្ធី** | សមាជិក |
| ១២. លោកជំទាវ **សែម សក្តិភូឡា** | សមាជិក | ៣៨. លោក **ស សំណាង** | សមាជិក |
| ១៣. ឯកឧត្តម **ចាយ ច័ន្ទតារាវណ្ណ** | សមាជិក | ៣៩. លោក **ឆន់ ដារិទ្ធ** | សមាជិក |
| ១៤. ឯកឧត្តម **ម៉ុង មុនីចរិយា** | សមាជិក | ៤០. លោក **វ៉ាន់ សុបញ្ញា** | សមាជិក |
| ១៥. ឯកឧត្តម **ប្លង់ សំណាង** | សមាជិក | ៤១. លោក **យ៉េម តុលា** | សមាជិក |
| ១៦. ឯកឧត្តម **តាំង ស៊ុនឡាយ** | សមាជិក | ៤២. លោក **សំ ដារ៉ា** | សមាជិក |
| ១៧. ឯកឧត្តម **ឃ្លោក ដារ៉ា** | សមាជិក | ៤៣. លោក **ឡោ គ្រឹម** | សមាជិក |
| ១៨. លោក **គី ខេមលីន** | សមាជិក | ៤៤. លោក **ខ៉ែត ណារ័ត្ន** | សមាជិក |
| ១៩. លោកស្រី TOBE Yuki | សមាជិក | ៤៥. លោកជំទាវ **ទេព មូផល** | សមាជិក |
| ២០. លោកជំទាវ **មាន ពេជ្រដាប៊ីណា** | សមាជិក | ៤៦. ឯកឧត្តម **អ៊ុវ ប៉ូលី** | សមាជិក |
| ២១. ឯកឧត្តម **ហេង សុខណា** | សមាជិក | ៤៧. លោក **ញ៉ឹម សុធា** | សមាជិក |
| ២២. លោក **ម៉ុង មុនីសោភា** | សមាជិក | ៤៨. លោក **ណាយ សំអុល** | សមាជិក |
| ២៣. លោក **យាប់ មេត្តា** | សមាជិក | ៤៩. លោកជំទាវ **ឃុត ស៊ាងអែ** | សមាជិក |
| ២៤. លោក **អ៊ី ថាវរៈ** | សមាជិក | ៥០. លោក **ឈឿន គុយអេង** | សមាជិក |
| ២៥. លោក **ខួន ឧត្តី** | សមាជិក | ៥១. លោកស្រី **គន្ធា ស្រីសុជាតា** | សមាជិក |



www.moj.gov.kh/kh/book-library

៥២. លោកស្រី **នៅ សុជាតា** សមាជិក

៥៣. លោក **ស៊ុំ ណារ៉ា** សមាជិក

៥៤. លោក **ពៅ វិសាល** សមាជិក

៥៥. លោក **ឌី ផានិត** សមាជិក

៥៦. លោកស្រី **សុវណ្ណា បញ្ញា** សមាជិក

៥៧. លោកស្រី **ឃុត សុនិតា** សមាជិក

៥៨. លោក **ឈន វិសាល** សមាជិក

៥៩. លោកស្រី **ឈួន មរកត** សមាជិក

៦០. លោក GOTO Keisuke សមាជិក

៦១. លោក KAWAKAMI Tsukasa សមាជិក

៦២. លោកស្រី MIZOGUCHI Chie សមាជិក

៦៣. លោក **ទ៉ូច ហួតឆាយ** សមាជិក

៦៤. លោក **ចន សុភ័ក្រ** សមាជិក

៦៥. លោក **គុជ តារ៉ា** សមាជិក

៦៦. លោកស្រី **ខេង ខេមរៈ** សមាជិក

៦៧. លោកស្រី **អ៊ិន ឆរីដា** សមាជិក

៦៨. លោកស្រី **ហេង សុម៉ាលីន** សមាជិក



www.moj.gov.kh/kh/book-library

# សេចក្ដីថ្លែងអំណរគុណ

ក្រុមការងារបច្ចេកទេស ដើម្បីអនុវត្តផែនការប្រតិបត្តិការ និងតារាងផែនការសកម្មភាពនៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ ជំហានទី៦ សូមគោរពថ្លែងអំណរគុណចំពោះ ៖

- ឯកឧត្ដម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានបង្កើតក្រុមការងារបច្ចេកទេសដើម្បីអនុវត្តផែនការប្រតិបត្តិការ និងតារាងផែនការសកម្មភាពនៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ជំហានទី៦។

- ឯកឧត្ដម **ជិន ម៉ាលីន** រដ្ឋលេខាធិការប្រចាំការ និងជានាយកគ្រប់គ្រងគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ ជំហានទី៦។

- ឯកឧត្ដម **កេខ សុម៉ារិទ្ធ** រដ្ឋលេខាធិការ និងជាអ្នកគ្រប់គ្រងគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ ជំហានទី៦ ព្រមទាំងជាប្រធានក្រុមការងារបច្ចេកទេស ដែល **ឯកឧត្ដម** តែងតែចូលរួមដឹកនាំកិច្ចប្រជុំប្រចាំសប្ដាហ៍របស់ក្រុមការងារ។

- ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ដែលបានជួយគាំទ្រគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ ជំហានទី៦។

- បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ដែលបានផ្ដល់ទីតាំង និងជួយសម្របសម្រួលដល់ដំណើរការនៃកិច្ចប្រជុំប្រចាំសប្ដាហ៍របស់ក្រុមការងារប្រព្រឹត្តទៅបានរលូន។

- **ឯកឧត្ដម លោកជំទាវ លោក លោកស្រី** អនុប្រធាន សមាជិក អ្នកជំនាញការ JICA ព្រមទាំងអ្នកបកប្រែ ដែលបានចូលរួមនៅក្នុងការតាក់តែងសៀវភៅចេញជាសមិទ្ធផលនេះឡើង។

សូម **ឯកឧត្ដម លោកជំទាវ លោក លោកស្រី** ទទួលបាននូវសេចក្ដីសុខ សុភមង្គល និងជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។



www.moj.gov.kh/kh/book-library

# បញ្ជីអក្សរកាត់

១. ក.រ.ណ. អានថា ក្រមរដ្ឋប្បវេណី

២. ក.ន.ណ. អានថា ក្រមនីតិវិធីរដ្ឋប្បវេណី

៣. ច.ន.ប. អានថា ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

៤. ច.ន.ម. អានថា ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

៥. ច.អ.គ. អានថា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

៦. ម. អានថា មាត្រា

៧. ក. អានថា កថាខណ្ឌ

៨. វ. អានថា វាក្យខណ្ឌ

៩. ច. អានថា ចំណុច

១០. ផ. អានថា ផ្នែក

១១. ឧ. អានថា ឧទាហរណ៍

១២. ទំ. អានថា ទំព័រ



www.moj.gov.kh/kh/book-library

# មាតិកា


ទំព័រ

**អារម្ភកថា** ... i

**សេចក្តីថ្លែងអំណរគុណ** ... v

**បញ្ជីអក្សរកាត់** ... vi

**មាតិកា** ... 1

**សេចក្តីផ្តើម** ... 3

**ជំពូកទី ១ គម្រោងមេរៀន** ( Course Outline ) ... 4

**ផ្នែកទី ១ ៖ ប្រភេទ និងលក្ខខណ្ឌនៃការលែងលះ** ... 4

**១- ការលែងលះតាមផ្លូវបណ្តឹង** ... 4

**២- ការលែងលះដោយការព្រមព្រៀង** ( **ម. ៩៧៩ នៃ ក.រ.ណ.** ) ... 6

**ផ្នែកទី ២ ៖ អានុភាពដែលកើតឡើងដោយសារការលែងលះ** ... 7

**១- ការកំណត់អ្នកមានអំណាចមេបា** ( **ម. ១០៣៧ នៃ ក.រ.ណ.** ) ... 7

**២- ការបែងចែកទ្រព្យសម្បត្តិរួម** ( **ម. ៩៨០ នៃ ក.រ.ណ.** ) ... 9

**៣- ការកំណត់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន** ( **ម. ១០៤០ នៃ ក.រ.ណ.** ) ... 11

**៤- ការកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន** ( **ម.១០៤០ នៃ ក.រ.ណ.** ) ... 12

**៥- ការកំណត់អំពីអាហារកិច្ច** ( **ម. ៧៦ នៃ ច.អ.គ.** ) ... 12

**ផ្នែកទី ៣ ៖ នីតិវិធីសម្រាប់ការទាមទារលែងលះ** ... 14

**១- នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល** ... 15

**២- នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង** ... 18

**ផ្នែកទី ៤ ៖ នីតិវិធីសម្រាប់ការទាមទារផ្សេងទៀត នៅក្នុងរឿងក្តីលែងលះ** ... 20

**១- នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល** ... 20

**២- នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង** ... 21

**៣- នីតិវិធីបណ្តឹងរដ្ឋប្បវេណី** ... 21

**ផ្នែកទី ៥ ៖ ការតាក់តែងសេចក្តីសម្រេច** ... 22




www.moj.gov.kh/kh/book-library

១- សាលក្រម ..... 22
២- ដីកាសម្រេច ..... 22
ជំពូកទី ២ ករណីសិក្សា ..... 23
ក. ករណីសិក្សាទី ១ ..... 23
ខ. ករណីសិក្សាទី ២ ..... 24
គ. ករណីសិក្សាទី ៣ ..... 25
ឃ. ករណីសិក្សាទី ៤ (ការបែងចែកទ្រព្យសម្បត្តិ) ..... 26
ជំពូកទី ៣ សំណួរស្រាវជ្រាវ ..... 31
ជំពូកទី ៤ ឯកសារគំរូ ..... 34
ក. ឯកសារគំរូ (ទម្រង់គំរូ មិនមែនខ្លឹមសារគំរូ) ..... 34
១. គំរូពាក្យបណ្ដឹង ..... 34
២. គំរូលិខិតពាក្យសុំកែតម្រូវពាក្យបណ្ដឹង ..... 47
៣. គំរូឯកសារចម្លើយ ..... 50
៤. គំរូលិខិតសាលក្រម ..... 55
៥. គំរូដីកាសម្រេច ..... 75
ឧបសម្ព័ន្ធ ..... 77
ឧបសម្ព័ន្ធទី ១ : ការពន្យល់អំពីទ្រឹស្ដី A និង ទ្រឹស្ដី B នៃសិទ្ធិទាមទារលៃលះ ..... 78
ឧបសម្ព័ន្ធទី ២ : ការពន្យល់អំពីទ្រឹស្ដីនៃការកំណត់អ្នកមានអំណាចមេបា ..... 90
ឧបសម្ព័ន្ធទី ៣ : រូបមន្តគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ករណីប្រទេសជប៉ុន ..... 99
ឧបសម្ព័ន្ធទី ៤ : អានុភាពនៃដីកាសម្រេច ..... 103
ឧបសម្ព័ន្ធទី ៥ : ការពន្យល់អំពីទស្សនៈនៃការទាមទារអាហារកិច្ច ..... 104
ឯកសារយោង ..... 106



www.moj.gov.kh/kh/book-library

# សេចក្តីផ្តើម

ការចងក្រងសៀវភៅមេរៀនស្តីពីការលែងលះនេះ មានគោលបំណងឱ្យសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា សិក្សាស្វែងយល់អំពីមូលហេតុនៃការលែងលះ ផលវិបាកគតិយុត្តដែលកើតឡើងនៅក្រោយការលែងលះ ដោយផ្តោតសំខាន់លើការកំណត់អ្នកមានអំណាចមេបា ការបែងចែកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ការកំណត់សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន និងកំណត់អំពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ជាអាទិ៍។ បន្ថែមលើចំណុចជាសារធាតុទាំងអស់នេះ សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា នឹងសិក្សាស្វែងយល់អំពីនីតិវិធីដែលត្រូវយកមកអនុវត្តនៅក្នុងការទាមទារលែងលះ ការចាត់ចែងបន្ទាប់បន្សំ ការធ្វើសេចក្តីសន្និដ្ឋាន និងវាយតម្លៃពាក់ព័ន្ធនឹងបញ្ញត្តិដែលបានសិក្សា និងករណីសិក្សា ព្រមទាំងការធ្វើសេចក្តីសន្និដ្ឋាន និងប្រៀបធៀបខ្លឹមសារ លក្ខខណ្ឌ អានុភាពនៃបញ្ញត្តិមាត្រា និងនីតិវិធីដែលមានភាពពាក់ព័ន្ធគ្នា ជាពិសេស ស្វែងយល់អំពីរបៀបក្នុងការតាក់តែងសេចក្តីសម្រេច។

ក្រុមការងាររំពឹងទុកថា បន្ទាប់ពីបានឆ្លងកាត់ការសិក្សាលើមេរៀននេះរួច សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា នឹងទទួលបានចំណេះដឹងពាក់ព័ន្ធនឹងការលែងលះ និងអានុភាពដែលកើតឡើងក្រោយការលែងលះ ព្រមទាំងអាចអនុវត្តនីតិវិធី (នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឬនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឬនីតិវិធីបណ្តឹងរដ្ឋប្បវេណី) ឱ្យបានត្រឹមត្រូវពាក់ព័ន្ធនឹងការទាមទារលែងលះ និងការទាមទារផ្សេងទៀតនៅក្នុងរឿងក្តីលែងលះ ជាពិសេសអាចតាក់តែងសេចក្តីសម្រេចពាក់ព័ន្ធនឹងការទាមទារលែងលះ និងការទាមទារផ្សេងទៀតនៅក្នុងរឿងក្តីលែងលះឱ្យបានត្រឹមត្រូវស្របតាមបញ្ញត្តិច្បាប់ជាធរមាន។

សៀវភៅនេះ ត្រូវបានបែងចែកជា ៤ជំពូក ដូចខាងក្រោម :

ជំពូកទី ១ គម្រោងមេរៀន (Course Outline)

ជំពូកទី ២ ករណីសិក្សា

ជំពូកទី ៣ សំណួរស្រាវជ្រាវ

ជំពូកទី ៤ ឯកសារគំរូ

បន្ថែមពីលើជំពូកទាំងបួននេះ ឧបសម្ព័ន្ធនៃសៀវភៅនេះ ត្រូវបានតាក់តែងឡើងដោយពន្យល់អំពីទ្រឹស្តី ឬទស្សនៈដែលអាចមានពាក់ព័ន្ធនឹងការបកស្រាយបញ្ញត្តិច្បាប់សារធាតុ និងច្បាប់នីតិវិធីនៅក្នុងរឿងក្តីលែងលះ។



www.moj.gov.kh/kh/book-library

# ជំពូកទី ១

## គម្រោងមេរៀន ( Course Outline )

- សញ្ញាណទូទៅពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ស្របច្បាប់

① លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍

② អានុភាពនៃអាពាហ៍ពិពាហ៍

- សញ្ញាណទូទៅអំពីការលែងលះ

## ផ្នែកទី ១ ៖ ប្រភេទ និងលក្ខខណ្ឌនៃការលែងលះ

### ១- ការលែងលះតាមផ្លូវបណ្ដឹង

#### ១.១- សិទ្ធិលែងលះ (សិទ្ធិទាមទារលែងលះ)

* ការពន្យល់អំពី សិទ្ធិលែងលះ សូមពិនិត្យមើលសេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ : នីតិវិធីបណ្ដឹង ទំព័រទី ៥៦.[1] ។

មាត្រា ៩៧៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី បញ្ញត្តអំពីសិទ្ធិទាមទារឱ្យលែងលះ ដោយផ្អែកលើទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ដែលត្រូវបានបកស្រាយ ជាការកំណត់សិទ្ធិទាមទារឱ្យលែងលះ មានតែមួយប៉ុណ្ណោះ។ នៅក្នុងបញ្ញត្តិមាត្រានេះ ចាប់ពីចំណុច «ក» រហូតដល់ចំណុច «ឃ» បញ្ញត្តពីហេតុជាក់លាក់ ដែលនាំឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញ ហើយបញ្ញត្តិចំណុច «ង» ក៏បានកំណត់អំពីហេតុដោយឡែកដទៃទៀត ដែលមិនរាប់បញ្ចូលនៅក្នុងចំណុច «ក» ដល់ចំណុច «ឃ» ដែលបណ្ដាលឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញ។ សរុបមក មូលហេតុនៃសិទ្ធិទាមទារលែងលះ ចាប់ពីបញ្ញត្តិចំណុច «ក» ដល់ចំណុច «ង» គឺសុទ្ធតែជាករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទាំងអស់។

ហេតុនេះ ដើមចោទត្រូវទាមទារឱ្យតុលាការចេញសាលក្រមមានខ្លឹមសារសម្រេចអំពីការទាមទារលែងលះ។ អ្វីដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង គឺខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ដែលជាអាពាហ៍ពិពាហ៍ស្របច្បាប់ [2] (ការចុះសំបុត្រអាពាហ៍ពិពាហ៍)។ អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន (មូលហេតុណាមួយ ឬច្រើន ដែលមានចែងនៅក្នុង ម. ៩៧៨ ក. ១ នៃ ក.រ.ណ.)។

---

[1]. សូមអានការពន្យល់បន្ថែម នៅក្នុងឧបសម្ព័ន្ធទី ១។ ការសរសេរនៅក្នុងចំណុចនេះ គឺផ្អែកលើការបកស្រាយ (ទ្រឹស្ដី B នៅក្នុងឧបសម្ព័ន្ធទី ១) ដែលជ្រើសរើសដោយក្រុមការងារ TWG ដែលជាក្រុមការងារតាក់តែងសៀវភៅនេះ។

[2]. អាពាហ៍ពិពាហ៍ស្របច្បាប់ ជាអាពាហ៍ពិពាហ៍ដែលមានអានុភាព ដោយបំពេញលក្ខខណ្ឌទម្រង់ នៅក្នុងមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី និងលក្ខខណ្ឌសារធាតុចាប់ពីមាត្រា ៩៤៨ ដល់មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណី។



www.moj.gov.kh/kh/book-library

ឧទាហរណ៍ ៖ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺ «ឱ្យដើមចោទឈ្មោះ.....និងចុងចម្លើយឈ្មោះ...... លែងលះគ្នា» ឬ «លែងលះដើមចោទឈ្មោះ..... និងចុងចម្លើយឈ្មោះ.....»[3]។ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺ «ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ០១ នៅក្នុងសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០២០ ចុះថ្ងៃទី១ ខែមករា ឆ្នាំ២០២០»។ អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺ «ដើមចោទទាមទារលែងលះ ដោយសារចុងចម្លើយបានប្រព្រឹត្តអំពើផិតជាមួយមិត្តរួមការងាររបស់ខ្លួន រហូតដល់មានកូនម្នាក់ទៀតផងដែរ»។

☝ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ (សេចក្តីសម្រេចបញ្ចប់នៃសាលក្រម)

សាលក្រមលែងលះ ជាប្រភេទសាលក្រមបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត។[4] ដូចនេះ ការលែងលះមានអានុភាព ដោយសារការចូលជាស្ថាពរនៃសាលក្រម ហើយអានុភាពនេះ គឺទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានរំលត់ដោយពុំមានការធ្វើសកម្មភាព ជាអាទិ៍ ពីភាគីឡើយ។ ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ (សេចក្តីសម្រេចបញ្ចប់នៃសាលក្រម) គឺត្រូវសរសេរយ៉ាងណា ឱ្យអ្នកអានអាចយល់បានយ៉ាងច្បាស់លាស់ ពីគោលគំនិតនៃការសរសេរសេចក្តីសម្រេចនេះ។ របៀបសរសេរដែលបានភ្ជាប់ជូននៅក្នុងសៀវភៅមេរៀននេះ មានដូចខាងក្រោម ហើយក្នុងចំណោមរបៀបសរសេរសេចក្តីសម្រេចបញ្ចប់ខាងក្រោមនេះ របៀបសរសេរមួយណាក៏ត្រឹមត្រូវដែរ។

① «លែងលះដើមចោទ និងចុងចម្លើយ»

ចំណុចល្អ ៖ ជាពាក្យពេចន៍ ដែលអាចបែងចែកឱ្យដាច់ពីសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក ហើយបញ្ជាក់ឱ្យកាន់តែច្បាស់ថាជាសាលក្រមបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត។ ម្យ៉ាងទៀត ការសរសេរបែបនេះ គឺមាននៅក្នុងសៀវភៅទម្រង់គំរូ ហើយក៏ត្រូវបានប្រើប្រាស់ក្នុងការអនុវត្តជាក់ស្តែងច្រើន។

ចំណុចបញ្ហា ៖ វេយ្យាករណ៍មានលក្ខណៈឆ្គង។

② «ឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នា»

ចំណុចល្អ ៖ ដូចគ្នានឹងពាក្យពេចន៍នៃមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី ហើយនៅក្នុងការអនុវត្តជាក់ស្តែងមានការប្រើប្រាស់ការសរសេរបែបនេះដែរ។ ម្យ៉ាងទៀត របៀបសរសេរនេះ អាចបង្ហាញឱ្យកាន់តែច្បាស់ថា អ្នកវិនិច្ឆ័យអំពីការទទួលស្គាល់ ឬមិនទទួលស្គាល់ការទាមទារលែងលះ នៅក្នុងបណ្តឹងលែងលះ ជាតុលាការ។

ចំណុចបញ្ហា ៖ ស្រដៀងនឹងពាក្យថា «បង្គាប់ឱ្យ ឬ ឱ្យ» នៅក្នុងសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក ដែលនាំឱ្យមិនអាចញែកដាច់ពីគ្នាបានរវាងសាលក្រមផ្តល់តាវកាលិក និងសាលក្រមប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត។

មតិផ្ទុយនឹងចំណុចបញ្ហា ៖ តាមន័យវេយ្យាករណ៍ ពាក្យ «ឱ្យលែងលះ» មានន័យថា ឱ្យរំលាយទំនាក់ទំនង

[3]. ផ្អែកតាមការបកស្រាយ (ទ្រឹស្តី B នៅក្នុងឧបសម្ព័ន្ធទី ១) ដែលជ្រើសរើស ដោយក្រុមការងារ TWG ដែលជាក្រុមការងារតាក់តែងសៀវភៅមេរៀននេះ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺមិនចាំបាច់សរសេរ «ផ្អែកលើទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់» ទេ ព្រោះ សិទ្ធិទាមទារលែងលះមានតែមួយ មិនចាំបាច់សរសេរបន្ថែម ដើម្បីញែកឱ្យដាច់ពីគ្នាដូចករណីសិទ្ធិទាមទារដទៃទេ ។

[4]. សូមអានទំព័រទី ៥១ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្តឹង ។



www.moj.gov.kh/kh/book-library

អាពាហ៍ពិពាហ៍ មិនមែនមានន័យថា ឱ្យភាគីធ្វើសកម្មភាពលែងលះគ្នាទេ (ធ្វើសកម្មភាព ឬផ្តល់តាវកាលិក)។ ដូចនេះ សាលក្រមនេះ បែងចែកដាច់ពីសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក។

③ «ឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នា ចាប់ពីពេលសាលក្រមចូលជាស្ថាពរ»។ (ពាក្យពេចន៍ «ចាប់ពីពេលសាលក្រមចូលជាស្ថាពរ» មិនត្រូវបានយកមកប្រើប្រាស់ឡើយ នៅក្នុងយុត្តិសាស្ត្រនៃតុលាការកំពូល)។

ចំណុចល្អ ៖ បើប្រៀបធៀបនឹងចំណុច② គឺបញ្ជាក់យ៉ាងច្បាស់លាស់ថា ជាសាលក្រមបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ហើយមានសរសេរនៅក្នុងចំណុចលេខ១២ នៃសៀវភៅស្តីពីការពន្យល់អំពីនីតិវិធីជម្រះក្តីលើកទី១។

ចំណុចបញ្ហា ៖ សាលក្រមផ្សេង ក៏មានអានុភាពចាប់ពីសាលក្រមចូលជាស្ថាពរដែរ ហេតុនេះ បើដាក់ពាក្យ «ចាប់ពីពេលសាលក្រមចូលជាស្ថាពរ» ចូលតែក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមលែងលះ នឹងនាំឱ្យមានការយល់ច្រឡំកើតឡើង។

### ១.២- លក្ខខណ្ឌ

① អាពាហ៍ពិពាហ៍ស្របច្បាប់[5] (លក្ខខណ្ឌទាក់ទងនឹងច្បាប់នីតិវិធី)

② មូលហេតុលែងលះ (ម. ៩៧៨ ក. ១ នៃ ក.រ.ណ.)

②-1 ការប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ

②-2 ការបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ

②-3 ការមិនដឹងច្បាស់ថា សហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ

②-4 សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ

②-5 ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញ[6]

### ១.៣- មូលហេតុនៃការច្រានចោលការទាមទារលែងលះ (ម. ៩៧៨ ក. ២ និង ក. ៣ នៃ ក.រ.ណ.)

- ប្រសិនបើការលែងលះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូន ក្រលំបាកយ៉ាងខ្លាំង

- ប្រសិនបើការលែងលះបណ្តាលឱ្យសហព័ទ្ធ ឬកូន មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន

- ប្រសិនបើយល់ឃើញថា ការទាមទារលែងលះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារលែងលះ ធ្វេសប្រហែសយ៉ាងខ្លាំងក្នុងសហប្រតិបត្តិការ និងការជួយសង្គ្រោះចំពោះសហព័ទ្ធ (មូលហេតុច្រានចោលការទាមទារលែងលះពាក់ព័ន្ធនឹងមូលហេតុ ②-4 និង ②-5)

## ២- ការលែងលះដោយការព្រមព្រៀង[7] (ម. ៩៧៩ នៃ ក.រ.ណ.)

---

[5]. អាពាហ៍ពិពាហ៍ស្របច្បាប់ ជាលក្ខខណ្ឌបណ្តឹង ហើយក៏ជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារផងដែរ ។ ក្នុងករណីដែលភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ដូចមានចែងនៅក្នុងមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី នោះមិនមែនជាអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ។ អាពាហ៍ពិពាហ៍ស្របច្បាប់ ជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ (ម. ៧៥ ក. ២ ច. ខ នៃ ក.ន.ណ.) ។ ក្នុងករណីដែលគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ បណ្តឹងនឹងត្រូវបានលើកចោល ដោយសាលក្រម ដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ មូលហេតុជាបណ្តឹងមានលក្ខណៈផ្ទុយច្បាប់ ហើយមិនអាចកែតម្រូវបាន។

[6]. ការពន្យល់បន្ថែមពាក់ព័ន្ធនឹងមូលហេតុនេះ សូមពិនិត្យមើល សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ៣ ទំព័រ ២០។

[7]. ចំណុច ①, ② និង ③ គឺជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ (ម. ២៦ ក. ២ ច. ខ នៃ ច.ន.ម.) ។



www.moj.gov.kh/kh/book-library

① អាពាហ៍ពិពាហ៍ស្របច្បាប់

② ការព្រមព្រៀងគ្នាលែងលះ (មានឆន្ទៈលែងលះពិតប្រាកដ)

③ ការព្រមព្រៀងគ្នាលើអ្នកមានអំណាចមេបា ក្នុងករណីដែលកូនជាអនីតិជន

☝ មូលហេតុដែលការព្រមព្រៀងអំពីអ្នកមានអំណាចមេបា ជាលក្ខខណ្ឌ៖

លក្ខខណ្ឌ ③ កើតចេញពីការបកស្រាយច្បាប់សារជាតុ (ម. ៩៧៩ និង ម. ១០៣៧ នៃ ក.រ.ណ. ជាអាទិ៍) ដូចខាងក្រោម ៖

ប្រសិនបើឪពុកម្ដាយលែងលះគ្នា អំណាចមេបាលើកូនដែលជាអនីតិជន នឹងក្លាយជាអំណាចមេបាទោល (ម. ១០៣៧ នៃ ក.រ.ណ.)។ ដូចនេះ ប្រសិនបើឪពុកម្ដាយលែងលះគ្នា ប្រាកដជាជះឥទ្ធិពលដោយផ្ទាល់ទៅលើឋានៈតាមផ្លូវច្បាប់របស់ឪពុកម្ដាយដែលជាភាគីនៃអាពាហ៍ពិពាហ៍ និងកូនផងដែរ។ ប្រព័ន្ធនៃការលែងលះដោយការព្រមព្រៀង ជាប្រព័ន្ធយកការព្រមព្រៀងរបស់ភាគីនៃអាពាហ៍ពិពាហ៍មកធ្វើជាមូលដ្ឋាន ហើយទោះបីជាមិនអាចព្រមព្រៀងគ្នាអំពីកូនដែលត្រូវទទួលរងនូវឥទ្ធិពលដោយផ្ទាល់លើឋានៈតាមផ្លូវច្បាប់ក៏ដោយក្ដី ក៏មិនគប្បីអនុញ្ញាតឱ្យឪពុកម្ដាយដោះស្រាយ ដោយផ្អែកលើត្រឹមតែការព្រមព្រៀងអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ខ្លួននោះឡើយ។ ហេតុនេះ គប្បីបកស្រាយថា ដើម្បីលែងលះដោយការព្រមព្រៀង ប្ដីប្រពន្ធមិនត្រឹមព្រមព្រៀងតែអំពីការលែងលះនោះទេ ប៉ុន្តែក៏ចាំបាច់ត្រូវព្រមព្រៀងគ្នាអំពីអ្នកមានអំណាចមេបាលើកូនដែលជាអនីតិជនផងដែរ។ ហេតុនេះ នៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង តុលាការអាចទទួលស្គាល់ពាក្យសុំលែងលះដោយការព្រមព្រៀង (ផ. ៤ ច. ៥ នៃតារាងឧបសម្ព័ន្ធ នៃ ច.ន.ម.) លុះត្រាតែ ឪពុកម្ដាយបានព្រមព្រៀងគ្នាអំពីអ្នកមានអំណាចមេបា ករណីមានកូនជាអនីតិជន។ ករណីនេះ ប្រសិនបើឪពុកម្ដាយមិនអាចព្រមព្រៀងគ្នាអំពីការកំណត់អ្នកមានអំណាចមេបា ពួកគាត់ត្រូវដាក់ពាក្យបណ្ដឹងលែងលះ (ម. ៩៧៩ និង ម. ៩៨២ នៃ ក.រ.ណ.)។

## ផ្នែកទី ២ ៖ អានុភាពដែលកើតឡើងដោយសារការលែងលះ

នៅពេលលែងលះគ្នា នាំឱ្យមានការកំណត់អ្នកមានអំណាចមេបា ការបែងចែកទ្រព្យសម្បត្តិរួម ការកំណត់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ការកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងជាមួយកូន ការរាយការណ៍អំពីស្ថានភាពរបស់កូន ការផ្លាស់ប្ដូរនាមត្រកូលរបស់ប្ដីប្រពន្ធ ជាអាទិ៍។

### ១- ការកំណត់អ្នកមានអំណាចមេបា[8] (ម. ១០៣៧ នៃ ក.រ.ណ.)

#### ១.១- ការកំណត់អ្នកមានអំណាចមេបាដោយច្បាប់

8. សូមអានការពន្យល់បន្ថែមនៅក្នុង ឧបសម្ព័ន្ធទី ២ ។



www.moj.gov.kh/kh/book-library

ម្ដាយ គឺជាអ្នកមានអំណាចមេបា ប្រសិនបើការលែងលះធ្វើឡើងមុនកំណើតកូន (ម. ១០៣៧ ក.២ វ.១ នៃ ក.រ.ណ.) ។

### ១.២- ការកំណត់អ្នកមានអំណាចមេបាដោយការព្រមព្រៀង

ប្ដីប្រពន្ធ អាចព្រមព្រៀងគ្នា ក្នុងការកំណត់អ្នកមានអំណាចមេបា (ម. ១០៣៧ ក. ១ នៃ ក.រ.ណ.)។

ប្រសិនបើការលែងលះធ្វើឡើងនៅមុនកំណើតកូន នោះនៅក្រោយកំណើតកូន អាចកំណត់យកឪពុក ជាអ្នកមានអំណាចមេបា តាមការព្រមព្រៀងរបស់ឪពុកម្ដាយ (ម. ១០៣៧ ក.២ វ.២ នៃ ក.រ.ណ.)។

ទោះបីជាមានការព្រមព្រៀងគ្នារបស់ឪពុកម្ដាយកំណត់អំពីអ្នកមានអំណាចមេបាហើយក៏ដោយ ក៏តុលាការត្រូវសរសេរអំពីការកំណត់អ្នកមានអំណាចមេបាក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ឬដីកាសម្រេច ព្រមគ្នាជាមួយនឹងសេចក្ដីសម្រេចបញ្ចប់ស្ដីពីការលែងលះដែរ។[9]

### ១.៣- ការកំណត់អ្នកមានអំណាចមេបាដោយតុលាការ

ការកំណត់អ្នកមានអំណាចមេបា ដែលមិនអាចធ្វើឡើងដោយការព្រមព្រៀង ឬ ពុំអាចពិភាក្សាគ្នាបាន គឺតុលាការជាអ្នកសម្រេច (ម. ១០៣៧ ក. ៣ នៃ ក.រ.ណ.)។

#### ១.៣.១- លក្ខខណ្ឌក្នុងការកំណត់អ្នកមានអំណាចមេបាដោយតុលាការ[10]

① ការទទួលស្គាល់ការទាមទារលែងលះគ្នា

② កូនជាអនីតិជន[11]

③ ឪពុកម្ដាយ ពិភាក្សាគ្នាពុំបានសម្រេច ឬពុំអាចពិភាក្សាគ្នាបាន (ម. ១០៣៧ ក. ១ និង ក. ២ នៃ ក.រ.ណ.)[12]

#### ១.៣.២- ចំណុចដែលតុលាការត្រូវពិចារណានៅពេលសម្រេចអំពីអំណាចមេបា

① ផលប្រយោជន៍របស់កូន (ម. ១០៣៧ ក. ៣ នៃ ក.រ.ណ.) អាចត្រូវពិចារណាដូចខាងក្រោម ៖

①-១. ស្ថានភាពឪពុក ឬម្ដាយ

---

9.ជាការបកស្រាយដែលត្រូវបានសម្រេចដោយក្រុមការងារ TWG ដែលជាក្រុមការងារតាក់តែងសៀវភៅមេរៀននេះ។ គប្បីពិចារណាថា នៅក្នុងការកំណត់អ្នកមានអំណាចមេបា គឺតម្រូវឱ្យមានភាពច្បាស់លាស់ និងពិតប្រាកដខ្ពស់ ដូចនេះ ការព្រមព្រៀងដោយផ្ទាល់មាត់របស់ភាគីតែមួយមុខ គឺមិនគ្រប់គ្រាន់ឡើយ ដោយចាំបាច់ត្រូវមានទម្រង់ជាក់លាក់។ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ដែលទាក់ទងនឹងការកំណត់អ្នកមានអំណាចមេបា គឺជាបញ្ញត្តិផ្អែកលើមាត្រាដែលមានចែងមុនពោលគឺមាត្រា ៩៧៨ និងមាត្រា ៩៧៩ ហើយការលែងលះតាម មាត្រា ៩៧៨ និងមាត្រា ៩៧៩ សុទ្ធតែត្រូវធ្វើតាមទម្រង់នៃសេចក្ដីសម្រេច។ ហេតុនេះ គប្បីបកស្រាយថា ការកំណត់អ្នកមានអំណាចមេបាដែលត្រូវធ្វើក្នុងពេលព្រមគ្នាជាមួយនឹងការលែងលះ ក៏ត្រូវតែធ្វើតាមទម្រង់នៃសេចក្ដីសម្រេចផងដែរ (ទ្រឹស្ដី ក) ។ ផ្ទុយមកវិញ ក៏មានទ្រឹស្ដីផ្សេង (ទ្រឹស្ដី ខ) ដែលបកស្រាយថា ប្រសិនបើយកពាក្យពេចន៍នៅក្នុងមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ធ្វើជាមូលដ្ឋានវិញនោះ គឺអានុភាពនៃការកំណត់អ្នកមានអំណាចមេបា នឹងកើតមានតាមតែការព្រមព្រៀងរបស់ឪពុកម្ដាយប៉ុណ្ណោះ។ ហេតុនេះ ករណីមានការព្រមព្រៀងរបស់ឪពុកម្ដាយរួចហើយ តុលាការមិនត្រូវសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបាឡើយ ប៉ុន្តែទោះបីជាមិនធ្វើការសម្រេចសេចក្ដី ក៏តុលាការគួរតែសរសេរនូវខ្លឹមសារដែលឪពុកម្ដាយបានព្រមព្រៀងគ្នា នៅក្នុងសំអាងហេតុនៃសេចក្ដីសម្រេចដែរ។

10. ចំណុច ①, ② និង ③ គឺជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ (ម. ១ និង ម. ២២ នៃ ច.ន.ឋ. និង ម. ៧៥ ក. ២ ក.ន.ណ.)។

11. ករណីលែងលះដែលបានធ្វើឡើងនៅមុនពេលកំណើតកូន (ពេលកូននៅក្នុងផ្ទៃម្ដាយ «គភ៌») គេមិនអាចកំណត់អ្នកមានអំណាចមេបា នៅពេលលែងលះបានទេ (ម. ១០៣៧ ក. ២ នៃ ក.រ.ណ.)។

12. ទោះបីមិនមានការទាមទារពីឪពុកម្ដាយក៏ដោយ ក៏តុលាការមានករណីយកិច្ចកំណត់អ្នកមានអំណាចមេបា (ម. ១០៣៧ ក. ៣ នៃ ក.រ.ណ.)។



www.moj.gov.kh/kh/book-library

- ស្ថានភាពគ្រប់គ្រង ៖ អាយុ សុខភាព ចំណេះដឹង ឥរិយាបថ កិរិយាមារយាទ បុគ្គលិកលក្ខណៈ ជាអាទិ៍

- ស្ថានភាពសេដ្ឋកិច្ច ៖ មុខរបរ ប្រាក់ចំណូល ទ្រព្យសម្បត្តិ លំនៅឋាន ជាអាទិ៍

- ស្ថានភាពទំនាក់ទំនងរវាងឪពុកម្តាយជាមួយកូនកន្លងមក ៖ ពេលវេលានៅជាមួយកូន ក្តីស្រឡាញ់ ភាពមាន ឬគ្មានជំនួយពីសាច់ញាតិ ជាអាទិ៍

①-២. ស្ថានភាពកូន

- អាយុ

- ស្ថានភាពនៃការលូតលាស់រូបរាងកាយ

- ស្ថានភាពផ្លូវចិត្ត ផ្នត់គំនិត ឆន្ទៈរបស់កូន

- ក្តីស្រឡាញ់

- ភាពស្និទ្ធស្នាលជាបងប្អូន (ករណីមានបងប្អូនពីរនាក់ ឬច្រើននាក់ អាចមានភាពស្និទ្ធស្នាលខ្លាំង មិនគួរបំបែកចេញពីគ្នា[13])

② យោបល់របស់កូន ដោយថ្លឹងថ្លែង និងពិចារណាទៅតាមអាយុ និងសភាពចាស់ទុំរបស់កូន (ម. ២២ ក.៤ នៃ ច.ន.ឋ.)

**២- ការបែងចែកទ្រព្យសម្បត្តិរួម** (**ម. ៩៨០ នៃ ក.រ.ណ.**)

**២.១- ការបែងចែកទ្រព្យសម្បត្តិរួមដោយភាគី**

ប្តីប្រពន្ធ អាចពិភាក្សាគ្នាបែងចែកទ្រព្យសម្បត្តិរួម ដោយយុត្តិធម៌ ។

**២.២- ការបែងចែកទ្រព្យសម្បត្តិរួមដោយតុលាការ**

ក្នុងករណីដែលគ្មានការពិភាក្សា (ឬគ្មានការព្រមព្រៀង) នោះ តុលាការ ជាអ្នកសម្រេច

លក្ខខណ្ឌក្នុងការបែងចែកទ្រព្យសម្បត្តិរួមដោយតុលាការ[14] ៖

① ការទទួលស្គាល់ការទាមទារលែងលះគ្នា

② មានទ្រព្យសម្បត្តិរួម

③ ប្តីប្រពន្ធ ពិភាក្សាគ្នាពុំបានសម្រេច ឬពុំអាចពិភាក្សាគ្នាបាន

(ក្នុងករណីដែលសហព័ទ្ធម្ខាង ទាមទារលើសពីចំណែកពាក់កណ្តាល ត្រូវបង្ហាញស្ថានភាពពិសេស)

**២.៣- វិធីកំណត់ការបែងចែកទ្រព្យសម្បត្តិរួមដោយតុលាការ**

① ការកំណត់ជាក់លាក់អំពីទ្រព្យសម្បត្តិរួម

13. នេះជាទ្រឹស្តីទូទៅ ហើយពុំមែនមានន័យថា ទ្រឹស្តីនេះត្រូវនឹងគ្រប់ករណីឡើយ។

14. ចំណុច ①, ② និង ③ គឺជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ (ករណីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល គឺ ម. ១ និង ម. ២២ នៃ ច.ន.ឋ. និង ម. ៧៥ ក.២ ក.ន.ណ.។ ករណីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង គឺ ម. ២៦ ក. ២ ច. ខ នៃ ច.ន.ម.)។



www.moj.gov.kh/kh/book-library

ធ្វើការកំណត់ ឬវែកញែកឱ្យដាច់ថា ទ្រព្យសម្បត្តិណាជា ទ្រព្យសម្បត្តិដោយឡែក (ម. ៩៧២ នៃ ក.រ.ណ.) និងទ្រព្យសម្បត្តិណាជា ទ្រព្យសម្បត្តិរួម (ម. ៩៧៣ នៃ ក.រ.ណ.) ព្រោះទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបែងចែក ដោយតុលាការ ជាទ្រព្យសម្បត្តិរួម (ទ្រព្យសកម្ម) តែប៉ុណ្ណោះ (ម. ៩៨០ ក. ២ ច. ២ នៃ ក.រ.ណ.)[15] ។

ការវាយតម្លៃទ្រព្យសម្បត្តិ ធ្វើឡើងតែចំពោះទ្រព្យសម្បត្តិរួមតែប៉ុណ្ណោះ។

ចាំបាច់ត្រូវមានការវាយតម្លៃ លើតម្លៃនៃទ្រព្យសម្បត្តិរួមដែលជាកម្មវត្ថុនៃការបែងចែក (គប្បីដឹង អំពីតម្លៃនៃទ្រព្យសម្បត្តិរួមនីមួយៗ និងមានមូលដ្ឋានច្បាស់លាស់ក្នុងការជ្រើសរើសវិធីបែងចែកដែលល្អប្រសើរ)។

② ការវាយតម្លៃទ្រព្យសម្បត្តិរួម

③ ចំណែកនៃការបែងចែកទ្រព្យសម្បត្តិរួម (ម. ៩៨០ នៃ ក.រ.ណ.)

គោលការណ៍ ៖ សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលបាន ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម (ម. ៩៨០ ក. ២. ច. ខ នៃ ក.រ.ណ.)

អញ្ញត្រកម្ម ៖ សហព័ទ្ធ មានសិទ្ធិស្នើសុំលើសពីចំណែក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម (បើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង) (ម. ៩៨០ ក. ២. ច. ខ វ. ២ នៃ ក.រ.ណ.)

- ទំហំនៃការបរិច្ចាគរបស់សហព័ទ្ធ
- ទំហំនៃការបរិច្ចាគរបស់សហព័ទ្ធចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ
- ការថែរក្សា ឬការបង្កើនទ្រព្យ[16]
- អំឡុងពេលអាពាហ៍ពិពាហ៍
- កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍
- អាយុ
- ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ
- វិជ្ជាជីវៈ
- ប្រាក់ចំណូល
- លទ្ធភាពធ្វើការងាររបស់សហព័ទ្ធនីមួយៗ
- ផលប្រយោជន៍របស់កូន ជាអាទិ៍

គេហកិច្ចត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះ (ម. ៩៨០ ក. ៣ នៃ ក.រ.ណ.)

---

15. កាតព្វកិច្ចដោយសាមគ្គីភាពរបស់ប្តីប្រពន្ធ (ម. ៩៧៥ នៃ ក.រ.ណ.) មិនអាចបែងចែក តាមការបែងចែកទ្រព្យសម្បត្តិបានទេ ដោយហេតុថា ម្ចាស់បំណុល អាចទាមទារឱ្យប្តីប្រពន្ធទាំងសងខាងអនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគ ដោយព្រមគ្នា ឬដោយបន្តបន្ទាប់បាន (ម. ៩២១ ក. ១ នៃ ក.រ.ណ.) ហេតុនេះ ប្រសិនបើមានការបែងចែកបំណុលរវាងប្តីប្រពន្ធដោយស្រេចតែចិត្តបែបនេះ វានឹងធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់ម្ចាស់បំណុល (តតិយជន)។

16. នៅក្នុងមាត្រា ៩៨០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី គឺមានពាក្យពេចន៍ដូចការសរសេរនេះ។ ប៉ុន្តែ បញ្ញត្តិនេះ គប្បីបកស្រាយ ដោយផ្អែកលើគោលបំណងរបស់អ្នកនីតិករ តាមអត្ថន័យដូចខាងក្រោម ៖

- ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ
- ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះការថែរក្សា ឬ ការបង្កើនទ្រព្យ



www.moj.gov.kh/kh/book-library

④ វិធីនៃការបែងចែកទ្រព្យសម្បត្តិរួម (ម. ៩៨០ និង ម. ២១២ នៃ ក.រ.ណ.)[17]៖

- បំប្លែងស្ថានភាពគតិយុត្តនៃទ្រព្យសម្បត្តិ ពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ទៅជា វត្ថុកម្មសិទ្ធិអវិភាគ

- បែងចែកវត្ថុតាមរូបដើម

- ឱ្យលក់ដេញថ្លៃ ហើយចែកប្រាក់លក់នោះតាមចំណែក

- ផ្ទេរចំណែកទ្រព្យសម្បត្តិរួមឱ្យទៅសហព័ទ្ធម្ខាងទៀត ដោយឱ្យបង់ប្រាក់សំណងនៃចំណែកនោះ

## ៣- ការកំណត់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (ម. ១០៤០ នៃ ក.រ.ណ.)

### ៣.១- ការកំណត់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដោយភាគី

ប្តីប្រពន្ធ អាចពិភាក្សាគ្នាអំពីសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។

### ៣.២-ការកំណត់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដោយតុលាការ

ក្នុងករណីដែលការពិភាក្សាគ្នាពុំបានសម្រេច ឬពុំអាចពិភាក្សាគ្នាបាន តុលាការជាអ្នកសម្រេច។

#### ៣.២.១- លក្ខខណ្ឌក្នុងការកំណត់បន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដោយតុលាការ[18]

① ការទទួលស្គាល់ការទាមទារលែងលះគ្នា

② កូនជាអនីតិជន

③ ឪពុកម្តាយ ពិភាក្សាគ្នាពុំបានសម្រេច ឬពុំអាចពិភាក្សាគ្នាបាន អំពីចំនួនសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (ម. ១០៤០ ក. ៤ នៃ ក.រ.ណ.)

#### ៣.២.២- ចំណុចដែលតុលាការត្រូវពិចារណានៅពេលកំណត់បន្ទុកសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

① ពិចារណាស្ថានភាពនៃជីវភាព និងសេដ្ឋកិច្ចរបស់សហព័ទ្ធនីមួយៗ (ម. ១០៤០ ក. ៦ នៃ ក.រ.ណ.)

- ប្រាក់ចំណូលរបស់សហព័ទ្ធនីមួយៗ

- បន្ទុកចំណាយដើម្បីគ្រប់គ្រងថែរក្សាកូននៅមុនពេលលែងលះ

- កម្រិតស្តង់ដារអប្បបរមានៃជីវភាពសម្រាប់ចំណាយនៅក្នុងការរស់នៅ

② ត្រូវកំណត់ឱ្យច្បាស់អំពីចំនួនទឹកប្រាក់ដែលត្រូវបង់ រយៈពេលបង់ និងវិធីបង់ទាក់ទងនឹងសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

- ឱ្យបង់សោហ៊ុយនេះ ប្រចាំខែ ជាអាទិ៍

---

17. តតិយជន ក្រៅពីសហព័ទ្ធ (ឧ. កូន) មិនអាចទទួលបានទ្រព្យសម្បត្តិពីការបែងចែកទ្រព្យសម្បត្តិរួម ដោយតុលាការទេ។ អ្នកដែលអាចទទួលបានទ្រព្យសម្បត្តិតាមរយៈការបែងចែកទ្រព្យសម្បត្តិរួមដោយតុលាការ គឺសហព័ទ្ធ (ម. ៩៨០ ក. ២ ច. ក និង ច. ខ នៃ ក.រ.ណ.) មិនមែនតតិយជនឡើយ។

18. ចំណុច ①, ② និង ③ គឺជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ (ករណីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល គឺ ម. ១ និង ម. ២២ នៃ ច.ន.ឋ. និង ម. ៧៥ ក. ២ ក.ន.ណ. ។ ករណីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង គឺ ម. ២៦ ក. ២ ច. ខ នៃ ច.ន.ម.) ។



www.moj.gov.kh/kh/book-library

នៅក្នុងប្រទេសជប៉ុន ការគណនាអំពីសោហ៊ុយនេះ គឺមានរូបមន្តច្បាស់លាស់[19]។

### ៤- ការកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន (ម.១០៤០ នៃ ក.រ.ណ.)

#### ៤.១- ការកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន ដោយភាគី

ប្ដីប្រពន្ធ អាចពិភាក្សា ឬព្រមព្រៀងគ្នា អំពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។

#### ៤.២-ការកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូនដោយតុលាការ

ក្នុងករណីដែលពិភាក្សាគ្នាពុំបានសម្រេច ឬ ពុំអាចពិភាក្សាគ្នាបាន តុលាការជាអ្នកសម្រេច។

##### ៤.២.១- លក្ខខណ្ឌក្នុងការកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូនដោយតុលាការ[20]

① ការទទួលស្គាល់ការទាមទារលែងលះគ្នា

② កូនជាអនីតិជន

③ ឪពុកម្ដាយ ពិភាក្សាគ្នាពុំបានសម្រេច ឬពុំអាចពិភាក្សាគ្នាបាន អំពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន (ម. ១០៤០ ក. ៤ នៃ ក.រ.ណ.)។

##### ៤.២.២- ចំណុចដែលតុលាការត្រូវពិចារណានៅពេលកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន

① ផលប្រយោជន៍កូនជាអាទិភាព (ម. ១០៤០ ក. ៦ នៃ ក.រ.ណ.)

- ពេលវេលារបស់កូន

- ស្ថានភាពសុខភាពរបស់កូន

- ស្ថានភាពផ្សេងទៀត ដែលកូនគួរ ឬមិនគួរជួបអ្នកដែលគ្មានអំណាចមេបា ឧ. ធ្លាប់ប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ឬប្រើប្រាស់អំពើហិង្សា ជាអាទិ៍

② គប្បីសរសេរកំណត់ឱ្យបានច្បាស់លាស់អំពីវិធីចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ដូចជា

- ថ្ងៃ និង ម៉ោង ឬ ចំនួនដង នៃការជួបប្រាស្រ័យទាក់ទងជាមួយកូន

- រយៈពេល ដែលត្រូវចូលជួបមួយលើកៗ

- វិធីនៃការប្រគល់កូន

### ៥- ការកំណត់អំពីអាហារកិច្ច (ម. ៧៦ នៃ ច.អ.គ.)

* សូមពិនិត្យមើលការពន្យល់បន្ថែម នៅក្នុងសេចក្ដីកំណត់មាត្រា ៧៨ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

---

19. សូមមើលការពន្យល់បន្ថែម នៅក្នុងឧបសម្ព័ន្ធទី ៣ ។

20. ចំណុច ①, ② និង ③ គឺជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ (ករណីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល គឺ ម. ១ និង ម. ២២ នៃ ច.ន.ឋ. និង ម. ៧៥ ក. ២ ក.ន.ណ. ។ ករណីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង គឺ ម. ២៦ ក. ២ ច. ខ នៃ ច.ន.ម.) ។



www.moj.gov.kh/kh/book-library

* បញ្ញត្តិស្តីពីអាហារកិច្ច ដែលមានចែងនៅក្នុងមាត្រា ៧៦ និងមាត្រា ៧៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ មិនមានចែងនៅក្នុងក្រមរដ្ឋប្បវេណីទេ។ ប្រសិនបើ សហព័ទ្ធដែលត្រូវការអាហារកិច្ចក្រោយលែងលះ នឹងមានភាពក្រលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាពក្រោយការលែងលះ តុលាការអាចច្រានចោលការទាមទារលែងលះ (ម.៩៧៨ ក.២នៃក.រ.ណ.)។ ម្យ៉ាងទៀត នៅក្នុងករណីដែលសហព័ទ្ធទាមទារលែងលះ ដោយសារសហព័ទ្ធម្ខាងទៀតបង្កើតនូវមូលហេតុដែលធ្វើឱ្យបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍ ដូចជា អំពើផិតក្បត់ ឬអំពើហិង្សា ជាអាទិ៍ នោះបញ្ហាទាក់ទងនឹងការទាមទារអាហារកិច្ច អាចត្រូវបានដោះស្រាយតាមរយៈប្រាក់សំណងជំងឺចិត្ត (ការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល)។

អាហារកិច្ច អាចត្រូវបានផ្តល់ជាទឹកប្រាក់ ឬជារបស់ (ម. ៧៧ នៃ ច.អ.គ.)។

### ៥.១- ការកំណត់អំពីអាហារកិច្ចដោយភាគី

ប្តីប្រពន្ធ អាចពិភាក្សា ឬព្រមព្រៀងអំពីកម្រិតអាហារកិច្ច ដែលត្រូវបង់ឱ្យសហព័ទ្ធដែលខ្វះខាត។

### ៥.២- ការកំណត់អំពីអាហារកិច្ចដោយតុលាការ

ក្នុងករណីដែលប្តីប្រពន្ធ មិនឯកភាពគ្នា តុលាការជាអ្នកសម្រេច។

#### ៥.២.១- លក្ខខណ្ឌដែលនាំឱ្យកើតមានសិទ្ធិទាមទារឱ្យកំណត់អំពីអាហារកិច្ច[21]

① ការទទួលស្គាល់ការទាមទារលែងលះគ្នា

② ប្តីឬប្រពន្ធដែលធ្វើការទាមទារអាហារកិច្ច គ្មានកំហុស ហើយមានជីវភាពខ្វះខាត

③ ប្តីនិងប្រពន្ធ មិនឯកភាពគ្នាក្នុងការបង់អាហារកិច្ច

#### ៥.២.២- ចំណុចដែលតុលាការត្រូវពិចារណានៅពេលកំណត់អំពីអាហារកិច្ច

① កម្រិតជីវភាព (ប្រាក់ចំណូល) របស់ ប្តី ឬ ប្រពន្ធ

② កម្រិតខ្វះខាតនៃប្តី ឬប្រពន្ធដែលគ្មានកំហុស

③ ទំហំនៃកំហុសដែលបណ្តាលឱ្យមានការលែងលះ ជាអាទិ៍

21. ចំណុច ① ② និង ③ គឺជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ (ម. ៧៥ ក. ២ នៃ ក.ន.ណ.)។ បន្ថែមពីលើនេះ អាពាហ៍ពិពាហ៍ស្របច្បាប់ និងចំណុច ① គឺជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ។



www.moj.gov.kh/kh/book-library

## ផ្នែកទី ៣ ៖ នីតិវិធីសម្រាប់ការទាមទារលែងលះ

មាននីតិវិធីពីរ ដែលត្រូវយកមកអនុវត្តក្នុងការទាមទារលែងលះ :

| **ល.រ** | **ស្ថានភាព** | **នីតិវិធី** | |
|---|---|---|---|
| | | នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល | នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង |
| **១** | ការលែងលះ តាមបញ្ញត្តិមាត្រា ៩៧៨ (គ្មានការព្រមព្រៀងលែងលះ) | ✓ | |
| **២** | ការលែងលះ តាមបញ្ញត្តិមាត្រា ៩៧៩ (មានការព្រមព្រៀងលែងលះ) | | ✓ |

ករណីលែងលះដែលមានកូនជាអនីតិជន[22] នីតិវិធីនឹងមានដូចខាងក្រោម ៖

| **ល.រ** | **ស្ថានភាព** | **នីតិវិធី** | |
|---|---|---|---|
| | | នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល | នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង |
| **១** | មានការព្រមព្រៀងលែងលះ និង ការព្រមព្រៀងកំណត់អ្នកមានអំណាចមេបា | | ✓ |
| **២** | មានការព្រមព្រៀងលែងលះ និង គ្មានការព្រមព្រៀងកំណត់អ្នកមានអំណាចមេបា | ✓ | |

22. ការសម្រេចអំពីការលែងលះ និងការកំណត់អ្នកមានអំណាចមេបា ត្រូវធ្វើឡើងនៅក្នុងសេចក្តីសម្រេចតែមួយ ដោយមិនអាចសម្រេចមុនក្រោយ។ ប៉ុន្តែ ការសម្រេចពាក់ព័ន្ធនឹងការបែងចែកទ្រព្យ និងការចាត់ចែងទាក់ទងនឹងកូន (ការកំណត់បន្ទុកសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន និងការកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន) អាចសម្រេចនៅក្នុងដីកាសម្រេច តាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បន្ទាប់ពីមានសេចក្តីសម្រេចលែងលះបាន។



www.moj.gov.kh/kh/book-library

| | | | |
|---|---|---|---|
| ៣ | គ្មានការព្រមព្រៀងលែងលះ និង ការព្រមព្រៀងកំណត់អ្នកមានអំណាចមេបា | ✓ | |
| ៤ | គ្មានការព្រមព្រៀងលែងលះ និង គ្មានការព្រមព្រៀងកំណត់អ្នកមានអំណាចមេបា | ✓ | |

### ១- នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល[23]

- ការលែងលះ តាមបញ្ញត្តិមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (ម. ៣ ច. គ នៃ ច.ន.ឋ.)។

- នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល គឺអនុវត្តតាមនីតិវិធីបណ្តឹងរដ្ឋប្បវេណី ដែលចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងមានចែងពិសេសនៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (ម. ១ នៃ ច.ន.ឋ.)។

- នីតិវិធីជារួម ៖ ការដាក់ពាក្យបណ្តឹង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការប្រកាសសាលក្រម។

#### ១.១- បញ្ញត្តិពិសេសនៅក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

- ការបញ្ចូលការទាមទារដែលពាក់ព័ន្ធ (ម. ១១ នៃ ច.ន.ឋ.)

- ការបន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង និងបណ្តឹងតប (ម. ១២ នៃ ច.ន.ឋ.)

- បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលមិនត្រូវយកមកអនុវត្ត (ម. ១៣ នៃ ច.ន.ឋ.)

- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ (ម. ១៤ នៃ ច.ន.ឋ.)

- ការបង្គាប់ឱ្យសាមីភាគីបង្ហាញខ្លួន (ម. ១៥ នៃ ច.ន.ឋ.)

- ការមិនធ្វើជាសាធារណៈនៃការទាញហេតុផលដោយផ្ទាល់មាត់ (ម. ១៦ នៃ ច.ន.ឋ.)

- វិសាលភាពនៃបុគ្គលដែលទទួលនូវអានុភាពនៃសាលក្រម (ម. ១៧ នៃ ច.ន.ឋ.)

- ការហាមមិនឱ្យដាក់បណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្រោយពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរ (ម. ១៨ នៃ ច.ន.ឋ.)

- មរណភាពរបស់ដើមចោទ (ម. ១៩ នៃ ច.ន.ឋ.)

- មរណភាពរបស់ចុងចម្លើយ (ម. ២០ នៃ ច.ន.ឋ.)

#### ១.២- បណ្តឹង

23. រាល់ចំណុចដែលបានរៀបរាប់នៅក្នុងផ្នែកនេះ ចង់បង្ហាញឱ្យឃើញពីចំណុចគោលដែលមាននៅក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មិនមែនមានន័យថាជា Check List សម្រាប់អនុវត្តនៅក្នុងនីតិវិធីទេ ។


www.moj.gov.kh/kh/book-library

① តុលាការដែលមានសមត្ថកិច្ច (ម. ១០ នៃ ក.ន.ណ. និង ម. ៥ នៃ ច.ន.ប.) ៖

- សមត្ថកិច្ចផ្ដាច់មុខ

- សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គល ដែលពាក់ព័ន្ធនឹងបណ្ដឹងនោះ (ប្ដីឬប្រពន្ធ)

② ខ្លឹមសារ និងទម្រង់នៃពាក្យបណ្ដឹង អនុវត្តតាមបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

③ ការពិនិត្យពាក្យបណ្ដឹង (ម. ៧៨ នៃ ក.ន.ណ.) និងការបញ្ជូនពាក្យបណ្ដឹង (ម. ៧៩ នៃ ក.ន.ណ.)

④ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង និងការកោះហៅគូភាគី (ម. ៨០ នៃ ក.ន.ណ.)

## ១.៣- ការទាញហេតុផលដោយផ្ទាល់មាត់ និងការរៀបចំ

① ឯកសារត្រៀម ៖ អាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម (មធ្យោបាយតទល់ ឬការពារខ្លួន) (ម. ១០១ នៃ ក.ន.ណ.)

② ការផ្សះផ្សា អាចធ្វើបានគ្រប់កាលបរិច្ឆេទនៃនីតិវិធី.[24](ម. ៩៨៤ ក. ១ នៃ ក.រ.ណ.)

- កម្មវត្ថុនៃការផ្សះផ្សា ៖ ត្រូវផ្សះផ្សាឱ្យគូភាគីព្រមព្រៀងគ្នា ឈប់លែងលះ.[25]

- ប្រសិនបើការផ្សះផ្សាជោគជ័យ (គូភាគីព្រមព្រៀងគ្នា ឈប់លែងលះ) តុលាការ គប្បីណែនាំឱ្យដើមចោទដកពាក្យបណ្ដឹងលែងលះ.[26]

---

24. សូមប្រុងប្រយ័ត្នពីភាពខុសគ្នារវាងការផ្សះផ្សាតាមមាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណី និង ការផ្សះផ្សា (ការសះជា) តាមមាត្រា ២២០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ការផ្សះផ្សា តាមបញ្ញត្តិមាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណី ជាការផ្សះផ្សា ផ្អែកតាមច្បាប់សារធាតុ ដែលមានកម្មវត្ថុតែមួយគត់ គឺផ្សះផ្សាឱ្យគូភាគីព្រមព្រៀងគ្នា ឈប់លែងលះ ហើយដកពាក្យបណ្ដឹងលែងលះ។ ចំណែក ការផ្សះផ្សា តាមបញ្ញត្តិមាត្រា ២២០ និងមាត្រា ៩៧ ព្រមទាំងមាត្រា ១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ជាការផ្សះផ្សា ផ្អែកតាមច្បាប់នីតិវិធី ដែលមិនអាចយកមកអនុវត្តនៅក្នុងនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលទេ។ ប្រធាននៃការផ្សះផ្សា គឺភាគី។ តុលាការជាអ្នកណែនាំទៅកាន់ភាគី ឱ្យភាគីធ្វើការផ្សះផ្សា (ពាក្យ «សាកល្បងផ្សះផ្សា» នៅក្នុង ម. ៩៧ និង ម. ១០៤ នៃ ក.ន.ណ មិនមែនមានន័យថា «តុលាការសាកល្បងធ្វើការផ្សះផ្សា» នោះទេ ប៉ុន្តែ មានន័យថា «តុលាការណែនាំភាគីឱ្យធ្វើការផ្សះផ្សា រួចសាកល្បងឱ្យធ្វើការផ្សះផ្សារវាងភាគី«។)។
ក្នុងបណ្ដឹងទាមទារលែងលះ តុលាការអាចណែនាំឱ្យភាគីព្រមព្រៀងត្រូវគ្នាវិញ ឈប់លែងលះ («ការផ្សះផ្សា» ផ្អែកតាម ម. ៩៨៤ នៃ ក.រ.ណ.) រួចដោយសាកល្បងឱ្យភាគីធ្វើការផ្សះផ្សា នៅគ្រប់កាលបរិច្ឆេទនៃនីតិវិធី (សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ម. ៩៨៤)។ ទោះបីជា ការផ្សះផ្សានេះបានសម្រេច (មានន័យថា ប្ដីប្រពន្ធនោះត្រូវគ្នាវិញ) ក៏ដោយក្ដី ក៏តុលាការមិនអាចធ្វើកំណត់ហេតុសះជានៃការលែងលះបានឡើយ ហើយប្ដីឬប្រពន្ធដែលប្ដឹងទាមទារលែងលះត្រូវធ្វើការដកពាក្យបណ្ដឹង តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងករណីដែលដើមចោទមិនដកពាក្យបណ្ដឹង តុលាការត្រូវធ្វើការវិនិច្ឆ័យលើពាក្យបណ្ដឹងនោះ រួចចេញសាលក្រមច្រានចោលការទាមទារ ដោយសារតែគ្មានមូលហេតុនៃការលែងលះ (ដោយសារតែ ម. ១៣ ក.២ នៃ ច.ន.ប. មិនអនុវត្ត ម. ២២០ និង ម. ២២២ នៃ ក.ន.ណ. ឡើយ)។ ដើមចោទត្រូវដកពាក្យបណ្ដឹង ហើយប្រសិនបើភាគីទាំងសងខាង អវត្តមាននៅកាលបរិច្ឆេទនៃនីតិវិធី នោះត្រូវចាត់ទុកថាបានដកពាក្យបណ្ដឹង តាមមាត្រា ២១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
គូភាគីមិនអាចធ្វើការផ្សះផ្សាឱ្យសះជា ដោយផ្អែកលើការព្រមព្រៀងគ្នាលែងលះបានទេ ហើយតុលាការក៏មិនអាចសាកល្បងណែនាំការផ្សះផ្សាឱ្យភាគីទទួលស្គាល់ការទាមទារលែងលះបានឡើយ។ ទោះបីជាក្រោយពីការដាក់ពាក្យបណ្ដឹង ភាគីបានព្រមព្រៀងគ្នាលែងលះនៅចំពោះមុខតុលាការក៏ដោយ ក៏តុលាការមិនអាចចេញកំណត់ហេតុសះជាឡើយ។ ក្នុងស្ថានភាពនេះ ដើមចោទអាចដកពាក្យបណ្ដឹងទាមទារលែងលះ និងបន្ទាប់មក ភាគីអាចដាក់ពាក្យសុំលែងលះដោយការព្រមព្រៀងអនុលោមតាមច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង។ ក្នុងករណីដែលភាគីមិនដកពាក្យបណ្ដឹង តុលាការត្រូវយកបណ្ដឹងទាមទារលែងលះនោះមកវិនិច្ឆ័យ ហើយចេញសាលក្រម (ដោយសារ ម. ១៣ ក.២ នៃ ច.ន.ប. មិនអនុវត្ត ម. ២២០ និង ម. ២២២ នៃ ក.ន.ណ.)។

25. «ការផ្សះផ្សា» នៅក្នុងមាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណី អនុញ្ញាតឱ្យភាគីព្រមព្រៀងគ្នាមិនលែងលះ ដោយពុំចាំបាច់ឈានទៅដល់ការព្រមព្រៀងរួមរស់ជាមួយគ្នាវិញនោះទេ។ នេះដោយសារតែ ទោះបីជាមានទំនាក់ទំនងអាពាហ៍ពិពាហ៍ក៏ដោយក្ដី ក៏អាចមានករណីរស់នៅបែកគ្នា ទៅតាមស្ថានភាពផ្សេងដែរ។

26. ការដកពាក្យបណ្ដឹង អាចធ្វើជាលាយលក្ខណ៍អក្សរ ឬអាចធ្វើឡើងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនីតិវិធី។ ករណីធ្វើឡើងដោយផ្ទាល់មាត់ នៅក្នុងកាលបរិច្ឆេទនៃនីតិវិធី ខ្លឹមសារនៃការដកពាក្យបណ្ដឹងត្រូវកត់ត្រាចូលក្នុងកំណត់ហេតុ (ម.២១៧ ក.២, ក.៣ និង ក.៤, ម.១១១ ច.ឃ និង ម.១១៩ ក.១ ច.កនៃក.ន.ណ.)។



www.moj.gov.kh/kh/book-library

- មិនអាចធ្វើការផ្សះផ្សាដើម្បីឱ្យគូភាគីលែងលះគ្នា (មិនអាចផ្សះផ្សាលើបណ្ដឹងលែងលះបានទេ) តាមកំណត់ហេតុស្ដីពីការសះជា (ម. ១៣ នៃ ច.ន.ប. មិនយក ម. ២២០ និង ម. ២២២ នៃ ក.ន.ណ. មកអនុវត្តទេ)

③ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

- រៀបចំការអះអាង (ម. ១០៣ នៃ ក.ន.ណ.)

- រៀបចំចំណុចវិវាទ (ម. ១០៣ នៃ ក.ន.ណ.)

- រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទ (ម. ១០៣ នៃ ក.ន.ណ.)

- សកម្មភាពនៃបណ្ដឹង ជាអាទិ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ម. ១០៦ នៃ ក.ន.ណ.)

- ការបញ្ជាក់អំពីអង្គហេតុដែលនឹងត្រូវបំភ្លឺ (ម. ១០៧ នៃ ក.ន.ណ.)

- ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងការកោះហៅគូភាគី (ម. ១១៣ នៃ ក.ន.ណ.)

④ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

- ថ្លែងការណ៍អំពីលទ្ធផលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ម. ១១៦ ក. ១ និង ក. ២ នៃ ក.ន.ណ.)

- ពិនិត្យភស្តុតាងជាសមូហវិធី (ម. ១២៧ នៃ ក.ន.ណ.)

- ទាញហេតុផលចុងក្រោយ (ម. ១១៦ ក. ៥ នៃ ក.ន.ណ.)

### ១.៤- ការសម្រេចសេចក្ដី

- សេចក្ដីសម្រេច ៖ សាលក្រម

- សាលក្រម ត្រូវប្រកាសជាសាធារណៈ ក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ (ម. ១៨៧ នៃ ក.ន.ណ.)

- របៀបនៃការប្រកាស ៖ ប្រកាសតាមកាលបរិច្ឆេទ នៅក្នុងបន្ទប់សវនាការជាសាធារណៈ ដោយអានសេចក្ដីសម្រេចបញ្ចប់ ផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (ម. ១៨៨ នៃ ក.ន.ណ.)

- ការបញ្ជូនលិខិតសាលក្រម ៖ ក្នុងអំឡុងពេល ០២ (ពីរ) សប្ដាហ៍ គិតចាប់ពីថ្ងៃប្រកាសសាលក្រម (ម. ១៩០ នៃ ក.ន.ណ.)

- អានុភាពនៃសាលក្រម ៖ កើតមាននៅពេលប្រកាស (ម. ១៨៦ នៃ ក.ន.ណ.)

- អានុភាពអាជ្ញាអស់ជំនុំ ៖ កើតមាននៅពេលសាលក្រមចូលជាស្ថាពរ (ម. ១៩៤ ក. ១ នៃ ក.ន.ណ.)

---

ប្រសិនបើដើមចោទ មិនដកពាក្យបណ្ដឹង (បន្តបង្ហាញខ្លួននៅកាលបរិច្ឆេទ) តុលាការ នឹងវិនិច្ឆ័យលើបណ្ដឹងលែងលះរួចចេញសាលក្រម (ច្រានចោលការទាមទារ) ប្រសិនបើ ដើមចោទមិនដកពាក្យបណ្ដឹង ហើយអវត្តមាននៅក្នុងនីតិវិធី នោះត្រូវចាត់ទុកថា ដកពាក្យបណ្ដឹង តាមបញ្ញត្តិមាត្រា ២១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។



www.moj.gov.kh/kh/book-library

- សាលក្រមចូលជាស្ថាពរ ៖ នៅពេលផុតអំឡុងពេលសម្រាប់បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលស្របច្បាប់ (ម. ១៩៣ ក. ១ នៃ ក.ន.ណ.) ឬនៅពេលបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ត្រូវបានលើកចោលដោយតុលាការជាន់ខ្ពស់ (ម. ១៩៣ ក. ២ នៃ ក.ន.ណ.)

## ២- នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

- ការលែងលះ តាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ម. ៣ ក. ១ និង ផ. ៤ ច. ៥ នៃតារាងឧបសម្ព័ន្ធនៃ ច.ន.ម.)

- នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ជានីតិវិធីសម្រេចសេចក្តីត្រូវធ្វើឡើងដោយដីកាសម្រេច (ម. ៣ នៃ ច.ន.ម.)។ ក្រៅពីករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បញ្ញត្តិស្តីពីដីកាសម្រេច ដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ (ម. ៣ ក. ៣ នៃ ច.ន.ម.)

- នីតិវិធីជារួម ៖ ការដាក់ពាក្យសុំ នីតិវិធីសួរ/នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងដីកាសម្រេច។

### ២.១- ការដាក់ពាក្យសុំ

- តុលាការដែលមានសមត្ថកិច្ច ៖ តុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ (ម. ៤ ក. ១ និង ផ. ៤ ច. ៥ តារាងឧបសម្ព័ន្ធ នៃ ច.ន.ម.)

- ការជម្រះក្តីដោយចៅក្រមម្នាក់ ឬដោយក្រុមប្រឹក្សាជំនុំជម្រះ (ម. ១១ នៃ ច.ន.ម.)

- ភាគី៖ អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត និងជនពាក់ព័ន្ធ (ម. ១៥ នៃ ច.ន.ម.)

- សមត្ថភាពរបស់ជនពាក់ព័ន្ធ (ម. ១៦ នៃ ច.ន.ម.)

- សមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី (ម. ១៧ នៃ ច.ន.ម.)

- អ្នកតំណាងដោយអាណត្តិ ៖ សកម្មភាព និងលក្ខណៈសម្បត្តិ (ម. ១៨, ម. ១៩, ម. ២០ និង ម. ២១ នៃ ច.ន.ម.)

- ខ្លឹមសារ និងទម្រង់នៃពាក្យសុំ ៖ ធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ (ម. ២៦ ក. ១ និង ក. ៦ នៃ ច.ន.ម.)

- ចំណុចដែលត្រូវសរសេរ ៖

  + មាត្រា ២៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

  + លក្ខខណ្ឌបន្ថែម រួមមាន ការព្រមព្រៀងគ្នាលែងលះ និងការព្រមព្រៀងគ្នាលើអ្នកមានអំណាចមេបាក្នុងករណីដែលកូនជាអនីតិជន។



www.moj.gov.kh/kh/book-library

## ២.២- ការទាញហេតុផលដោយផ្ទាល់មាត់ ឬការសួរដោយឆន្ទានុសិទ្ធិ

- ការផ្សះផ្សា អាចធ្វើបានគ្រប់កាលបរិច្ឆេទនៃនីតិវិធី (ម. ៩៨៤ ក. ១ នៃ ក.រ.ណ.)

+ កម្មវត្ថុនៃការផ្សះផ្សា ៖ ត្រូវផ្សះផ្សាឱ្យគូភាគីព្រមព្រៀងគ្នាឈប់លែងលះ

+ ប្រសិនបើការផ្សះផ្សា ទទួលបានជោគជ័យ (គូភាគីព្រមព្រៀងគ្នាឈប់លែងលះ) អ្នកដាក់ពាក្យសុំគប្បីដកពាក្យសុំលែងលះវិញ

- នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ៖ ពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីចេញដីកាសម្រេចឡើយ (ម. ២៨ ក. ១ នៃ ច.ន.ម.)។ ប៉ុន្តែ ក្នុងករណីដែលឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ បញ្ញត្តិស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ការសាកសួរសាក្សី ការសាកសួរភាគី កោសលវិច័យ ការត្រួតពិនិត្យនិងភស្តុតាងជាឯកសារ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវអនុវត្តដូចគ្នាផងដែរ លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីនេះ (ម. ៣៤ ក. ២ នៃ ច.ន.ម.)

- ការសួរដោយឆន្ទានុសិទ្ធិ ៖ ក្នុងករណីមិនធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

+ អាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀត (ម. ២៨ ក. ២ វ. ១ នៃ ច.ន.ម.)

+ អាចអនុញ្ញាតឱ្យអ្នកដែលយល់ឃើញថាសមរម្យ ចូលស្តាប់បាន (ម. ២៨ ក. ២ វ. ២ នៃ ច.ន.ម.)

- ករណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន (ម. ២៩ នៃ ច.ន.ម.)

- ការចូលរួម ៖ ការចូលរួមដោយតំណាងអយ្យការ (ម. ៣០ នៃ ច.ន.ម.) និងការចូលរួមដោយជនពាក់ព័ន្ធនឹងផលប្រយោជន៍ (ម. ៣១ នៃ ច.ន.ម.)

- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ (ម. ២៧ ក. ១ នៃ ច.ន.ម.) ការស្រាវជ្រាវអង្គហេតុ និងការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ (ម. ២៧ ក. ២ នៃ ច.ន.ម.)

## ២.៣- ការសម្រេចសេចក្តី

- សេចក្តីសម្រេច ៖ ដីកាសម្រេច (ម.៣ ក. ២ នៃ ច.ន.ម.)

- ដីកាសម្រេច ៖ ត្រូវជូនដំណឹង តាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេច (ម. ៣៦ នៃ ច.ន.ម.)

- ការបង្កើតអានុភាពនៃដីកាសម្រេច[27] ៖ ដីកាសម្រេច មិនត្រូវបង្កើតអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ[28] (ម. ៣៧ ក. ៣ នៃ ច.ន.ម.)

---

27. ការពន្យល់បន្ថែមអំពីអានុភាពនៃដីកាសម្រេច មាននៅក្នុងឧបសម្ព័ន្ធទី ៤។

28. សូមប្រុងប្រយ័ត្នពីភាពខុសគ្នា ជាមួយនឹងមាត្រា ២១៣ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី (ដីកាសម្រេច នឹងមានអានុភាព លុះត្រាតែបានជូនដំណឹងតាមវិធីដែលទទួលស្គាល់ថាសមរម្យ)។



www.moj.gov.kh/kh/book-library

- ការចូលជាស្ថាពរនៃដីកាសម្រេច ៖ អំឡុងពេលសម្រាប់បណ្តឹងជំទាស់ (ម. ៤០ នៃ ច.ន.ម.) បានកន្លងផុត (ម. ៣៧ នៃ ច.ន.ម.) ឬនៅពេលដែលបណ្តឹងជំទាស់ត្រូវបានលើកចោលដោយតុលាការនៃបណ្តឹងជំទាស់ (ម. ៣៧ ក. ២ នៃ ច.ន.ម.)។

## ផ្នែកទី ៤ ៖ នីតិវិធីសម្រាប់ការទាមទារផ្សេងទៀត នៅក្នុងរឿងក្តីលែងលះ

ក្រៅពីការទាមទារឱ្យលែងលះ ដែលជាការទាមទារចម្បង ភាគីក៏អាចធ្វើការទាមទារផ្សេងទៀតនៅក្នុងរឿងក្តីលែងលះ ដូចជា ការកំណត់អ្នកមានអំណាចមេបា ការបែងចែកទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ការកំណត់បន្ទុកសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន និងការកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន ការទាមទារឱ្យកំណត់អាហារកិច្ច ជាអាទិ៍ ។

ដោយឡែកទោះបីជាបញ្ញត្តិច្បាប់ បានផ្តល់សិទ្ធិឱ្យភាគីអាចធ្វើការទាមទារបាន ក៏ប៉ុន្តែចំណុចនៃការទាមទារនេះ ក៏មិនមែនសុទ្ធតែអាចទាមទារខុសពីនីតិវិធីដែលបានកំណត់ដែរ។ ខាងក្រោមនេះ ជានីតិវិធីគ្របដណ្តប់លើការទាមទារផ្សេងៗនៃរឿងក្តីលែងលះ ៖

### ១- នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

### ១.១- ការកំណត់អ្នកមានអំណាចមេបា

- ការកំណត់អ្នកមានអំណាចមេបា ៖ ការសម្រេចដោយឆន្ទានុសិទ្ធិ ហើយត្រូវធ្វើឡើង ព្រមគ្នានៅក្នុងនីតិវិធីនៃការលែងលះ (ម. ១០៣៧ នៃ ក.រ.ណ. និង ម. ២២ ក. ១ នៃ ច.ន.ឋ.)

- នៅពេលតុលាការកំណត់អ្នកមានអំណាចមេបា ៖ តុលាការអាចបង្គាប់ឱ្យភាគីប្រគល់កូន (ម. ២២ ក. ២ នៃ ច.ន.ឋ.)

ប្រសិនបើប្តីប្រពន្ធបានព្រមព្រៀងគ្នាអំពីការកំណត់អ្នកមានអំណាចមេបា៖តុលាការត្រូវសរសេរនូវការកំណត់អ្នកមានអំណាចមេបាតាមការព្រមព្រៀងនេះ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម។

### ១.២- ការចាត់ចែងទាក់ទងនឹងការចំបាច់ថែរក្សាកូន និងការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិរួម

- ការបែងចែកទ្រព្យសម្បត្តិរួមប្តីប្រពន្ធ (ម. ២២ ក. ១ នៃ ច.ន.ឋ.) ការកំណត់បន្ទុកសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (ម. ១០៤០ ក. ៤ នៃ ក.រ.ណ. និង ម. ២២ ក. ១ នៃ ច.ន.ឋ.) និងការកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន (ម. ១០៤០ ក. ៤ នៃ ក.រ.ណ. និង ម. ២២ ក. ១ នៃ ច.ន.ឋ.) ត្រូវសម្រេចតាមពាក្យសុំ ដោយមិនអាចប្រើឆន្ទានុសិទ្ធិបានឡើយ។

- នីតិវិធីនឹងសម្រេចរួមគ្នាជាមួយនឹងបណ្តឹងទាមទារលែងលះ (ម. ២២ ក. ១ នៃ ច.ន.ឋ.)

+ កំណត់នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលទទួលស្គាល់ការទាមទារលែងលះ



www.moj.gov.kh/kh/book-library

+ ប្រសិនបើមិនបានដាក់ពាក្យសុំ នៅក្នុងពាក្យបណ្ដឹងទាមទារលែងលះទេ ប្ដីឬប្រពន្ធ អាចដាក់ពាក្យសុំតាមក្រោយ នៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

## ២- នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

### ២.១- ការកំណត់អ្នកមានអំណាចមេបា[29]

ការលែងលះដោយការព្រមព្រៀង ត្រូវពិភាក្សាគ្នារវាងប្ដីប្រពន្ធថា តើនរណាជាអ្នកមានអំណាចមេបា?[30]

- អំណាចមេបា៖ អាចសម្រេច នៅក្នុងដីកាសម្រេចលែងលះបាន តែក្នុងករណីដែលគូភាគី មិនមានវិវាទអំពីការកំណត់អ្នកមានអំណាចមេបា។

- ទោះបីជាមិនមានពាក្យសុំ ក៏តុលាការត្រូវសរសេរអំពីការកំណត់អ្នកមានអំណាចមេបាក្នុងសេចក្ដីសម្រេចបញ្ចប់នៃដីកាសម្រេច ហើយត្រូវធ្វើឡើងព្រមគ្នាជាមួយដីកាសម្រេចលែងលះ។

### ២.២- ការចាត់ចែងទាក់ទងនឹងការបីបាច់ថែរក្សាកូន និងការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ

- ការបែងចែកទ្រព្យសម្បត្តិរួមប្ដីប្រពន្ធ ការកំណត់បន្ទុកសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន និងការកំណត់អំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន ៖ អាចសម្រេច

+ នៅក្នុងដីកាសម្រេចជាមួយនឹងពាក្យសុំលែងលះដោយការព្រមព្រៀង

+ នៅក្នុងដីកាសម្រេចដោយឡែក ក្រោយការលែងលះ (លែងលះតាមផ្លូវបណ្ដឹង ឬលែងលះដោយការព្រមព្រៀង)

- ការសម្រេចដោយដីកាសម្រេច (ម. ៣. ក. ២ និងតារាងឧបសម្ព័ន្ធនៃ ច.ន.ម.)

## ៣- នីតិវិធីបណ្ដឹងរដ្ឋប្បវេណី

- អាហារកិច្ច[31] (ម. ៧៦ នៃ ច.អ.គ.) អាចទាមទារបានតាមនីតិវិធីបណ្ដឹងរដ្ឋប្បវេណី[32]

- ការទាមទារឱ្យកំណត់អំពីអាហារកិច្ច៖

+ មិនស្ថិតនៅក្នុងវិសាលភាពនៃមាត្រា ៣ និងមាត្រា ២២ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល

+ មិនមាននៅក្នុង តារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនបណ្ដឹង

---

29. សូមអានការពន្យល់បន្ថែម នៅក្នុងឧបសម្ព័ន្ធទី ២ ។

30. ទាក់ទងនឹង «ការព្រមព្រៀងអំពីអ្នកមានអំណាចមេបា» ជាលក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង សូមមើល ក. ប្រភេទ និងលក្ខខណ្ឌនៃការលែងលះ ២. ការលែងលះដោយការព្រមព្រៀង ចំណុច ③។

31. សូមអានការពន្យល់បន្ថែម នៅក្នុងឧបសម្ព័ន្ធទី ៥ ។

32. សូមមើលសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្ដឹង។



www.moj.gov.kh/kh/book-library

## ផ្នែកទី ៥ ៖ ការតាក់តែងសេចក្ដីសម្រេច

### ១- សាលក្រម

- ទម្រង់លិខិតសាលក្រម ៖ អនុលោមតាមទម្រង់អប្បបរមា (ម.១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

- ពាក្យពេចន៍នៃសេចក្ដីសម្រេច ៖ អនុលោមតាមពាក្យពេចន៍នៅក្នុងបញ្ញត្តិក្រមរដ្ឋប្បវេណី

### ២- ដីកាសម្រេច

- ទម្រង់ដីកាសម្រេច ៖ អនុលោមតាមទម្រង់អប្បបរមានៃមាត្រា ៣៥ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹង

+ លាយលក្ខណ៍អក្សរ
+ សំអាងហេតុ
+ សេចក្ដីសម្រេចបញ្ចប់ និង
+ ហត្ថលេខារបស់ចៅក្រម

- ពាក្យពេចន៍នៃសេចក្ដីសម្រេច ៖ អនុលោមតាមពាក្យពេចន៍នៅក្នុងបញ្ញត្តិក្រមរដ្ឋប្បវេណី។



www.moj.gov.kh/kh/book-library

## ជំពូកទី ២

## ករណីសិក្សា

### ក. ករណីសិក្សាទី ១

ការអះអាងរបស់ A

A និង B បានចាប់ផ្តើមរស់នៅជាមួយគ្នាជាប្តីប្រពន្ធនៅខេត្តកំពង់ធំ ដោយចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៥ ។ B ចាប់ផ្តើមប្រើអំពើហិង្សាលើ A ជារៀងរាល់ថ្ងៃតាំងពីឆ្នាំ ២០១៩ មក។ A ធ្លាប់រងរបួសដោយសារ B វាយធ្វើបាប និងធ្លាប់ចូលពេទ្យផងដែរ។ A បានពិភាក្សាពីរឿងអំពើហិង្សារបស់ B ជាមួយម្តាយ និងមិត្តភក្តិរបស់ខ្លួន ហើយម្តាយ និងមិត្តភក្តិរបស់ខ្លួនក៏ធ្លាប់ស្តីបន្ទោសទៅ B ផងដែរ ប៉ុន្តែ B នៅតែមិនបានបញ្ឈប់ការប្រើអំពើហិង្សានោះទេ។ A ទ្រាំនឹងការប្រើអំពើហិង្សារបស់ B មិនបាន ក៏បានចាកចេញពីផ្ទះដែលធ្លាប់រស់នៅជាមួយ B ហើយទៅរស់នៅម្នាក់ឯងនៅភ្នំពេញ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ ២០២៣ ហើយបច្ចុប្បន្ន A នៅតែរស់នៅភ្នំពេញដដែល។ A ចង់លែងលះជាមួយ B។

ការអះអាងរបស់ B

B មិនធ្លាប់ប្រើអំពើហិង្សាលើ A សូម្បីតែម្តង។ B មិនមានបំណងលែងលះជាមួយ A ទេ។ B ចង់ឱ្យ A ត្រឡប់មករស់នៅកំពង់ធំវិញ។

សំណួរ

១. យោងតាមច្បាប់នីតិវិធី តើ A ត្រូវចាប់ផ្តើមនីតិវិធីបែបណា ប្រសិនបើ A ទាមទារលែងលះ?

២. តើតុលាការណាដែលអាចទទួលស្គាល់ថាជាតុលាការមានសមត្ថកិច្ច ប្រសិនបើ A ទាមទារលែងលះ ?

៣. ឧទាហរណ៍ថា A បានដាក់ពាក្យបណ្តឹងលែងលះនៅថ្ងៃ ១ ខែសីហា ឆ្នាំ ២០២៣ ។

ក. ចូរសរសេរខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ (មាត្រា ៧៥ កថាខណ្ឌទី ២ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ? ចំពោះប្រាក់ប្រដាប់ក្តី ពុំចាំបាច់សរសេរទេ។

ខ. ចូរកំណត់សិទ្ធិទាមទារដែលជាមូលដ្ឋាននៃសាលក្រមដែលដើមចោទទាមទារនៅក្នុងសំណួរ «ក»។

គ. តើអង្គហេតុណា ជា «អង្គហេតុដែលជាមូលហេតុនៃការទាមទារ» (កថាខណ្ឌទី៣ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)?

ឃ. ចូរកំណត់ចំណុចវិវាទ។ (ចូរពិភាក្សាខ្លឹមសារនៃសំណួរក្នុងករណីការអះអាងរបស់ភាគីក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ទាញហេតុផល។)

ង. តើភស្តុតាងអ្វីខ្លះដែលចាំបាច់សម្រាប់ការវិនិច្ឆ័យអំពីចំណុចវិវាទ?



www.moj.gov.kh/kh/book-library

【ឯកសារសម្រាប់រៀនទុកមុន】

សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ៣ (ទំ. ១៩ ដល់ ទំ. ៣៣)

សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្តឹង (ទំ. ៣៤ ដល់ ទំ. ៣៩)

សៀវភៅស្តីពីការពន្យល់អំពីនីតិវិធីនៃការជម្រះក្តីលើកទី១ (ទំ. ១ ដល់ ទំ. ១០)

## ខ. ករណីសិក្សាទី ២

លោក «ក» និង លោកស្រី «ខ» បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាក្នុងឆ្នាំ២០១០ នៅស្រុកកំណើតរបស់លោកស្រី «ខ» នាខេត្តសៀមរាប ហើយក្រោយពីបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅខេត្តសៀមរាបរួចមក អ្នកទាំងពីរបានរស់នៅជាមួយគ្នានៅរាជធានីភ្នំពេញ។ បច្ចុប្បន្នអ្នកទាំងពីរមានកូនចំនួន ២នាក់ ដោយកូនទី១ ឈ្មោះ «គ» ភេទប្រុស អាយុ ៦ឆ្នាំ និងកូនទី២ ឈ្មោះ «ឃ» ភេទស្រី អាយុ ៤ឆ្នាំ ។ សព្វថ្ងៃលោក «ក» រស់នៅខេត្តព្រះសីហនុម្នាក់ឯងដោយសារគាត់ ត្រូវបំពេញការងារនៅទីនោះ។ មូលហេតុ លោក «ក» ត្រូវបំពេញការងារនៅទីនោះជាញឹកញាប់ និងមិនសូវយកចិត្តទុកដាក់លើគ្រួសារ ទើបធ្វើឱ្យលោកស្រី «ខ» មានអារម្មណ៍ថា អស់មនោសញ្ចេតនាជាប្តីប្រពន្ធជាមួយលោក «ក» តទៅទៀត ស្របពេលដែលលោក «ក» និយាយថា ខ្លួនក៏ឈប់ស្រឡាញ់លោកស្រី «ខ» ដែរ ។ ដូចនេះ លោក «ក» និងលោកស្រី «ខ» មានបំណងលែងលះ។ លទ្ធផលនៃការពិភាក្សាគ្នារវាងលោក «ក» និងលោកស្រី «ខ» គឺសម្រេចថា លោកស្រី «ខ» ជាអ្នកមានអំណាចមេបាលើកូនទាំងពីរ។

សំណួរ

សូមផ្តល់មូលហេតុ និងមាត្រាដែលជាមូលដ្ឋាន នៅពេលឆ្លើយសំណួរករណីសិក្សាដូចខាងក្រោម។

១. តើត្រូវមានការទាមទារតាមនីតិវិធីបែបណាខ្លះ ដើម្បីសម្រេចពីការលែងលះរវាងលោក «ក» និង លោកស្រី «ខ»? តើការដាក់ពាក្យនោះ ត្រូវធ្វើដោយរួមគ្នា ឬត្រូវធ្វើឡើងដោយតែភាគីម្ខាង?

២. ឧបមាថា ខុសពីករណីសិក្សាខាងលើ ក្នុងករណីដែលលោក «ក» និង លោកស្រី «ខ» អះអាងថាខ្លួនមានសិទ្ធិអំណាចមេបាលើកូនទាំងសងខាង តើនីតិវិធីដែលត្រូវទាមទារខុសគ្នាពីករណីនៃសំណួរទី ១ឬទេ ? បើខុស តើខុសបែបណា?

៣. ករណីទាមទារតាមនីតិវិធីដូចដែលបានឆ្លើយនៅក្នុងសំណួរទី ១ខាងលើ តើតុលាការណាមានសមត្ថកិច្ច?

៤. បន្ថែមពីលើអង្គហេតុ ដូចមានសរសេរនៅក្នុងករណីសិក្សាខាងលើ ប្រសិនបើលោក «ក» និងលោកស្រី «ខ» មានវិវាទអំពីរបៀបបែងចែកទ្រព្យសម្បត្តិ តើភាគីត្រូវជ្រើសយកនីតិវិធីមួយណាក្នុងការទាមទារឱ្យតុលាការបែងចែកទ្រព្យសម្បត្តិ?



www.moj.gov.kh/kh/book-library

### គ. ករណីសិក្សាទី ៣

#### ១. ការអះអាងរបស់លោក «ក» (ប្តី) ៖

«ក» បានរៀបការជាមួយ «ខ» និងបានចុះបញ្ជីអាពាហ៍ពិពាហ៍ នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៥ ហើយបានចាប់ផ្តើមជីវភាពជាប្តីប្រពន្ធ ដោយរស់នៅជាមួយនឹងឪពុកម្តាយរបស់ «ខ» នៅស្រុកកំណើតរបស់ «ខ»។ នៅខែកក្កដា ឆ្នាំ២០១៧ «ក» និង «ខ» មានកូន «គ១» ហើយនៅខែកញ្ញា ឆ្នាំ២០១៩ «ក» និង «ខ» មានកូន «គ២» ។ ក្នុងអំឡុងពេលនោះ «ក» និង «ខ» បានរស់នៅចុះសម្រុងគ្នាតែមួយរយៈក្រោយមក «ក» និង «ខ» ចាប់ផ្តើមមានទំនាស់ពាក្យសំដីជាមួយគ្នាច្រើនទៅៗ។ បន្ថែមពីនេះទៀត ឪពុកម្តាយរបស់ «ខ» តែងតែនិយាយគំហកទៅ «ក» ជារៀងរាល់ថ្ងៃថា «អញមិនចង់ឃើញមុខឯងទៀតទេ ចេញពីផ្ទះរបស់អញភ្លាមទៅ»។ «ក» ធ្លាប់មានទំនាស់ពាក្យសំដីជាមួយម្តាយរបស់ «ខ» ហើយក៏ធ្លាប់ត្រូវបានម្តាយរបស់ «ខ» វាយ ២ ទៅ៣ ដងផងដែរ។ «ខ» បានដឹងពីទង្វើបែបនោះរបស់ឪពុកម្តាយខ្លួនដែរ ប៉ុន្តែ «ខ» មិនដែលឃាត់ឪពុកម្តាយខ្លួនទេ ហើយក៏មិនដែលកាន់ជើង «ក» ដែរ។

ទីបំផុតនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយទ្រាំតទៅទៀតមិនបាន «ក» បានចាកចេញពីស្រុកកំណើតរបស់ «ខ» ទៅជួលខុនដូរដើម្បីស្នាក់នៅ។ ក្រោយពីបានរស់នៅបែកគ្នានៅពេលបើកមើលប្រព័ន្ធបណ្តាញសង្គម (SNS) របស់ «ខ» ឃើញគាត់បង្ហោះថា «ឯងក្រឡុកគ្រួសារអញសម្បើមដែរណាស់ អញមិនលើកលែងឱ្យឯងជាដាច់ខាត កុំចង់លេងជាមួយភ្លើង» ដែលគំរាមកំហែងធ្វើឱ្យ «ក»មានភាពភិតភ័យ។ ម្យ៉ាងទៀត នៅអំឡុងពេលដើមខែធ្នូ ឆ្នាំ២០២១ នៅពេល «ក» ទៅយកអីវ៉ាន់នៅផ្ទះដែល «ខ» កំពុងរស់នៅ ក៏បានឃើញ «ខ» ក្នុងផ្ទះកាន់កាំបិត ហើយដើរមកកាន់ «ក» រួចនិយាយថា «អញនឹងសម្លាប់ឯងហើយ ចាំអញងាប់តាមក្រោយ»។ នៅពេលឃើញស្ថានភាពបែបនេះ «ក» ក៏រត់ចេញភ្លាម។ ក្រោយមកទៀត «ខ» បានតេទូរស័ព្ទទៅ «ក» ជាច្រើនលើកច្រើនសា នៅពេល «ក» លើកទូរស័ព្ទ «ខ» ក៏និយាយថា «អញមិនលើកលែងឱ្យឯងទេ ។ អញនឹងសម្លាប់ឯងហើយ ចាំអញងាប់តាមក្រោយ»។ «ក» មិនហ៊ានត្រឡប់ទៅស្រុកកំណើតរបស់ «ខ» វិញឡើយ ដោយសារមានភាពភ័យខ្លាច ហេតុនេះ «ក» បានរស់នៅបែកគ្នាជាមួយ «ខ» អស់រយៈពេល៣ខែ ដែលជាហេតុនាំឱ្យ «ក» ចង់លែងលះជាមួយ «ខ»។ «ខ» ធ្លាប់បាននិយាយថា «ក» បានប្រព្រឹត្តអំពើផិត ប៉ុន្តែ «ក» ពុំបានប្រព្រឹត្តអំពើផិតឡើយ។ តាំងពីរស់នៅបែកគ្នា «ក» បានបង់ថ្លៃជីវភាពរស់នៅទៅឱ្យ «ខ» ហើយស្ថានភាពសុខភាពរបស់ «ខ» ក៏មិនមានបញ្ហាអ្វីដែរ ហេតុនេះ ច្បាស់ជាអាចចិញ្ចឹមមើលថែ «គ១» និង «គ២» បាន ។

#### ២. ការអះអាងរបស់ «ខ» (ប្រពន្ធ) ៖

«ខ» មិនមានបំណងលែងលះជាមួយ «ក» ទេ។ ជាការពិតដែល «ក» និង «ខ» មានការឈ្លោះប្រកែកគ្នាច្រើនតាំងពីពេល «គ២» កើតមក ហើយបានរស់នៅបែកគ្នាតាំងពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ មកម្ល៉េះ។ មូលហេតុនោះគឺ «ក» បានប្រព្រឹត្តអំពើផិតជាមួយ «ឃ» ហើយដើម្បីរស់នៅជាមួយ «ឃ»។ «ក» បានចាកចេញពីផ្ទះដោយទុកកូន «គ១» និង «គ២» ចោល ។ ឪពុកម្តាយរបស់ «ខ» មិនដែលនិយាយគំហកទៅ «ក» ថា «អញមិនចង់ឃើញមុខឯងទៀតទេ ចេញពីផ្ទះរបស់អញភ្លាមទៅ» ហើយម្តាយរបស់ «ខ» ក៏មិនធ្លាប់វាយ «ក» ទេ។ ម្យ៉ាងទៀត «ខ» ក៏មិនដែល



www.moj.gov.kh/kh/book-library

និយាយគំរាម «ក» ដែរ។ «ខ» មិនធ្លាប់កាន់កាំបិត ហើយនិយាយថា សម្លាប់ «ក» ទេ ហើយក៏មិនធ្លាប់ទូរស័ព្ទនិយាយរឿងនោះដែរ។ «ខ» នៅតែស្រឡាញ់ «ក» ហើយបើ «ក» ត្រឡប់មកវិញ ប្រាកដជាអាចរស់នៅចុះសម្រុងជាមួយគ្នាតទៀត។

«ក» មិនដែលត្រឡប់មកផ្ទះវិញសោះ ហើយក៏មិនដែលផ្ញើថ្លៃជីវភាពមកដែរ។ បន្ថែមពីនេះទៀត «ខ» មានជំងឺធ្ងន់ រួមទាំងត្រូវមើលថែ «គ១» និង «គ២» ហេតុនេះ «ខ» មិនអាចចេញទៅក្រៅធ្វើការបានទេ។ មកដល់ពេលនេះ ជីវភាពរបស់ «ខ» ពឹងទៅលើលុយដែលសន្សំបានមុនពេលរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែលុយសន្សំមិនអាចទ្រទ្រង់ជីវភាពបានទៀតឡើយ។ «ខ» ចាំបាច់ត្រូវទៅទទួលការព្យាបាលនៅមន្ទីរពេទ្យរាល់សប្តាហ៍ ប៉ុន្តែ ដោយសារលុយសម្រាប់ព្យាបាលទាំងនោះបានចំណាយអស់ហើយ ហេតុនេះ ប្រសិនបើលែងលះបែបនេះ «ខ» មិនអាចទទួលការព្យាបាលទៀតបានឡើយ។ ម្យ៉ាងទៀត «គ១» ពិការរាងកាយ ចាប់តាំងពីកើតមក ហើយចាំបាច់ត្រូវមានការមើលថែក្នុងជីវភាពប្រចាំថ្ងៃ។ ឪពុកម្តាយរបស់ «ខ» មានវ័យចំណាស់ មិនអាចរកប្រាក់ចំណូលបាន ហើយក៏មិនអាចជួយមើលថែកូនបានដែរ។ ការមើលថែកូន «គ១» និង «គ២» ម្នាក់ឯងពិតជាមានភាពពិបាកជាខ្លាំង មិនអាចទ្រាំទ្របាន ហេតុនេះ «ខ» សុំឱ្យ «ក» វិលត្រឡប់មកផ្ទះវិញ។

សំណួរ

«ក» បានដាក់ពាក្យបណ្តឹងលែងលះ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២។

១. សូមកំណត់សិទ្ធិទាមទារដែលជាមូលដ្ឋាននៃការទាមទាររបស់ «ក»។

២. សូមសរសេរអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ(ចំណុច ខ កថាខណ្ឌទី២ មាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ (ម. ៧៥ ក. ៣ នៃក.ន.ណ.)។

៣. សន្មតថាអ្នកជាចៅក្រមទទួលបន្ទុករឿងក្តីនេះ។

ចូរពិចារណា «ខ» នឹងអះអាងដូចម្តេចចំពោះការទាមទាររបស់ «ក» រួចសរសេរអង្គហេតុតវ៉ា (ម. ១០១ ក.៣ នៃ ក.ន.ណ. ដោយពុំចាំបាច់សរសេរអំពីការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់ ឬមិនទទួលស្គាល់ នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹងទេ)។

ចូរពន្យល់អំពីមូលហេតុនៃការលើកឡើងអង្គហេតុតវ៉ានោះ។

៤. សន្មតថា ការអះអាងរបស់ «ក» និង «ខ» ខាងលើ រក្សាដដែលនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ សូមកំណត់ចំណុចវិវាទផ្អែកលើករណីសន្មតនោះ។

### ឃ. ករណីសិក្សាទី ៤ (ការបែងចែកទ្រព្យសម្បត្តិ)

ការអះអាងរបស់ X (ប្តី) ៖

X និង Y បានចុះបញ្ជីអាពាហ៍ពិពាហ៍នៅខែឧសភា ឆ្នាំ២០១៨ ហើយបានចាប់ផ្តើមជីវភាពជាប្តីប្រពន្ធ ដោយរស់នៅខេត្តបាត់ដំបង ដែលជាស្រុកកំណើតរបស់ Y។ នៅឆ្នាំ២០១៩ ពួកយើងមានកូន Z ម្នាក់។ ប៉ុន្តែ X និង Y មាន



www.moj.gov.kh/kh/book-library

ទំនាក់ទំនងមិនល្អជាមួយគ្នាពីមួយថ្ងៃទៅមួយថ្ងៃ រហូតឈានដល់លែងលះគ្នា តាមរយៈសេចក្តីសម្រេចលែងលះ ដែលចូលជាស្ថាពរនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ដោយកំណត់យក Y ជាអ្នកមានអំណាចមេបាលើ Z។ នៅក្រោយពេលលែងលះ អ្នកទាំងពីររស់នៅផ្សេងគ្នា ដោយ Y បន្តរស់នៅក្នុងផ្ទះនៅស្រុកកំណើតនោះដដែល ចំណែកឯ X រស់នៅផ្ទះផ្សេងនៅក្នុងខេត្តបាត់ដំបងដូចគ្នា។ នៅពេលលែងលះ ពួកយើងពិភាក្សាគ្នាពុំបានសម្រេចអំពីរឿងទ្រព្យសម្បត្តិទេ ហេតុនេះ ពួកយើងសុំឱ្យតុលាការសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិ។

- នៅក្រោយពេលចុះបញ្ជីអាពាហ៍ពិពាហ៍ជាមួយនឹង Y X បានបើកគណនីប្រាក់សន្សំក្នុងធនាគារ A ដោយដាក់ឈ្មោះរបស់ X និងបានប្រើប្រាស់គណនីនោះ។ នៅកាលបរិច្ឆេទនៃសេចក្តីសម្រេចអំពីការលែងលះបានចូលជាស្ថាពរ ក្នុងគណនីនេះសល់ប្រាក់ចំនួន ៣.០០០ ដុល្លារអាម៉េរិកជាង។ ប៉ុន្តែ ① ក្រោយពេលលែងលះ X បានបិទគណនីប្រាក់សន្សំក្នុងធនាគារ A និងបានចាយប្រាក់អស់ទៅហើយ។ ឥឡូវប្រាក់នោះមិនមាននៅសល់ទេ ហេតុនេះ សុំឱ្យ Y ឈប់ទាមទារ ព្រោះមិនអាចបែងចែកប្រាក់នោះទេ។
- ក្រោយពេល Y រៀបអាពាហ៍ពិពាហ៍ X និង Y បានចាប់ផ្តើមបើកហាងលក់គ្រឿងសង្ហារិម។ ដោយសារ X ធ្វើការនៅក្នុងក្រុមហ៊ុនទេសចរណ៍ ដូចនេះ មិនអាចធ្វើការងារក្នុងហាងលក់គ្រឿងសង្ហារិមបានទេ ប៉ុន្តែ ② ផលិតផល B នៅក្នុងហាងគ្រឿងសង្ហារិម ជារបស់ X និង Y។ ផលិតផល B មានតម្លៃស្មើនឹង ២០.០០០ ( ពីរម៉ឺន ) ដុល្លារអាម៉េរិក។
- រថយន្ត C ដែល Y កំពុងប្រើប្រាស់ (ដែលបានកត់ត្រា នៅក្នុងចំណុចទី ២ នៃ "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ) ជារថយន្តដែលបានទិញកាលពីខែសីហា ឆ្នាំ២០១៨ ។ ③ រថយន្តនេះ បានចុះបញ្ជីក្រោមឈ្មោះរបស់ Y ប៉ុន្តែរថយន្តនេះ គឺ X បានទិញដោយប្រើប្រាក់ដែលខ្លួនបានសន្សំមុនពេលរៀបអាពាហ៍ពិពាហ៍ ហេតុនេះ វាជាទ្រព្យដោយឡែករបស់ X។
- នៅខែតុលា ឆ្នាំ២០១៨ X និង Y បានទិញដី L នៅខេត្តបាត់ដំបង (ដែលបានកត់ត្រា នៅក្នុងចំណុចទី ៣ នៃ "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ) និងបានចុះបញ្ជីជាទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ហើយបានសង់ផ្ទះលើដីនោះ។ ចំណាយលើថ្លៃទិញដី L និងសោហ៊ុយសាងសង់ផ្ទះសរុបអស់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាម៉េរិក។ ដោយសារសោហ៊ុយចំណាយនេះ X និង Y បានខ្ចីលុយពីធនាគារ D ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាម៉េរិក ដោយប្រើឈ្មោះ X និង Y រួមគ្នា និងបានបង្កើតហ៊ីប៉ូតែកលើដី L ហើយបានសងជាបន្តបន្ទាប់។ បំណុលដែលមាននៅធនាគារ D នៅសល់ ៤៥.០០០ (បួនម៉ឺនប្រាំពាន់) ដុល្លារអាម៉េរិក។ ④ X មិនទាន់បានពិភាក្សាជាមួយធនាគារ D ទេ ប៉ុន្តែ X គ្មានបំណងសងរួមគ្នាជាមួយ Y ទៀតទេ ហេតុនេះ សុំឱ្យបែងចែកបំណុល ដែលនៅសល់ជាមួយ Y ម្នាក់ពាក់កណ្តាល។
- កន្លងមក X ជាអ្នករកប្រាក់ផ្គត់ផ្គង់ជីវភាពនៅក្នុងផ្ទះច្រើនជាង ហេតុនេះ សុំឱ្យចែកទ្រព្យសម្បត្តិដោយឱ្យ X ជាអ្នកទទួលបានទ្រព្យច្រើនជាង។
- ចំពោះដី L និង ផ្ទះលើដីនោះ X ចង់លក់ និងយកថ្លៃលក់នោះមកបែងចែកគ្នា។



www.moj.gov.kh/kh/book-library

ការអះអាងរបស់ Y ( ប្រពន្ធ ) :

ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ និងការលែងលះរវាង X និង Y គឺដូចអ្វីដែល X បានអះអាង។ ប៉ុន្តែទាក់ទងនឹងទ្រព្យសម្បត្តិ មានចំណុចមួយចំនួន Y ចង់បញ្ជាក់ដូចខាងក្រោម :

- X និយាយថា ប្រាក់សន្សំក្នុងធនាគារ A អស់លើងហើយ ប៉ុន្តែ ① នៅពេលលែងលះ Y មានប្រាក់នៅសល់ប្រហែល ១០.០០០ (មួយម៉ឺន) ដុល្លារអាម៉េរិក ច្បាស់ណាស់ ដូចនេះប្រាក់នោះគួរជាទ្រព្យដែលត្រូវបែងចែក ហើយត្រូវចែកមកខ្ញុំពាក់កណ្ដាល។
- ហាងគ្រឿងសង្ហារិម ជាហាងដែលបើកដោយឪពុកម្ដាយរបស់ Y ហើយ Y គ្រាន់តែជួយលក់គ្រឿងសង្ហារិមនៅក្នុងហាងនោះតែប៉ុណ្ណោះ។ ដោយសារ ហាងនេះ គឺជាហាងដែលគ្រប់គ្រងដោយឪពុកម្ដាយរបស់ Y ដូចនេះ ② ផលិតផល B គឺជាទ្រព្យរបស់ឪពុកម្ដាយ Y។
- រថយន្ត C ទិញនៅខែសីហា ឆ្នាំ២០១៨ ③ ជារថយន្តដែលបានទិញដោយប្រើប្រាក់រកបានក្រោយអាពាហ៍ពិពាហ៍រវាង X និង Y ហេតុនេះ វាមិនមែនជាទ្រព្យដោយឡែករបស់ X ទេ។
- ④ បំណុលដែលសល់នៅធនាគារ D ចំនួន ៤៥.០០០ (បួនម៉ឺនប្រាំពាន់) ដុល្លារអាម៉េរិក សុំឱ្យបែងចែកជាពីរស្មើគ្នារវាង X និង Y។
- ដោយសារ Y ត្រូវទទួលបន្ទុកចិញ្ចឹមកូន Z ហេតុនេះ សុំឱ្យបែងចែកឱ្យ Y ជាអ្នកទទួលបានទ្រព្យច្រើនជាង។
- ដី L និង ផ្ទះលើដីនោះ ចង់ឱ្យទៅកូន Z។

| | |
|---|---|
| បញ្ជីទ្រព្យសម្បត្តិរួម : | |
| ១ | ប្រាក់សន្សំ |
| | ធនាគារឈ្មោះ ……………………………… សាខា ……………………….. |
| | លេខគណនី ………………………….… ប្រភេទគណនី ……………….. |
| ២ | រថយន្ត |
| | ប្រភេទ ……………………………. |
| | ម៉ាក ……………………………. |
| | ពណ៌ ……………………………. |
| | កម្មសិទ្ធិករ ……………………………. |
| | អាសយដ្ឋាន ……………………………. |
| | ផ្លាកលេខ ……………………………. |
| ៣ | ដី |
| | ប្រភេទ ……………………………. |
| | លេខក្បាលដី ……………………………. |



www.moj.gov.kh/kh/book-library

សំណួរ

1. X មានបំណងចង់ឱ្យតុលាការបែងចែកទ្រព្យសម្បត្តិរបស់ខ្លួន និង Y។ តើ X ត្រូវធ្វើយ៉ាងដូចម្តេច ឬជ្រើសរើសនីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិមួយណា ទើបអាចឱ្យតុលាការដែលមានសមត្ថកិច្ច ធ្វើការបែងចែកទ្រព្យសម្បត្តិទាំងនោះបាន?
2. ក្នុងករណីមានការអះអាងអំពី ការអះអាង ① របស់ X និង ការអះអាង ① របស់ Y ទាក់ទងនឹងប្រាក់សន្សំនៅធនាគារ A តើអង្គហេតុដែល X បានបិទគណនីប្រាក់សន្សំក្នុងធនាគារ A និងប្រើប្រាស់ប្រាក់សន្សំអស់ក្រោយពេលលែងលះ អាចនាំឱ្យជះឥទ្ធិពលបែបណា ដល់ការបែងចែកទ្រព្យសម្បត្តិ? (មានន័យថា នៅពេលពិចារណាអំពីការបែងចែកទ្រព្យសម្បត្តិ តើតុលាការចាំបាច់គិតអំពីអង្គហេតុនេះដែរឬទេ? ប្រសិនបើចាំបាច់ តើតុលាការគប្បីពិចារណាដូចម្តេច?) សូមឆ្លើយដោយពិចារណាលើចំណុចថាតើការអះអាងរបស់ X និង Y ផ្ទុយគ្នាត្រង់ចំណុចណា។
3. ចូរសន្មតថា អ្នកជាចៅក្រមដែលធ្វើការពិចារណាអំពីការបែងចែកទ្រព្យសម្បត្តិ នៅពេលពិចារណាអំពីការបែងចែកទ្រព្យសម្បត្តិទាក់ទងនឹងផលិតផល B តើការអះអាង② របស់ X និង ការអះអាង② របស់ Y ទាក់ទងនឹងផលិតផល B នៅក្នុងហាងលក់គ្រឿងសង្ហារិម ជាការអះអាងដែលមានអត្ថន័យតាមផ្លូវច្បាប់ដូចម្តេច? ចូរឆ្លើយអំពីអត្ថន័យនៃការអះអាងរបស់ X និងការអះអាងរបស់ Y នីមួយៗ ដោយចង្អុលបង្ហាញពីមាត្រាពាក់ព័ន្ធ។
4. ចូរសន្មតថា អ្នកជាចៅក្រមដែលធ្វើការពិចារណាអំពីការបែងចែកទ្រព្យសម្បត្តិ នៅពេលពិចារណាអំពីការបែងចែកទ្រព្យសម្បត្តិទាក់ទងនឹងរថយន្ត C តើការអះអាង ③ របស់ X និង ការអះអាង ③ របស់ Y ទាក់ទងនឹងរថយន្ត C ជាការអះអាងដែលមានអត្ថន័យតាមផ្លូវច្បាប់ដូចម្តេច? ពាក់ព័ន្ធនឹងការអះអាងអំពីរថយន្ត C ថាជាទ្រព្យសម្បត្តិដោយឡែក ឬ យ៉ាងណានោះ តើរវាង X និង Y អ្នកណាគឺជាអ្នកមានទំនួលខុសត្រូវក្នុងការបញ្ជាក់ ពាក់ព័ន្ធនឹងការអះអាងនោះ? ហើយ តើភាគីដែលមានបន្ទុកទទួលខុសត្រូវក្នុងការបញ្ជាក់នោះ អាចបង្ហាញភស្តុតាងបែបណាខ្លះដើម្បីបញ្ជាក់ភស្តុតាងលើអង្គហេតុទាក់ទងនឹងការអះអាងនេះ?
5. ចូរសន្មតថា អ្នកគឺជាចៅក្រមដែលធ្វើការពិចារណាអំពីការបែងចែកទ្រព្យសម្បត្តិ ប្រសិនបើ X និង Y បានអះអាងដូចនៅក្នុងការអះអាង ④ របស់ X និង ការអះអាង ④ របស់ Y តើបំណុលចំពោះធនាគារ D គប្បីក្លាយជាកម្មវត្ថុនៃការបែងចែកដែរឬទេ? ចូរឆ្លើយដោយចង្អុលបង្ហាញពីមាត្រាពាក់ព័ន្ធ។
6. នៅក្នុងការសម្រេចសេចក្តី X និង Y បានអះអាងដូចអ្វីដែលមានសរសេរនៅក្នុងករណីសិក្សា ហើយតាមលទ្ធផលនៃការពិនិត្យភស្តុតាងផ្សេងៗ និង ការជំនុំជម្រះរួចមក តុលាការបានពិចារណាដូចខាងក្រោម។ ចូរពិចារណាអំពីសេចក្តីសម្រេចបញ្ចប់នៃសេចក្តីសម្រេចដ៏សមស្របមួយ នៅក្នុងករណីនេះ។ (លើកលែងតែសេចក្តីសម្រេចដែលទាក់ទងនឹងបន្ទុកសោហ៊ុយសម្រាប់នីតិវិធី។)



www.moj.gov.kh/kh/book-library

【ការពិចារណារបស់តុលាការ】 ចំណុចនេះពាក់ព័ន្ធតែសំណួរទី ៦ ប៉ុណ្ណោះ។

A. យោងតាមលទ្ធផលនៃការពិនិត្យភស្តុតាង ចំពោះប្រាក់សន្សំនៅធនាគារ A ដែលដាក់ឈ្មោះរបស់ X តុលាការបានទទួលស្គាល់អង្គហេតុដូចតទៅ : ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹង Y រួច X បានបើកគណនីប្រាក់សន្សំនៅធនាគារ A ដោយដាក់ឈ្មោះរបស់ X និងបានប្រើប្រាស់គណនីនោះ។ នៅពេលដែលការលែងលះរបស់ X និង Y បានចូលជាស្ថាពរ គណនីនោះ មានប្រាក់សរុប ចំនួន ៥.០០០ ដុល្លារអាម៉េរិក។ ប៉ុន្តែ ក្រោយពេលលែងលះ X បានបិទគណនីនោះចោល រួចដកប្រាក់ចេញវិញទាំងអស់ ដូចនេះ ប្រាក់នោះត្រូវបានចាយអស់ហើយ បច្ចុប្បន្ននេះ ពុំមានប្រាក់សន្សំនោះនៅធនាគារទៀតឡើយ។

B. តាមលទ្ធផលនៃការពិនិត្យភស្តុតាង បានទទួលស្គាល់ថា ផលិតផល B នៅក្នុងហាងលក់គ្រឿងសង្ហារិម គឺជាកម្មសិទ្ធិរបស់ឪពុកម្តាយរបស់ Y។

C. ទោះជាបានពិនិត្យភស្តុតាងគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏នៅតែមិនអាចបញ្ជាក់ច្បាស់ថា តើរថយន្ត C គឺជារថយន្តដែល X ទិញដោយប្រើលុយសន្សំផ្ទាល់ខ្លួនមុនរៀបអាពាហ៍ពិពាហ៍ ឬក៏ជារថយន្តទិញដោយប្រើលុយដែលខិតខំរកជាមួយនឹង Y ក្រោយពេលរៀបអាពាហ៍ពិពាហ៍ឡើយ។ បច្ចុប្បន្ន រថយន្តC ត្រូវបានវាយតម្លៃថា មានតម្លៃស្មើនឹង ១០.០០០ ដុល្លារអាម៉េរិក។

D. បច្ចុប្បន្ន ដី L និងផ្ទះលើដីនោះ ជារបស់ដែល X និង Y ទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ បច្ចុប្បន្នត្រូវបានវាយតម្លៃថា មានតម្លៃស្មើនឹង ៦០.០០០ ដុល្លារអាម៉េរិក។

E. ចំណែកនៃការបែងចែកទ្រព្យសម្បត្តិ គប្បីម្នាក់ៗ ទទួលបានចំណែកស្មើនឹង ១ភាគ២។

F. - ដោយសារ Y កំពុងប្រើប្រាស់រថយន្ត C គប្បីឱ្យ Y ទទួលបានរថយន្ត C។
- ដោយសារតែ ដី L និង ផ្ទះលើដីនោះ នៅជាប់បន្ទុកហ៊ីប៉ូតែក ដូចនេះ ពុំគប្បីចាត់ចែងលក់ រួចបែងចែកថ្លៃលក់នោះឡើយ ប៉ុន្តែ គប្បីបែងចែកតាមវិធីបំប្លែងវត្ថុនោះទៅជាវត្ថុកម្មសិទ្ធិអវិភាគ ដោយឱ្យ X និង Y ក្លាយជាម្ចាស់កម្មសិទ្ធិអវិភាគ។ គប្បីឱ្យ X និង Y ទទួលបានកម្មសិទ្ធិអវិភាគលើដី L និងផ្ទះលើដីនោះ ដោយចំណែក១ភាគ២ ក្នុងម្នាក់។

G. ក្រោយពីបានពិចារណាលើចំណុចទាំងនេះរួច គប្បីសម្រួល តាមរយៈការឱ្យបង់ប្រាក់។

【ឯកសារយោងសម្រាប់រៀនទុកមុន】

ទម្រង់គំរូក្នុងរឿងក្តីលែងលះ និង ឯកសារពាក់ព័ន្ធនៃទម្រង់គំរូ "របៀបចាត់ចែងរឿងក្តីលែងលះ" ៤-(៥)។



www.moj.gov.kh/kh/book-library

## ជំពូកទី ៣

## សំណួរស្រាវជ្រាវ

### ក. ប្រភេទ លក្ខខណ្ឌ និងនីតិវិធីនៃការលែងលះ

១. តើនីតិវិធីនៃការលែងលះមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់ និងប្រៀបធៀបលក្ខខណ្ឌ និងអានុភាពនៃការលែងលះនីមួយៗ។

២. ផ្អែកតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា តើមូលហេតុនៃការលែងលះមានអ្វីខ្លះ? ចូរពន្យល់ដោយលើកឧទាហរណ៍អំពីមូលហេតុនៃការលែងលះនីមួយៗ។

៣. ទោះបីជាមានមូលហេតុលែងលះក្នុងមាត្រា ៩៧៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីក៏ដោយ តើតុលាការអាចច្រានចោលការទាមទារលែងលះរបស់ដើមចោទបានដែរ ឬទេ? ប្រសិនបើអាចច្រានចោលការទាមទារលែងលះបាន ចូរពន្យល់ឱ្យបានក្បោះក្បាយ ដោយលើកមូលដ្ឋានច្បាប់ និងឧទាហរណ៍។ នៅពេលលើកឡើងពីគោលគំនិតនៃមាត្រាដែលយកមកធ្វើជាមូលដ្ឋាននោះ ចូរពន្យល់ដោយពិចារណាពីទំនាក់ទំនងនៃមាត្រានោះ ទៅនឹងមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

៤. តើការលែងលះដោយការព្រមព្រៀង ចាំបាច់ត្រូវមានមូលហេតុដូចចែងក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីដែរ ឬទេ? ក្រោយពីពិចារណាលើចំណុចនេះ ចូរពន្យល់អំពីលក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង។

៥. ចូរពន្យល់អំពីសមត្ថកិច្ចតុលាការនៅក្នុងរឿងក្តីលែងលះ និងបទប្បញ្ញត្តិមាត្រាដែលត្រូវយកមកអនុវត្ត។

៦. ចូរឆ្លើយសំណួរខាងក្រោម ដោយពិចារណាអំពីគោលគំនិតនៃការលើកលែងការអនុវត្ត ផ្នែកទាក់ទងនឹងអង្គហេតុដែលភាគីបានសារភាពចំពោះមុខតុលាការ ដែលមានចែងក្នុងមាត្រា ៩៦ និងមាត្រា ១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (ម. ១៣ ក. ១ នៃច.ន.ឋ.)។

*A បានដាក់ពាក្យបណ្តឹងទាមទារលែងលះពី B ដែលមានទំនាក់ទំនងអាពាហ៍ពិពាហ៍នឹងគ្នា ដោយយកមូលហេតុថា ខ្លួនបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំហើយ ។ B បាននិយាយថា "ខ្ញុំកំពុងរស់នៅបែកគ្នាជាមួយនឹង A អស់រយៈពេលជាង១ឆ្នាំមកហើយ" ។ ប៉ុន្តែ ផ្អែកតាមលទ្ធផលនៃការសាកសួរសាក្សី C ដែលជាកូនរបស់ A និង B តុលាការបានដឹងថា ការពិត A និង B មិនបានរស់នៅបែកគ្នាទេ។ តើតុលាការគប្បីទទួលស្គាល់អង្គហេតុដែលភាគីលើកឡើងនោះ និងចេញសាលក្រមទទួលស្គាល់ការលែងលះដែរ ឬទេ ប្រសិនបើ A និង B និយាយថា "កំពុងរស់នៅបែកគ្នាអស់រយៈពេលជាង ១ឆ្នាំ" ?*

៧. នៅក្នុងនីតិវិធីនៃបណ្តឹងលែងលះ តើតុលាការអាចធ្វើការផ្សះផ្សា តាមមាត្រា ២២០ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានដែរ ឬទេ? ចូរពន្យល់ដោយពិចារណាអំពីអត្ថន័យនៃពាក្យ "ផ្សះផ្សា" ក្នុងមាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណី។ នៅក្នុងនីតិវិធីនៃបណ្តឹងលែងលះ ប្តីប្រពន្ធបានយល់ព្រមសះជាគ្នា ដោយព្រមព្រៀងឈប់លែងលះ និងរួមរស់នៅជាមួយគ្នាវិញ តើតុលាការត្រូវធ្វើដូចម្តេច? ចូរពន្យល់ ។

៨. នៅក្នុងបណ្តឹងលែងលះ តើតុលាការគប្បីចាត់ការដូចម្តេច ចំពោះករណីនីមួយៗ ដូចខាងក្រោម ? ចូរពន្យល់ពីមូលហេតុនៃចំណាត់ការនោះ ដោយលើកយកមាត្រាដែលជាមូលដ្ឋាន និងគោលគំនិតនៃមាត្រានោះ រួចធ្វើការប្រៀបធៀបនឹងករណីបណ្តឹងទាមទារឱ្យសងប្រាក់កម្ចី។ សន្មតថាភាគីបានទទួលការកោះហៅក្នុងកាលបរិច្ឆេទនីមួយៗ។

(១). ករណីចុងចម្លើយ ពុំបានបង្ហាញខ្លួន នៅក្នុងកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។

(២). ករណីភាគីទាំងសងខាង ពុំបានបង្ហាញខ្លួននៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។



www.moj.gov.kh/kh/book-library

៩. តើភាគីដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ អាចដាក់ពាក្យសុំលែងលះដោយការព្រមព្រៀងបានដែរឬទេ? ក្នុងករណីភាគីដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍បានដាក់ពាក្យសុំលែងលះ មកតុលាការ តើតុលាការគប្បីធ្វើដូចម្ដេច?

១០. ចូរតាក់តែងពាក្យពេចន៍នៃសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ដែលទទួលស្គាល់ការទាមទារលែងលះ ក្នុងករណីដែល X បានទាមទារលែងលះតាមផ្លូវបណ្ដឹង ដោយយកសហព័ទ្ធ Y ធ្វើជាចុងចម្លើយ (សរសេរត្រឹមខ្លឹមសារពាក់ព័ន្ធនឹងការលែងលះតែប៉ុណ្ណោះ)។ បន្ទាប់មក ចូរពន្យល់ពីអានុភាពនៃសាលក្រមទទួលស្គាល់ការទាមទារលែងលះ ថាតើសាលក្រមនេះមានអានុភាពយ៉ាងដូចម្ដេច? ចំពោះនរណាខ្លះ?

១១. ចូរតាក់តែងពាក្យពេចន៍នៃសេចក្ដីសម្រេចបញ្ចប់ ទទួលស្គាល់ពាក្យសុំលែងលះដោយការព្រមព្រៀង (សរសេរត្រឹមខ្លឹមសារ ពាក់ព័ន្ធនឹងការលែងលះ តែប៉ុណ្ណោះ)។

១២. X បានទាមទារលែងលះតាមផ្លូវបណ្ដឹង ដោយយកសហព័ទ្ធ Y ធ្វើជាចុងចម្លើយ។ ក្នុងករណីដែលគ្មានពាក្យសុំពី X តើតុលាការអាចសម្រេចសេចក្ដីលើចំណុចខាងក្រោម នៅក្នុងសាលក្រមទទួលស្គាល់ការទាមទារលែងលះរបស់ X ដែរ ឬទេ? ចុះករណីលែងលះដោយការព្រមព្រៀង? ចូរពិចារណាសំណួរនេះ ដោយសន្មតថា X និង Y មិនអាចពិភាក្សាគ្នាលើចំណុចទាំងអស់ខាងក្រោមនេះ :

(១). ការកំណត់អ្នកមានអំណាចមេបា (ម. ១០៣៧ នៃ ក.រ.ណ.)

(២). ការបែងចែកទ្រព្យសម្បត្តិរួម (ម. ៩៨០ នៃ ក.រ.ណ.)

(៣). បន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (ម. ១០៤០ នៃ ក.រ.ណ.)

(៤). របៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន (ម. ១០៤០ នៃ ក.រ.ណ.)

(៥). ខ្លឹមសារ និងរបៀបរបបនៃការរាយការណ៍អំពីស្ថានភាពរបស់កូន (ម. ១០៤១ នៃ ក.រ.ណ.)

១៣. X បានធ្វើការទាមទារលែងលះតាមផ្លូវបណ្ដឹង ដោយយកសហព័ទ្ធ Y ធ្វើជាចុងចម្លើយ។ នៅក្នុងសាលក្រមតុលាការបានទទួលស្គាល់ការទាមទារលែងលះរបស់ X ហើយបានកំណត់អ្នកមានអំណាចមេបាលើកូន ព្រមទាំងកំណត់អំពីការបែងចែកទ្រព្យសម្បត្តិរួម និងបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ស្របទៅតាមពាក្យសុំរបស់ភាគី។ ចុងចម្លើយ Y ពុំយល់ទាស់នឹងការទទួលស្គាល់ការទាមទារលែងលះឡើយ ប៉ុន្តែគាត់មិនពេញចិត្តនឹងការកំណត់អ្នកមានអំណាចមេបា ការបែងចែកទ្រព្យសម្បត្តិរួម និងបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដែលជាការចាត់ចែងបន្ទាប់បន្សំឡើយ ហើយបានប្ដឹងឧទ្ធរណ៍ចំពោះតែសេចក្ដីសម្រេចពាក់ព័ន្ធនឹងការចាត់ចែងបន្ទាប់បន្សំទាំងនេះ។ នៅក្នុងករណីនេះ តើអានុភាពនៃការលែងលះកើតឡើង ដែរឬទេ?

## ខ. អានុភាពនៃការលែងលះ

### ខ.១. ការកំណត់អ្នកមានអំណាចមេបា

១. នៅពេលសម្រេចអំពីការលែងលះរវាងឪពុកម្ដាយ តើតុលាការគប្បីកំណត់អ្នកមានអំណាចមេបាដោយពិចារណាលើស្ថានភាពបែបណាខ្លះ ប្រសិនបើការពិភាក្សារបស់ឪពុកម្ដាយអំពីអ្នកមានអំណាចមេបាលើកូន ពុំអាចសម្រេច? ចូរបកស្រាយដោយលើកឧទាហរណ៍មកពន្យល់។

២. X បានដាក់ពាក្យបណ្ដឹងទាមទារលែងលះ ដោយយកសហព័ទ្ធ Y ធ្វើជាចុងចម្លើយ ហើយតុលាការបានចេញសាលក្រមទទួលស្គាល់ការលែងលះ ដោយកំណត់យក X ធ្វើជាអ្នកមានអំណាចមេបាលើកូន C ដែលជាអនីតិជន (កើតថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០)។ ចូរតាក់តែងពាក្យពេចន៍នៃសេចក្ដីសម្រេចក្នុងករណីនេះ (ដោយពុំចាំបាច់សរសេរពីខ្លឹមសារទាក់ទងនឹងប្រាក់ប្រដាប់ក្ដីឡើយ)។



www.moj.gov.kh/kh/book-library

## ខ.២. ការបែងចែកទ្រព្យសម្បត្តិរួម

១. ចូរពន្យល់អំពីគោលគំនិតនៃប្រព័ន្ធបែងចែកទ្រព្យសម្បត្តិរួម (ម. ៩៨០ នៃ ក.រ.ណ. ចែងថា ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិ ។) ហេតុអ្វី?

២. ចូរពន្យល់អំពីទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ និងទ្រព្យសម្បត្តិដោយឡែក។ តើទ្រព្យសម្បត្តិដោយឡែកមានអ្វីខ្លះ? ចូរបកស្រាយដោយលើកឧទាហរណ៍មកពន្យល់។

៣. នៅពេលពិចារណាអំពីសមាមាត្រនៃការបែងចែកទ្រព្យសម្បត្តិ តើតុលាការអាចពិចារណាលើស្ថានភាពអ្វីខ្លះ? ចូរបកស្រាយដោយលើកឧទាហរណ៍មកពន្យល់។

## ខ.៣. ការកំណត់បន្ទុកនៃសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

១. ក្នុងករណីដែលឪពុកម្តាយលែងលះគ្នា ហើយបានសុំឱ្យតុលាការសម្រេចអំពីបន្ទុកនៃសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដែលជាអនីតិជន ដោយមូលហេតុការពិភាក្សារវាងឪពុកម្តាយពុំបានសម្រេច។ តើតុលាការត្រូវសម្រេចបន្ទុកនៃសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនដែលជាអនីតិជន ដោយពិចារណាលើស្ថានភាពអ្វីខ្លះ? ចូរបកស្រាយដោយលើកឧទាហរណ៍មកពន្យល់ ។

២. X បានដាក់បណ្តឹងទាមទារលែងលះ ដោយយកសហព័ទ្ធ Y ធ្វើជាចុងចម្លើយ ហើយបានដាក់ពាក្យសុំចាត់ចែងបន្ទាប់បន្សំចំពោះបន្ទុកសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន C ដែលជាអនីតិជន (កើតថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១)។ តុលាការទទួលស្គាល់ការទាមទារលែងលះរបស់ X និងកំណត់យក X ជាអ្នកមានអំណាចមេបាលើកូន C ដែលជាអនីតិជន ហើយសម្រេចថា Y ត្រូវបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ក្នុងមួយខែ ចំនួន ២០០ ដុល្លារ ជារៀងរាល់ខែមកឱ្យ X រហូតដល់កូន C ក្លាយជានីតិជន។ ចូរតាក់តែងពាក្យពេចន៍នៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រមនៅក្នុងករណីនេះ (សរសេរត្រឹមខ្លឹមសារ ដែលពាក់ព័ន្ធនឹងបន្ទុកនៃសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនតែប៉ុណ្ណោះ) ។ ម្យ៉ាងទៀត ចូរពន្យល់អំពីមូលហេតុនៃការសរសេរសេចក្តីសម្រេចបែបនោះ ។

## ខ.៤. របៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន

១. ក្នុងករណីឪពុកម្តាយលែងលះគ្នា ហើយសុំឱ្យតុលាការសម្រេចអំពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ដោយមូលហេតុឪពុកម្តាយពិភាក្សាពុំបានសម្រេច។ តើតុលាការត្រូវសម្រេចអំពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ដោយពិចារណាលើស្ថានភាពអ្វីខ្លះ? ចូរបកស្រាយដោយលើកឧទាហរណ៍មកពន្យល់។

២. X បានដាក់បណ្តឹងទាមទារលែងលះ ដោយសហព័ទ្ធ Y ធ្វើជាចុងចម្លើយ ហើយតុលាការបានចេញសាលក្រមទទួលស្គាល់ការលែងលះ ដោយកំណត់យក X ធ្វើជាអ្នកមានអំណាចមេបាលើកូន C។ ប៉ុន្តែ ក្រោយពេលសាលក្រមលែងលះចូលជាស្ថាពរ X មិនឱ្យកូន C ជួប Y ទាល់តែសោះ។ Y បានដាក់ពាក្យសុំឱ្យតុលាការសម្រេចពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន C ។ ជាលទ្ធផលនៃការវិនិច្ឆ័យ គឺតុលាការបានសម្រេចឱ្យ Y ចូលជួបកូន C ចំនួន ១ ដង ក្នុងមួយខែ។ ក្នុងករណីនេះ ប្រសិនបើតុលាការកំណត់នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចដូចខាងក្រោមនេះ តើមានបញ្ហាអ្វីដែរឬទេ? បើមានបញ្ហា តើគប្បីកែសម្រួលលើសេចក្តីសម្រេចបញ្ចប់នេះយ៉ាងដូចម្តេច ដោយពិចារណាលើចំណុចអ្វីខ្លះ?

" X ត្រូវអនុញ្ញាតឱ្យ Y ចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន C របស់ X និង Y " ។



www.moj.gov.kh/kh/book-library

## ជំពូកទី ៤

## ឯកសារគំរូ

### ក. ឯកសារគំរូ (ទម្រង់គំរូ មិនមែនខ្លឹមសារគំរូ)

### ១. គំរូពាក្យបណ្ដឹង[33]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្ដឹង

**ដើមចោទ**

ឈ្មោះ : X

អាសយដ្ឋាន : ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ.....ឃុំ.....ស្រុក...... ខេត្តបាត់ដំបង[1]។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី : P

អាសយដ្ឋានការិយាល័យ : ......................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី : ..........................................

លេខទូរស័ព្ទ : ..........................................

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុង មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែចំពោះចំណុច ផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើត ជាអាទិ៍ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋាន បានផងដែរ ដូច្នេះ ត្រូវសរសេរ ចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពី ភាគី ។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ប្រសិនបើពុំមានការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូនទេ ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅឋានរបស់ដើមចោទជាអាទិ៍។ ហេតុនេះ នៅក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ដើមចោទ មានបំណងធ្វើការបញ្ជូនទៅកាន់ទីកន្លែងណាផ្សេង ក្រៅពីលំនៅឋានរបស់ដើមចោទ ជាអាទិ៍ គឺមានភាពចាំបាច់ក្នុងការសរសេរអំពីទីកន្លែង ដែលត្រូវបញ្ជូននៅក្នុងលិខិតពាក្យបណ្ដឹង ជាអាទិ៍។

[33]. https://moj.gov.kh/files/user-folder/Justice_Library/Sample-Divorce/5_ពាក្យបណ្ដឹង.pdf



www.moj.gov.kh/kh/book-library

ទីកន្លែងបញ្ជូន : ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី..............................[2]

**ចុងចម្លើយ**

ឈ្មោះ : Y

អាសយដ្ឋាន : ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧ មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងខេត្តបាត់ដំបង** [3]

**ក. ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឱ្យតុលាការចេញ** [4] :

---

[3] ដើមចោទត្រូវតែដាក់ពាក្យបណ្ដឹង ទៅតុលាការដែលមានសមត្ថកិច្ច (មាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ សមត្ថកិច្ចសាលាជម្រះក្ដីត្រូវកំណត់ តាមពេលដាក់ពាក្យបណ្ដឹង (មាត្រា ១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ បណ្ដឹងទាមទារលែងលះគ្នាស្ថិតនៅក្រោម សមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគី (ម. ៩៨២ ក. ១ នៃ ក.រ.ណ. និង ម. ១០ ក. ១ នៃ ក.ន.ណ.)។

នៅក្នុងរឿងក្ដីនេះ លំនៅឋានរបស់ដើមចោទ នៅខេត្តបាត់ដំបង ហើយលំនៅឋានរបស់ចុងចម្លើយនៅរាជធានីភ្នំពេញ ហេតុនេះ ហើយសាលាដំបូងខេត្តបាត់ដំបង និង សាលាដំបូងរាជធានីភ្នំពេញ គឺជាសាលាដំបូងដែលមានសមត្ថកិច្ច។

នៅក្នុងចំណោមសាលាដំបូងខេត្តបាត់ដំបង ឬ សាលាដំបូងរាជធានីភ្នំពេញ ដើមចោទអាចដាក់ពាក្យបណ្ដឹងទៅសាលាដំបូង ណាមួយក៏បាន ប៉ុន្តែនៅក្នុងរឿងក្ដីនេះ លំនៅឋានរបស់ដើមចោទរស់នៅខេត្តបាត់ដំបង ហើយបានចុះបញ្ជីអាពាហ៍ពិពាហ៍ នៅសាលាឃុំ នៅក្នុងខេត្តបាត់ដំបង ជាដើម ហេតុនេះ ដើមចោទបានដាក់ពាក្យបណ្ដឹងទៅសាលាដំបូងខេត្តបាត់ដំបង។

[4] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង (ម. ៧៥ ក. ២ ច. ខ នៃ ក.ន.ណ.)។ ម្យ៉ាងទៀត ប្រសិនបើតុលាការចេញសាលក្រម ឬ សាលដីកាដែលទទួលស្គាល់បណ្ដឹងទាមទារលែងលះ តុលាការ នឹងត្រូវសម្រេចសេចក្ដីអំពីការចាត់ចែងបន្ទាប់បន្សំ (ការកំណត់អ្នកមានអំណាចមេបា ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬ ការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ) ដោយឆន្ទានុសិទ្ធិ ឬ តាមពាក្យសុំ ហេតុដូច្នេះ ដើមចោទគប្បីសរសេរទុកជាមុន អំពីខ្លឹមសារនៃការចាត់ចែងបន្ទាប់បន្សំ ដែលទាមទារឱ្យតុលាការចេញ ទើបជាការប្រសើរ (ម. ២២ ក. ១ នៃ ច.ន.ឋ)។



www.moj.gov.kh/kh/book-library

(១) លែងលះដើមចោទ និងចុងចម្លើយ។ [5]

(២)កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុសរបស់ដើមចោទ និងចុងចម្លើយ ដែលមានឈ្មោះ សុក សុជាតិ (កើតនៅ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦)។ [6]

(៣) កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីរវាងដើមចោទ និងចុងចម្លើយដែលមាន ឈ្មោះ សុក សុជាតា (កើតនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៨)។ [7]

(៤) បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាមេរិកក្នុង ១ខែ ឱ្យទៅ ដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃ ដែលសាលក្រមនេះ ចូលជាស្ថាពរ រហូតដល់ឈ្មោះ សុក សុជាតិ ដែលបានកត់ត្រានៅក្នុងចំណុច (២) ខាងលើនេះ ក្លាយជានីតិជន។ [8]

---

[5] ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្ដឹងលែងលះគ្នា (តាមលក្ខណៈត្រឹមត្រូវ គឺពាក្យសុំលែងលះ) ទៅតុលាការបានក្នុង "ករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា" (ម. ៩៧៩ នៃ ក.រ.ណ.)។ ក្នុងករណីនេះ តុលាការត្រូវសម្រេចសេចក្ដី (ដីកាសម្រេច) ដោយផ្អែកតាមច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (ម. ៣ នៃ ច.ន.ម. តារាង ឧបសម្ព័ន្ធ ផ. ៤ ច. ៥)។ "ករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា" គឺសំដៅទៅលើករណីដែលភាគីសងខាងមានកូនដែលជាអនីតិជន ហើយភាគីសងខាងបានព្រមព្រៀងគ្នាចំពោះការសម្រេចអំពី ①ការលែងលះ និង ②អ្នកមានអំណាចមេបា។ មូលហេតុ គឺដោយសារតែនៅពេលដែលឪពុកម្ដាយលែងលះគ្នា ត្រូវតែកំណត់ឪពុក ឬម្ដាយណាម្ខាងជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្ដាយ (ម. ១០៣៧ ក. ១ នៃ ក.រ.ណ)។ ការលែងលះគ្នា ទាំងមិនបានកំណត់អំពីអ្នកមានអំណាចមេបា មិនត្រូវបានទទួលស្គាល់តាមក្រមរដ្ឋប្បវេណីទេ។ ដូច្នេះ ក្នុងករណីដែលតុលាការចេញដីកាសម្រេចទទួលស្គាល់ការលែងលះដោយផ្អែកតាមពាក្យសុំរបស់ភាគីនៃអាពាហ៍ពិពាហ៍ នៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃដីកាសម្រេច មិនមែនត្រឹមតែឱ្យ ①ភាគីលែងលះគ្នាទេ គឺចាំបាច់ត្រូវតែ ②កំណត់អំពីអ្នកមានអំណាចមេបាផងដែរ។ នៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង គឺមិនបានសរសេរអំពី "ដីកាសម្រេច" អំពីអ្នកមានអំណាចមេបា ដោយយោងតាមបញ្ញត្តិ មាត្រា១០៣៧ កថាខណ្ឌទី៣ គឺដោយសារតែមានការព្យាករណ៍ថា នៅពេលដែលធ្វើការសម្រេចសេចក្ដីអំពី "ពាក្យសុំលែងលះដោយការព្រមព្រៀង ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៧៩ (ការលែងលះដោយការព្រមព្រៀង) (តារាងឧបសម្ព័ន្ធ ផ្នែកទី ៤ ចំណុចទី ៥) គឺចាំបាច់ត្រូវតែសម្រេចអំពីអ្នកមានអំណាចមេបាផងដែរ (មិនអាចដាក់ពាក្យសុំអំពីការសម្រេចអំណាច មេបាដោយឯករាជ្យដាច់តែឯងបានទេ ចាំបាច់ត្រូវឱ្យតុលាការសម្រេចជាមួយគ្នានៅក្នុងពាក្យសុំលែងលះ)។

ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងនៃអាពាហ៍ពិពាហ៍មិនព្រមព្រៀងគ្នាលែងលះ ឬភាគីសងខាងបានព្រមព្រៀងលែងលះគ្នា ប៉ុន្តែមិនបានព្រមព្រៀងគ្នាសម្រេចអំពីអ្នកមានអំណាចមេបាទេ នឹងត្រូវដាក់ពាក្យបណ្ដឹងទាមទារលែងលះ (ម. ៩៧៨ និង ម. ៩៨២ នៃ ក.រ.ណ.)។ ក្នុងករណីទាំងនេះ តុលាការនឹងត្រូវធ្វើការសម្រេចសេចក្ដី (សាលក្រម) ដោយផ្អែកតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល (ម. ១៣ នៃ ច.ន.ឋ.) ដែលជានីតិវិធីមួយខុសគ្នាខ្លាំងទៅនឹងនីតិវិធីរដ្ឋប្បវេណីធម្មតា។ <u>នៅក្នុងករណីដែលតុលាការបានចេញសាលក្រមដោយប្រើប្រាស់នូវបញ្ញត្តនៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមិនអាចយកមកអនុវត្តបាននៅក្នុងនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល សាលក្រមនោះនឹងក្លាយទៅជាសាលក្រមដែលខុសច្បាប់</u> ហេតុដូច្នេះ ត្រូវមានការប្រុងប្រយ័ត្ន ជាពិសេស គឺចៅក្រម។

[6] ប្រសិនបើតុលាការចេញសាលក្រមទទួលស្គាល់បណ្ដឹងទាមទារលែងលះ តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា "ដោយឆន្ទានុសិទ្ធិ" (ម. ២២ ក. ១ នៃ ច.ន.ឋ.)។ ពាក្យថា "ដោយឆន្ទានុសិទ្ធិ" គឺមានន័យថា តុលាការចាំបាច់ត្រូវតែសម្រេចសេចក្ដី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ។ ប្រសិនបើនៅក្នុងពាក្យបណ្ដឹង ដើមចោទមិនបានសរសេរអំពីការកំណត់អ្នកមានអំណាចមេបានៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញក៏ដោយ ក៏តុលាការត្រូវកំណត់អ្នកមានអំណាចមេបាឱ្យទៅដើមចោទ ឬចុងចម្លើយណាម្ខាងដែរ ក្នុងករណីដែលទទួលស្គាល់បណ្ដឹងទាមទារលែងលះ។ ប៉ុន្តែការកំណត់អំណាចមេបានេះ ក៏តុលាការនឹងយកមកយោងនៅពេលដែលសម្រេចថា តើកំណត់អំណាចមេបាឱ្យទៅដើមចោទ ឬចុងចម្លើយណាម្ខាងផងដែរ? (តើដើមចោទមាន ឬគ្មានឆន្ទៈបីបាច់រក្សារូបកាយកូនដែរទេ?) ដូច្នេះហើយ បើសិនជាដើមចោទមានឆន្ទៈ តុលាការក៏អាចសរសេរអំពីឆន្ទៈនោះបានផងដែរ។

[7] ខ្លឹមសារដូចគ្នានឹង Footnote 6។

[8] ឪពុក ឬម្ដាយដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (ម. ១០៤០ ក. ១ នៃ ក.រ.ណ.)។



www.moj.gov.kh/kh/book-library

បើតុលាការចេញសាលក្រមដែលទទួលស្គាល់បណ្តឹងទាមទារលែងលះ ហើយបើមានពាក្យសុំពីភាគី ត្រូវធ្វើការសម្រេចសេចក្តីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន (ម. ២២ ក. ១ នៃ ច.ន.ឋ)។ ក្នុងករណីនេះ នៅក្នុងសាលក្រម តុលាការអាចបង្គាប់ឱ្យភាគីប្រគល់កូន ឬបង់ប្រាក់ឬផ្តល់តាវកាលិកផ្សេងទៀត (ម. ២២ ក. ២ នៃ ច.ន.ឋ.)។

ដើមចោទបានដាក់ពាក្យសុំទាមទារទៅចុងចម្លើយ ដែលមិនបានក្លាយជាអ្នកមានអំណាចមេបាលើកូនតាមរយៈការលែងលះឱ្យបង់ប្រាក់ ដែលជាការទទួលបន្ទុកទៅលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ក្នុងករណីនេះ តុលាការត្រូវតែសម្រេចទៅលើពាក្យសុំនេះ។

(៥) បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិកក្នុង ១ ខែ ឱ្យទៅដើមចោទគិតត្រឹមថ្ងៃចុងក្រោយ ជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ រហូតដល់ឈ្មោះ សុក សុជាតា ដែលបានកត់ត្រានៅក្នុងចំណុច (៣) ខាងលើនេះក្លាយជានីតិជន។[9]

(៦) បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០ (មួយរយ) ដុល្លារអាម៉េរិកក្នុង១ខែ ឱ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយ ជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ដើមចោទរៀបអាពាហ៍ពិពាហ៍ថ្មី។[10]

(៧) បែងចែកទ្រព្យសម្បត្តិនីមួយៗដែលបានកត់ត្រានៅក្នុង"បញ្ជីទ្រព្យសម្បត្តិរួម"[11] នៃឧបសម្ព័ន្ធដូចខាងក្រោមនេះៈ[12]

ក. ដី ដែលកត់ត្រានៅក្នុងចំណុច ១. " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា " ដី L1" ) ជា កម្មសិទ្ធិរបស់កូនប្រុសរវាងដើមចោទ និងចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ។[13] *( *ការទាមទារ នេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ពាក្យបណ្តឹងត្រូវបានកែតម្រូវ ហេតុនេះចំពោះការទាមទារដែលត្រឹមត្រូវ សូមពិនិត្យមើលឯកសារនៃលិខិតនោះ។)*

---

[9] ខ្លឹមសារដូចគ្នា នឹង Footnote 8។

[10] ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន។ ភាគីខាងក្រោយនេះ ត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន។ កម្រិតអាហារកិច្ច ត្រូវសម្រេចទៅតាមការយល់ព្រមរបស់គូភាគីទាំងសងខាង។ ក្នុងករណីដែលគូភាគីទាំងសងខាងមិនឯកភាពគ្នា តុលាការប្រជាជនត្រូវសម្រេចសេចក្តី។ បើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកិច្ចទៀតហើយ (ម. ៧៦ នៃ ច.អ.គ.)។
ដើមចោទ បានទាមទារទៅចុងចម្លើយឱ្យបង់អាហារកិច្ច ដោយផ្អែកតាមមាត្រា ៧៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។

[11] ឧបសម្ព័ន្ធ ជាឯកសារមួយដែលបានបង្កើតដើម្បីដាក់បញ្ចូលព័ត៌មាននោះ ហើយជាផ្នែកតែមួយនៃឯកសារដើម។ ឧបសម្ព័ន្ធ គឺ គ្រាន់តែជាការសរសេរដើម្បីធ្វើការសរុបនូវខ្លឹមសារមួយផ្នែកដាក់នៅក្នុងទំព័រចុងក្រោយ ដោយផ្អែកលើការពិចារណាអំពីភាពងាយស្រួលនៃការអានខ្លឹមសារទាំងស្រុងនៃឯកសារដើម។ ដូច្នេះហើយ ប្រសិនបើ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ" ត្រូវបានដកស្រង់ខ្លឹមសារទៅដាក់នៅក្នុងឧបសម្ព័ន្ធនោះមានន័យថា គេគ្រាន់តែបានយកខ្លឹមសារមួយផ្នែក ដែលមានភាពចាំបាច់ត្រូវសរសេរនៅក្នុង "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ" មកសរសេរសរុបដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះហើយ <u>"ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ" ក៏រួមបញ្ចូលទាំងឧបសម្ព័ន្ធផងដែរ។</u>

[12] ក្នុងការដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង (ម. ៩៨០ ក. ១ នៃ ក.រ.ណ.)។ ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិដោយផ្អែកទៅតាមចំណុចនីមួយៗនៅក្នុងមាត្រា៩៨០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។ បើតុលាការចេញសាលក្រមដែលទទួលស្គាល់បណ្តឹងទាមទារលែងលះ ហើយបើមានពាក្យសុំពីភាគីត្រូវធ្វើការសម្រេចសេចក្តី អំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន (ម. ២២ ក. ១ នៃ ច.ន.ឋ.)។ ក្នុងករណីនេះ នៅក្នុងសាលក្រម តុលាការអាចបង្គាប់ឱ្យភាគីប្រគល់កូន ឬបង់ប្រាក់ ឬផ្តល់តាវកាលិកផ្សេងទៀត (ម. ២២ ក. ២ នៃ ច.ន.ឋ.)។ដើមចោទបានដាក់ពាក្យសុំទាមទារឱ្យបែងចែកទ្រព្យសម្បត្តិរួម។ ក្នុងករណីនេះ តុលាការត្រូវតែសម្រេចសេចក្តីចំពោះពាក្យសុំនេះផងដែរ។

[13] នៅក្នុងការបែងចែកទ្រព្យសម្បត្តិ មិនអាចធ្វើប្រទានកម្មទ្រព្យសម្បត្តិទៅឱ្យតតិយជន ក្រៅពីប្តីប្រពន្ធបានទេ។ ប្រធានដែលទទួល បាននូវទ្រព្យសម្បត្តិគឺ "សហព័ទ្ធនីមួយៗ" ដែលមានចែងនៅក្នុងចំណុចនីមួយៗនៃមាត្រា៩៨០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។ ការណ៍ដែលឱ្យតតិយជនក្រៅពីសហព័ទ្ធនីមួយៗទទួលបាន គឺក្រមរដ្ឋប្បវេណីមិនទទួលស្គាល់នោះទេ។

<u>ការអះអាងនេះ ត្រូវបានកែតម្រូវដោយ "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ហេតុនេះ សូមពិនិត្យមើលទាំង ឯកសារនៃលិខិតនោះផង។</u>



www.moj.gov.kh/kh/book-library

ខ. ដី ដែលកត់ត្រានៅក្នុងចំណុច ២. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L2" ) ជាកម្មសិទ្ធិអវិភាគ រវាងដើមចោទ និងចុងចម្លើយក្នុងចំណែកម្នាក់ៗចំនួន ១ ភាគ ២។ បង្គាប់ឱ្យលក់ដេញថ្លៃលើ "ដី L2" ហើយយក ចំនួនទឹកប្រាក់ ដែលបានដកសោហ៊ុយ សម្រាប់នីតិវិធី ពីថ្លៃលក់នោះមកបែងចែកឱ្យទៅដើមចោទ និងចុងចម្លើយ ក្នុង ម្នាក់ៗ ចំនួន ១ ភាគ ២។

គ. ឡាន ដែលបានកត់ត្រា នៅក្នុងចំណុច ៣. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "រថយន្ត នៃរឿងក្តីនេះ") ជាកម្មសិទ្ធិរបស់ចុងចម្លើយ។ បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាម៉េរិក ឱ្យទៅដើម ចោទ។

ឃ. ម៉ូតូ ដែលបានកត់ត្រា នៅក្នុងចំណុច ៤. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ម៉ូតូនៃរឿង ក្តីនេះ ") ជា កម្មសិទ្ធិរបស់ដើមចោទ។

ង. ប្រាក់សន្សំ ដែលបានកត់ត្រា នៅក្នុងចំណុច ៥. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ប្រាក់សន្សំ នៃ រឿងក្តីនេះ") ជាកម្មសិទ្ធិរបស់ចុងចម្លើយ។ បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ២៥០ (ពីររយហាសិប) ដុល្លារអាម៉េរិក ឱ្យទៅដើមចោទ។

ច. កាតព្វកិច្ច ដែលបានកត់ត្រា នៅក្នុងចំណុច ៦. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធជាបន្ទុករបស់ចុងចម្លើយ។ *( *ការទាមទារនេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ត្រូវបានកែតម្រូវ ហេតុនេះចំពោះការទាមទារដែលត្រឹមត្រូវសូមពិនិត្យមើលឯកសារនៃលិខិតនោះ។)*

ឆ. កាតព្វកិច្ច ដែលបានកត់ត្រា នៅក្នុងចំណុច ៧. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាបន្ទុករបស់ចុងចម្លើយ។ *( * ការទាមទារនេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ត្រូវបានកែតម្រូវ ហេតុ នេះ ចំពោះការទាមទារដែលត្រឹមត្រូវ សូមពិនិត្យមើលឯកសារនៃលិខិតនោះ។)*

(៨) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។ [14]

---

[14] តុលាការត្រូវសម្រេចសេចក្តីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ (ម. ១៨២ ក. ៣ នៃ ក.ន.ណ.)។ ហើយប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី (ម. ៦៤ ក. ១ នៃ ក.ន.ណ.) ។



www.moj.gov.kh/kh/book-library

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ [15]

### ខ.១. ការបង្កើតអាពាហ៍ពិពាហ៍ និង ការរួមរស់ជីវភាពជាមួយគ្នាបន្ទាប់ពីពេលនោះ

ខ.១.១. ចុងចម្លើយកាលពីមុនបានរស់នៅក្បែរលំនៅឋានបច្ចុប្បន្នរបស់ដើមចោទ (ស្រុកកំណើតរបស់ដើមចោទ) ហើយដើមចោទស្ថិតនៅជាកុមារភាពនៅឡើយ។ ដោយសារតែការដើរស្វែងរកការងារធ្វើ ចុងចម្លើយក៏បានរើផ្ទះមកទីលំនៅបច្ចុប្បន្នរបស់ចុងចម្លើយ។ ក្រោយមក ដើមចោទ និងចុងចម្លើយបានស្រលាញ់គ្នារយៈពេលជាង១ឆ្នាំ ។ ហើយនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៥ ដើមចោទ និង ចុងចម្លើយ បានទៅចុះបញ្ជីអាពាហ៍ពិពាហ៍នៅសាលាឃុំ ដែលជាលំនៅឋានបច្ចុប្បន្នរបស់ដើមចោទ (ស្រុកកំណើតរបស់ដើមចោទ) បន្ទាប់មកក៏បានចាប់ផ្តើមរួមរស់ជីវភាពជាមួយគ្នានៅលំនៅឋានរបស់ចុងចម្លើយ។

**(ភស្តុតាង $X_1$, $X_2$)**

ខ.១.២. នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ កូនប្រុសឈ្មោះ សុក សុជាតិ (តទៅហៅថា "សុជាតិ") បានកើត។

**( ភស្តុតាង $X_3$ )**

ខ.១.៣. នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ កូនស្រីឈ្មោះ សុក សុជាតា (តទៅហៅថា "សុជាតា") បានកើត។

**( ភស្តុតាង $X_4$ )**

### ខ.២. មូលហេតុនៃការលែងលះគ្នា (មាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ង នៃ ក្រមរដ្ឋប្បវេណី)

ខ.២.១. ដើមចោទបានធ្វើការងារបណ្តើរ ហើយមើលថែទាំកូនបណ្តើរនៅរាជធានីភ្នំពេញទាំងពុំមានសាច់ញាតិណាម្នាក់នៅរាជធានីភ្នំពេញឡើយ ហើយបើទោះបីជានៅក្រោយកំណើតសុជាតិក៏ដោយ ក៏ភាគច្រើនចុងចម្លើយនៅតែបានយកការងារ និងការជួបជុំជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុនជាធំ ជាហេតុនាំឱ្យម៉ោងត្រឡប់មកផ្ទះវិញកាន់តែយប់ជ្រៅ។ មិនត្រឹមតែប៉ុណ្ណោះទេ ក្រោយពេលដើមចោទមានទម្ងន់សុជាតាក៏ដោយ ក៏ចុងចម្លើយមិនជួយសហការក្នុងការមើលថែទាំកូនទាល់តែសោះឡើយ បើទោះបីជាថ្ងៃសម្រាកក៏ដោយ ក៏គាត់បានចេញទៅក្រៅដោយនិយាយថា "មានការជួបជុំជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុន" ជាដើម។ ពេលដែលខ្ញុំរវល់មើលថែទាំកូនទាំង ២ ហើយខ្ញុំមិនអាចរៀបចំបាយទឹកឱ្យ Y នោះ Y ក៏ធ្លាប់បានស្តីបន្ទោសឱ្យខ្ញុំដូចជា "ផ្ទះនេះមិនត្រូវការអ្នកណាដែលមិនចេះធ្វើការងារផ្ទះទេ" ឬក៏ថា "ឱ្យខ្ញុំត្រឡប់ទៅស្រុកកំណើតវិញទៅ" ជាដើមថែមទៀតផង។

---

[15] អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង (ម. ៧៥ ក. ២ ច. ខ នៃ ក.ន.ណ.)។

ម្យ៉ាងទៀត នៅក្នុងពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូល ដែលទាក់ទងនឹង អង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង (ម. ៧៥ ក. ៣ នៃ ក.ន.ណ.) ។



www.moj.gov.kh/kh/book-library

(**ភស្តុតាង** $X_5$)

ខ.២.២. ដោយសារគិតអំពីកូនតូចទាំងពីរ ដើមចោទបានសុខចិត្តទ្រាំនឹងអាកប្បកិរិយាអស់ទាំងនេះ របស់ចុងចម្លើយ ដូចបានសរសេរនៅក្នុងចំណុច "ខ.២.១" ខាងលើនេះ។ ប៉ុន្តែនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៩ Y បានផឹកស្រា ហើយត្រឡប់មកផ្ទះវិញពាក់កណ្ដាលអធ្រាត្រ ដើមចោទបានព្រមានទៅចុងចម្លើយដោយសារតែបានធ្វើឱ្យភ្ញាក់សុជាតិ ដែលកំពុងតែគេងលក់ ស្រាប់តែចុងចម្លើយផ្ទុះកំហឹង ហើយបានប្រើអំពើហិង្សាមកលើដើមចោទភ្លាមៗតែម្ដង។ (**ភស្តុតាង** $X_5$)

ខ.២.៣. ដោយសារតែដើមចោទបានទទួលរងអំពើហិង្សាជាក់ស្ដែងពីចុងចម្លើយ ហេតុនេះហើយបានធ្វើឱ្យដើមចោទយល់ថា បើសិនជាបន្តរួមរស់ជីវភាពជាមួយចុងចម្លើយតទៅទៀត នឹងមានបញ្ហាទើប នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២០ ដើមចោទក៏បាននាំកូនទាំងពីរគឺ សុជាតិ និង សុជាតា ត្រឡប់ទៅស្រុកកំណើតរបស់ដើមចោទវិញ។ ចាប់ពីពេលនោះមក ដើមចោទ និង ចុងចម្លើយក៏បានបន្តរស់បែកគ្នា។ (**ភស្តុតាង** $X_6$)

ខ.២.៤. អាស្រ័យដូចបានលើកឡើងខាងលើនេះ ដោយហេតុថា ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ដូច្នេះហើយ ដើមចោទទាមទារលែងលះជាមួយចុងចម្លើយដោយផ្អែកតាម មាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ង នៃក្រមរដ្ឋប្បវេណី។

### ខ.៣. ការសម្រេចអំពីអ្នកមានអំណាចមេបា (មាត្រា ១០៣៧ កថាខណ្ឌទី១ និង ទី៣ នៃ ក្រមរដ្ឋប្បវេណី)

ខ.៣.១. ក្រោយពីការសម្រាល សុជាតិ និង សុជាតា ដើមចោទបានបីបាច់រក្សារូបកាយរបស់ពួកគេ រហូតមក។ ហើយសុជាតិ ទើបតែមានអាយុ ៣ ឆ្នាំ ចំណែកសុជាតា ទើបមានអាយុ ១ឆ្នាំ ដែលពួកគេទាំងពីរ គឺសុទ្ធតែនៅតូចៗ នៅឡើយ។ ដើម្បីឱ្យពួកគេទាំងពីរធំលូតលាស់បាន គឺមិនអាចខ្វះវត្តមានរបស់ ដើមចោទ ដែលជាម្ដាយបានឡើយ។

ខ.៣.២. មកទល់ពេលនេះ ចុងចម្លើយក៏មិនដែលជួយសហការមើលថែរក្សាកូនតូចៗទាំងពីរនេះ ទាល់តែសោះ ហើយស្ទើរតែពុំដែលបានប៉ះពាល់កូនឡើយ។

ខ.៣.៣. ដូច្នេះហើយដើមចោទសុំឱ្យតុលាការពិចារណាអំពីផលប្រយោជន៍របស់កូនទាំងពីរនាក់ ហើយសុំកំណត់អ្នកមានអំណាចមេបាលើកូនទាំងពីរឱ្យមកដើមចោទ។

### ខ.៤. បន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) (មាត្រា ១០៤០ កថាខណ្ឌទី ១, ទី ២, ទី ៤ និង ទី ៦ នៃ ក្រមរដ្ឋប្បវេណី)

ខ.៤.១. ដើមចោទបានលាឈប់ពីការងារនៅរាជធានីភ្នំពេញ បច្ចុប្បន្ននេះកំពុងតែគ្រប់គ្រងថែរក្សាកូនទាំងពីរ ដោយទទួលបានជំនួយពីឪពុកម្ដាយនៅឯស្រុកកំណើត។ បច្ចុប្បន្ននេះ ដើមចោទគ្មានប្រាក់ចំណូលទេ ដោយសារតែមិនមានការងារធ្វើ។

ខ.៤.២. ប៉ុន្តែចុងចម្លើយកំពុងតែធ្វើការជាបុគ្គលិកក្រុមហ៊ុននៅភ្នំពេញ ហើយមានប្រាក់ចំណូលប្រចាំឆ្នាំ ប្រហែលជា ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាម៉េរិក។

ខ.៤.៣. ហេតុដូច្នេះ ដើមចោទទាមទារទៅចុងចម្លើយឱ្យបង់ប្រាក់សម្រាប់កូនម្នាក់ៗ ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ប្រចាំខែនីមួយៗ (សរុបចំនួន ៣០០ (បីរយ) ដុល្លារអាម៉េរិក) ដែលជា សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទាំងពីរ (សោហ៊ុយចិញ្ចឹមបីបាច់កូន) ក្នុងអំឡុងពេល រហូតដល់កូនម្នាក់ៗ ក្លាយជានីតិជន។



www.moj.gov.kh/kh/book-library

### ខ.៥. ការទាមទារអាហារកិច្ច (មាត្រា ៧៦ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)

ខ.៥.១. ដើមចោទមិនមានកំហុសចំពោះការលែងលះគ្នាទេ ដូចបានសរសេរនៅក្នុងចំណុច "ខ.២" ខាងលើនេះ។ ម្យ៉ាងវិញទៀត ដើមចោទមិនមានប្រាក់ចំណូលទេ ដូចបានកត់ត្រានៅក្នុងចំណុច"ខ.៤.១" ។ ដូច្នេះ ដើមចោទទាមទារឱ្យចុងចម្លើយបង់អាហារកិច្ច។

ខ.៥.២. ដោយមើលឃើញថា ប្រាក់ចំណូលរបស់ចុងចម្លើយដូចបានកត់ត្រានៅក្នុងចំណុច "ខ.៤.២" ខាងលើនៅក្នុង១ឆ្នាំ បានប្រហែល ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាម៉េរិក ហើយចុងចម្លើយត្រូវទទួល បន្ទុកចំពោះសោហ៊ុយចិញ្ចឹមបីបាច់កូនទាំងពីរ ដូចបានកត់ត្រា នៅក្នុងចំណុច "ខ.៤.២" នៅក្នុង ១ឆ្នាំ ចំនួន ៣.៦០០ (បីពាន់ប្រាំមួយរយ) ដុល្លារអាម៉េរិក (៣០០ (បីរយ) ដុល្លារអាម៉េរិក X ១២ខែ = ៣.៦០០ (បីពាន់ប្រាំមួយរយ) ដុល្លារអាម៉េរិក) ដូច្នេះ ចំពោះចំនួនទឹកប្រាក់នៃអាហារកិច្ចគប្បីកំណត់ នៅក្នុង ១ ខែ ចំនួន ១០០ (មួយរយ) ដុល្លារអាម៉េរិក។

ខ.៥.៣. ដូច្នេះហើយ ដើមចោទទាមទារទៅចុងចម្លើយឱ្យបង់ប្រាក់ក្នុង ១ ខែ ចំនួន ១០០ (មួយរយ) ដុល្លារអាម៉េរិក ជាអាហារកិច្ចក្នុងអំឡុងពេលគិតត្រឹមដើមចោទរៀបអាពាហ៍ពិពាហ៍ថ្មី។

### ខ.៦. ការបែងចែងទ្រព្យសម្បត្តិ (មាត្រា ៩៨០ កថាខណ្ឌទី ២ នៃ ក្រមរដ្ឋប្បវេណី)

ខ.៦.១. រវាងដើមចោទ និងចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ។[16] **(ភស្តុតាង $X_7$ $X_8$ $X_9$ $X_{10}$)**

---

[16] ករណីដែលមិនអាចពិភាក្សាបានរវាងប្ដីប្រពន្ធ ត្រូវបែងចែកទ្រព្យសម្បត្តិអនុលោមតាមចំណុចនីមួយៗនៅក្នុងមាត្រា៩៨០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។ ចំពោះទ្រព្យសម្បត្តិដោយឡែកដែលកំណត់ នៅក្នុងមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី គឺសហព័ទ្ធ នីមួយៗ ត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែកនោះ ហេតុនេះមិនមានភាពចាំបាច់ដែលតុលាការត្រូវបែងចែកនោះទេ ។ ចំពោះ ទ្រព្យសម្បត្តិរួម (ម. ៩៧៣) ជាគោលការណ៍ សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលបាន ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម ប៉ុន្តែជា ករណីលើកលែង ប្រសិនបើមាន ① ករណីពិសេស និង ② ការទាមទាររបស់ប្ដីប្រពន្ធណាម្ខាង តុលាការអាចបែងចែកសមាមាត្រ ដែលខុសពី ១ ភាគ ២ បាន។



www.moj.gov.kh/kh/book-library

នៅក្នុងរឿងក្តីនេះ ដើមចោទបានអះអាង "ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះ" "លទ្ធកម្មនៃទ្រព្យសម្បត្តិ" (ម. ៩៨០ ក. ២ ច. ខ វ. ២ នៃ ក.រ.ណ.) ដែលជាករណីពិសេស ហើយសុំទាមទារតុលាការបែងចែកសមាមាត្រដែលមិនមែន ១ ភាគ ២។

ខ.៦.២. ចំពោះដី L1 និង ដី L2 គឺដើមចោទ និងចុងចម្លើយបានទិញដោយប្រើប្រាស់ប្រាក់សន្សំ ដែលមានរៀងៗខ្លួននៅមុនពេលអាពាហ៍ពិពាហ៍ និងប្រាក់ដែលបានខ្ចីពីធនាគាររួមគ្នា។ ចំពោះដី L1 គឺចង់ប្រទានកម្មទៅឱ្យសុជាតិ ដែលជាកូនរបស់ខ្លួនទាំងពីរ។[17] ***( *ការអះអាងនេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ត្រូវបានកែតម្រូវ ហេតុនេះចំពោះការអះអាងដែលត្រឹមត្រូវ សូមពិនិត្យមើលឯកសារនោះ។)*** ចំពោះដី L2 នឹងលក់ចេញ ហើយប្រាក់ថ្លៃ លក់នោះ គឺចង់ចែកពាក់កណ្តាលជាមួយចុងចម្លើយ។

ចំពោះរថយន្តនៃរឿងក្តីនេះ តម្លៃនាពេលបច្ចុប្បន្ន គឺ ១០.០០០ (មួយម៉ឺន) ដុល្លារអាម៉េរិក។ ដើមចោទ មិនសូវជាប្រើប្រាស់រថយន្តនៃរឿងក្តីនេះទេ ហេតុនេះ ប្រសិនបើអាចទទួលបានចំនួនទឹកប្រាក់៥.០០០ (ប្រាំពាន់) ដុល្លារអាម៉េរិក ដែលជាចំនួនប្រាក់ពាក់កណ្តាលពីចុងចម្លើយ គឺ ចុងចម្លើយអាចយកមកធ្វើជាកម្មសិទ្ធិបាន។

ចំពោះម៉ូតូនៃរឿងក្តីនេះ គឺដើមចោទបានទិញដោយប្រាក់បានមកពីលក់ម៉ូតូដែលមានកម្មសិទ្ធិ មុនពេលអាពាហ៍ពិពាហ៍ និងបន្ថែមដោយប្រាក់សន្សំរបស់ប្តីប្រពន្ធ។ ក្រោយពីបានរស់នៅបែកគ្នាជាមួយនឹងចុងចម្លើយក៏ដោយ ក៏ដើមចោទនៅតែប្រើប្រាស់ម៉ូតូនៃរឿងក្តីនេះ ហើយវាក៏ជាមានភាពចាំបាច់សម្រាប់ទៅទិញទំនិញប្រើប្រាស់ជាប្រចាំ ដូច្នេះដើមចោទចង់យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

ចំពោះប្រាក់សន្សំនៃរឿងក្តីនេះ គឺស្ថិតក្រោមឈ្មោះរបស់ចុងចម្លើយ ហេតុនេះទោះបីជាចុងចម្លើយ យកមកធ្វើជាកម្មសិទ្ធិក៏មិនអីដែរ ប៉ុន្តែនៅចំណុចនៃពេលចាប់ផ្តើមរស់នៅបែកគ្នារវាងដើមចោទ និងចុងម្លើយ គឺនៅមានសល់ប្រាក់ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាម៉េរិក ដូច្នេះទាមទារឱ្យបង់ប្រាក់ ចំនួន២៥០ (ពីររយហាសិប) ដុល្លារអាម៉េរិក ដែលជាចំនួនទឹកប្រាក់ពាក់កណ្តាល។

ចំពោះកាតព្វកិច្ចនីមួយៗ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ចំណុចលេខ ៦ និង៧ គឺដើមចោទមិនអាចបង់ប្រាក់បានទេ ហេតុនេះចង់ឱ្យចុងចម្លើយទទួលបន្ទុក។[18] ***( *ការអះអាងនេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យ បណ្តឹង" ត្រូវបានកែតម្រូវ ហេតុនេះចំពោះការអះអាងដែលត្រឹមត្រូវ សូមពិនិត្យមើលឯកសារនោះ។)***

## គ. ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីនៃរឿងក្តីនេះ គប្បីជាបន្ទុករបស់ចុងចម្លើយ (មាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

---

[17] នៅក្នុងការបែងចែកទ្រព្យសម្បត្តិ មិនអាចប្រទានកម្មទ្រព្យសម្បត្តិទៅឱ្យតតិយជន ក្រៅពីប្តីប្រពន្ធបានទេ ។ ប្រធាន ដែលទទួល បាននូវទ្រព្យសម្បត្តិគឺ "សហព័ទ្ធនីមួយៗ" ដែលមានចែងនៅក្នុងចំណុចនីមួយៗ នៃមាត្រា ៩៨០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។ ការណ៍ដែលឱ្យតតិយជន ក្រៅពីសហព័ទ្ធនីមួយៗទទួលបានគឺក្រមរដ្ឋប្បវេណីមិនទទួលស្គាល់នោះទការអះអាងនេះ ត្រូវបានកែតម្រូវដោយ "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ហេតុនេះ សូមពិនិត្យមើលទាំងឯកសារ នៃលិខិតនោះផង។

[18] កាតព្វកិច្ចដោយសាមគ្គីភាពរបស់ប្តីប្រពន្ធមិនអាចធ្វើការបែងចែកតែរវាងប្តីប្រពន្ធទេ។ ប្រសិនបើចង់ផ្លាស់ប្តូរអ្នកទទួលបន្ទុក ឬ ភាគទទួលបន្ទុកនៃកាតព្វកិច្ចត្រូវពិភាក្សាជាមួយម្ចាស់បំណុល (ក្នុងរឿងក្តីនេះ គឺធនាគារ)។ ចំពោះវិធីលម្អិត សូមយោងការពន្យល់ បន្ថែមនៅក្នុងឯកសារ ស្តីពីឧបសម្ព័ន្ធស្តីពី "ការអះអាងនីមួយៗរបស់ដើមចោទ និង ចុងចម្លើយ" ចំណុច 3។

ការអះអាងនេះ ត្រូវបានកែតម្រូវដោយ "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ហេតុនេះ សូមពិនិត្យមើលទាំងឯកសារ នៃលិខិតនោះផង។



www.moj.gov.kh/kh/book-library

## ឃ. ភស្តុតាង

១. សំបុត្រអាពាហ៍ពិពាហ៍របស់ដើមចោទ និង ចុងចម្លើយ (**ភស្តុតាង** $X_1$)[19]

២. សៀវភៅស្នាក់នៅរបស់ចុងចម្លើយ (**ភស្តុតាង** $X_2$)[20]

៣. សំបុត្រកំណើតរបស់សុជាតិ (**ភស្តុតាង** $X_3$)[21]

---

[19] "ភាគីនៃអាពាហ៍ពិពាហ៍" អាចដាក់ពាក្យបណ្តឹងទាមទារលែងលះបាន។ "អាពាហ៍ពិពាហ៍" នឹងមានអានុភាព ដោយ ①ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ② ការជូនដំណឹងជាសាធារណៈ ③ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ④ ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (ម. ៩៥៥ នៃ ក.រ.ណ.)។

ដូច្នេះបុគ្គលដែលមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ គឺមិនអាចដាក់ពាក្យបណ្តឹងទាមទារលែងលះបានទេ។ ក្នុងករណីដែលដាក់ពាក្យបណ្តឹងទាមទារលែងលះ ត្រូវតែដាក់នូវភស្តុតាងបញ្ជាក់អំពីការបានចុះបញ្ជីអាពាហ៍ពិពាហ៍ ពោលគឺសំបុត្រអាពាហ៍ពិពាហ៍។

[20] បណ្តឹងទាមទារលែងលះគ្នា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានលំនៅឋានរបស់ភាគី (ម. ១០ ក. ១ នៃ ក.ន.ណ.)។ "ផ្តាច់មុខ" គឺមានន័យថា មានតែតុលាការដែលបានកំណត់ប៉ុណ្ណោះ ទើបមានសមត្ថកិច្ចក្រៅពីតុលាការនោះ គឺពុំមានសមត្ថកិច្ចទេ (យោងតាម ម. ១៥ នៃ ក.ន.ណ.)។

តាមធម្មតា ក្រមនីតិវិធីរដ្ឋប្បវេណី ទទួលស្គាល់អំពីសមត្ថកិច្ចសាលាជម្រះក្តីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ (ម. ១៤ នៃ ក.ន.ណ.) ដូច្នេះហើយបើសិនជានៅពេលដែលដាក់ពាក្យបណ្តឹង ដើមចោទបានយកពាក្យបណ្តឹងទៅដាក់នៅតុលាការដែលគ្មានសមត្ថកិច្ចក៏ដោយ ក៏ចុងក្រោយតុលាការនោះនឹងនៅតែមានសមត្ថកិច្ច ។ ប៉ុន្តែករណីបែបនេះ នឹងមិនអាចកើតមាន ចំពោះពាក្យបណ្តឹងទាមទារលែងលះគ្នាបានទេ (នៅក្នុង ម. ១៥ នៃ ក.ន.ណ. មិនយក ម. ១៤ នៃក្រមដដែលនេះ មកអនុវត្តឡើយ)។

ហេតុដូច្នេះ ដំណាក់កាលនៃការដាក់ពាក្យបណ្តឹង ដើមចោទចាំបាច់ត្រូវសរសេរអំពីអាសយដ្ឋានរបស់ភាគីទុកជាមុនឱ្យបានច្បាស់លាស់។ ដូច្នេះ នៅពេលដាក់ពាក្យបណ្តឹងទាមទារលែងលះគ្នា គឺចាំបាច់ត្រូវតែដាក់នូវឯកសារដែលបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអាសយដ្ឋានរបស់ដើមចោទ និងចុងចម្លើយ ពោលគឺសៀវភៅស្នាក់នៅរបស់ភាគីនីមួយៗ។

[21] អ្នកដែលមានអំណាចមេបាមានសិទ្ធិ និង ករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយរបស់ "កូនដែលជាអនីតិជន" និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ (ម. ១០៣៤ នៃ ក.រ.ណ.) ។ ឪពុក ឬម្តាយដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិ ចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (ម. ១០៤០ ក. ១ នៃ ក.រ.ណ.)។ ដោយសារតែកូនដែលឪពុកម្តាយត្រូវគ្រប់គ្រងថែរក្សា គឺជាកូនដែលជាអនីតិជន ដូច្នេះ ការទទួលកាតព្វកិច្ចនូវបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយឪពុក ឬម្តាយដែលពុំមានអំណាចមេបា តាមរយៈការលែងលះគឺធ្វើឡើង នៅក្នុងអំឡុងពេលដែលកូននោះនៅជាអនីតិជន។ ម្យ៉ាងវិញទៀត អនីតិជនគឺសំដៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ (ម. ១៧ នៃ ក.រ.ណ.)។ ដើមចោទចាំបាច់ត្រូវតែបង្ហាញឱ្យបានច្បាស់លាស់ អំពីកូនរវាងដើមចោទ និងចុងចម្លើយថាជាអនីតិជន ដើម្បីទាមទារទៅចុងចម្លើយឱ្យអនុវត្តនូវកាតព្វកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន)។



www.moj.gov.kh/kh/book-library

៤. សំបុត្រកំណើតរបស់សុជាតា (**ភស្តុតាង** $X_4$)[22]
៥. កំណត់ហេតុប្រចាំថ្ងៃរបស់ដើមចោទ (**ភស្តុតាង** X5)
៦. សៀវភៅស្នាក់នៅរបស់ឪពុករបស់ដើមចោទ (**ភស្តុតាង** X6)[23]
៧. ច្បាប់ចម្លងនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ដី L1 (**ភស្តុតាង** X7)
៨. ច្បាប់ចម្លងនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ដី L2 (**ភស្តុតាង** X8)
៩. ច្បាប់ចម្លងនៃប័ណ្ណសម្គាល់យានជំនិះរបស់រថយន្តនៃរឿងក្តីនេះ (**ភស្តុតាង** X9)
១០. ប័ណ្ណសម្គាល់យានជំនិះរបស់ម៉ូតូនៃរឿងក្តីនេះ (**ភស្តុតាង** X10)

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។
សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ខេត្តបាត់ដំបង ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០
**អ្នកតំណាងដោយអាណត្តិ**

P

ឯកសារភ្ជាប់
១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"
២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ២ ច្បាប់"

[22] ខ្លឹមសារដូចគ្នានឹង Footnote 21 ។
[23] ខ្លឹមសារដូចគ្នានឹង Footnote 20 ។


www.moj.gov.kh/kh/book-library

**ឧបសម្ព័ន្ធ**

# បញ្ជីទ្រព្យសម្បត្តិរួម

១. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ.....ភូមិ....... ឃុំ.......... ស្រុក....... ខេត្តបាត់ដំបង

"លេខក្បាលដី" ..........

២. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ.......ភូមិ.......ឃុំ.......... ស្រុក....... ខេត្តបាត់ដំបង

"លេខក្បាលដី" ..........

៣. រថយន្ត

"ប្រភេទ" ទេសចរណ៍

"ម៉ាក" LEXUS RX300

"ពណ៌" ស

"កម្មសិទ្ធិករ" ចុងចម្លើយ

"អាសយដ្ឋាន" ផ្ទះលេខ 00 ផ្លូវ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ

"ផ្លាកលេខ" .....-.....

៤. ម៉ូតូ

"ប្រភេទ" ស្រី

"ម៉ាក" YAMAHA QBIX

"ពណ៌" ខ្មៅ

"កម្មសិទ្ធិករ" ដើមចោទ

"អាសយដ្ឋាន" ផ្ទះលេខ 00 ផ្លូវ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ

"ផ្លាកលេខ" .....-.....

៥. ប្រាក់សន្សំ

"ស្ថាប័នហិរញ្ញវត្ថុ" ធនាគារ...... សាខា........

"ប្រភេទ និង លេខគណនី" ប្រាក់សន្សំធម្មតា xxx xxx xxx

"ឈ្មោះម្ចាស់គណនី" ចុងចម្លើយ

៦. កាតឥណទានកិច្ច

"ស្ថាប័នហិរញ្ញវត្ថុ" ធនាគារ A សាខា........



www.moj.gov.kh/kh/book-library

"កូនបំណុល"                    ដើមចោទ និងចុងចម្លើយ (កាតព្វកិច្ចដោយសាមគ្គីភាព)

៧. កាតព្វកិច្ច

"ស្ថាប័នហិរញ្ញវត្ថុ"   ធនាគារ B សាខា........

"កូនបំណុល"                    ដើមចោទ និង ចុងចម្លើយ (កាតព្វកិច្ចដោយសាមគ្គីភាព)



www.moj.gov.kh/kh/book-library

២. គំរូលិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង[34]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង

**ដើមចោទ**

ឈ្មោះ : X

អាសយដ្ឋាន : ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ.......ឃុំ.......ស្រុក...... ខេត្តបាត់ដំបង។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី : P

អាសយដ្ឋានការិយាល័យ :

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី :

លេខទូរស័ព្ទ :

ទីកន្លែងបញ្ជូន : ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.......

**ចុងចម្លើយ**

ឈ្មោះ : Y

អាសយដ្ឋាន : ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**
**លោកចៅក្រម J នៃសាលាដំបូងខេត្តបាត់ដំបង**

**កម្មវត្ថុ** : ដាក់លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹងរបស់ X ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០២០

**យោង** : - មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- សំណុំរឿងរដ្ឋប្បវេណីលេខ…………………..ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០

ដោយសារតែនៅក្នុងពាក្យបណ្តឹងដែលបានដាក់នៅថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០២០ មានកំហុស ដូច្នេះខ្ញុំសុំកែតម្រូវដូចខាងក្រោម :

### ក. កែតម្រូវមួយផ្នែកទៅលើ "ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំ ដែលដើមចោទទាមទារឱ្យតុលាការចេញ"

ក.១. កែតម្រូវលេខ (៧) ចំណុច ក នៃ "ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំ ដែលដើមចោទទាមទារឱ្យតុលាការចេញ" ដូចខាងក្រោម [1] :

[34]. https://moj.gov.kh/files/user-folder/Justice_Library/Sample-Divorce/6_លិខិតពាក្យសុំកែតម្រូវពាក្យបណ្តឹង.pdf



www.moj.gov.kh/kh/book-library

"មុនពេលកែ"

ដី ដែលកត់ត្រានៅក្នុងចំណុច ១. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅ ថា "ដី L1") ជាកម្មសិទ្ធិរបស់កូនប្រុសរវាងដើមចោទ និងចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ។

"ក្រោយពេលកែ"

ដី ដែលកត់ត្រានៅក្នុងចំណុច ១. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅ ថា "ដី L1") ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗ ចំនួន ១ ភាគ ២។

បង្គាប់ឱ្យលក់ដេញថ្លៃលើ "ដី L1" ហើយយកចំនួនទឹកប្រាក់ដែលបានដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះ មកបែងចែកឱ្យទៅដើមចោទ និង ចុងចម្លើយ ក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

ក.២. កែតម្រូវលេខ (៧) ចំណុច ច. នៃ "ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំ ដែលដើមចោទទាមទារឱ្យតុលាការចេញ" ដូចខាងក្រោម[2] :

"មុនពេលកែ"

កាតព្វកិច្ច ដែលបានកត់ត្រានៅក្នុងចំណុច ៦. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាបន្ទុករបស់ចុងចម្លើយ។

[1] នៅក្នុងការបែងចែកទ្រព្យសម្បត្តិ  មិនអាចប្រទានកម្មទ្រព្យសម្បត្តិទៅឱ្យតតិយជនក្រៅពីប្តីប្រពន្ធបានទេ។  ប្រធានដែលទទួលបាននូវទ្រព្យសម្បត្តិគឺ  "សហព័ទ្ធនីមួយៗ ដែលមានចែងនៅក្នុងចំណុចនីមួយៗ នៃមាត្រា ៩៨០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី។ ការណ៍ដែលឱ្យតតិយជនក្រៅពីសហព័ទ្ធនីមួយៗទទួលបាន គឺក្រមរដ្ឋប្បវេណីមិនទទួលស្គាល់នោះទេ។

[2] កាតព្វកិច្ចដោយសាមគ្គីភាពរបស់ប្តីប្រពន្ធ មិនអាចធ្វើការបែងចែកតែរវាងប្តីប្រពន្ធទេ។ ប្រសិនបើចង់ផ្លាស់ប្តូរអ្នកទទួលបន្ទុក ឬ ភាគីទទួលបន្ទុកនៃកាតព្វកិច្ចត្រូវពិភាក្សាជាមួយម្ចាស់បំណុល (ក្នុងរឿងក្តីនេះគឺធនាគារ)។ ចំពោះវិធីលម្អិត សូមយោងការពន្យល់បន្ថែមនៅក្នុងឯកសារស្តីពីឧបសម្ព័ន្ធស្តីពី "ការអះអាងនីមួយៗរបស់ ដើមចោទ និង ចុងចម្លើយ" ចំណុច * 3 ។



www.moj.gov.kh/kh/book-library

"ក្រោយពេលកែ"

លុបចោលចំណុចនេះ។

ក.៣. កែតម្រូវលេខ (៧) ចំណុច ឆ នៃ "ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទ ទាមទារឱ្យតុលាការចេញ" ដូចខាងក្រោម[3] :

"មុនពេលកែ"

កាតព្វកិច្ច ដែលបានកត់ត្រានៅក្នុងចំណុច ៧. "បញ្ជីទ្រព្យសម្បត្តិរួម" នៃ ឧបសម្ព័ន្ធ ជាបន្ទុករបស់ចុងចម្លើយ។

"ក្រោយពេលកែ"

លុបចោលចំណុចនេះ។

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្តីអនុគ្រោះ។

ខេត្តបាត់ដំបង ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០

**អ្នកតំណាងដោយអាណត្តិ**

---

[3] យោង Footnote 2 ។



www.moj.gov.kh/kh/book-library

៣. គំរូឯកសារចម្លើយ[35]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ឯកសារចម្លើយ[1]

### ដើមចោទ

ឈ្មោះ : X

អាសយដ្ឋាន : ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ......ឃុំ.......ស្រុក.............ខេត្តបាត់ដំបង។

### ចុងចម្លើយ

ឈ្មោះ : Y

អាសយដ្ឋាន : ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

### អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រីមេធាវី : B

អាសយដ្ឋានការិយាល័យ : .............................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី : ............................

លេខទូរស័ព្ទ : .......

ទីកន្លែងបញ្ជូន : ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី : ..........................[2]

[1] ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅ តុលាការជាលើកដំបូង ហៅថា "ឯកសារចម្លើយ"។ នៅក្នុងឯកសារនេះ នឹងត្រូវសរសេរអំពី ① ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្ដឹង ② ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង និង ③ អង្គហេតុដើម្បីតវ៉ា ចំពោះអង្គហេតុដែលមានសរសេរ នៅក្នុងពាក្យបណ្ដឹង (ម. ១០១ ក. ៣ នៃ ក.ន.ណ.)។

[2] មាត្រា ២៤៩ និង មាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីកន្លែងបញ្ជូន មិនមែនជាកាតព្វកិច្ចទេ។ ប្រសិនបើមិនបានសរសេរអំពីទីកន្លែងបញ្ជូន ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅឋានរបស់ចុងចម្លើយ ជាអាទិ៍។ ដូច្នេះ នៅក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយចង់ធ្វើការបញ្ជូនទៅទីកន្លែងណាផ្សេងក្រៅពី លំនៅឋានរបស់ចុងចម្លើយ ជាអាទិ៍ ចាំបាច់ត្រូវសរសេរអំពីកន្លែងបញ្ជូន ចូលទៅក្នុងលិខិតលាយលក្ខណ៍អក្សរ ដូចជាឯកសារចម្លើយជាអាទិ៍។

[35]. https://moj.gov.kh/files/user-folder/Justice_Library/Sample-Divorce/7_ឯកសារចម្លើយ.pdf



www.moj.gov.kh/kh/book-library

## សូមគោរពជូន
## លោក / ចៅក្រមនៃសាលាដំបូងខេត្តបាត់ដំបង

**កម្មវត្ថុ** : សុំដាក់ឯកសារចម្លើយដើម្បីឆ្លើយតបនឹងពាក្យបណ្ដឹង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ និង លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្ដឹងចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ របស់ឈ្មោះ X

**យោង** : - មាត្រា ១០១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- សំណុំរឿងរដ្ឋប្បវេណី.......... ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០

### ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រម និង ការទាត់ចោលបន្ទាប់បន្សំ ដែលដើមចោទទាមទារឱ្យតុលាការចេញ

(១) ច្រានចោលការទាមទាររបស់ដើមចោទ។

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

### ខ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង

**ខ.១. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "ការបង្កើតអាពាហ៍ពិពាហ៍ និង ការរួមរស់ជីវភាពជាមួយគ្នាបន្ទាប់ពី** ពេលនោះ នៃចំណុច ខ.១." នៅក្នុងពាក្យបណ្ដឹង

ខ.១.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.១.១." នៃពាក្យបណ្ដឹង : ចុងចម្លើយទទួលស្គាល់។

ខ.១.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.១.២." នៃពាក្យបណ្ដឹង : ចុងចម្លើយទទួលស្គាល់។

ខ.១.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.១.៣" នៃពាក្យបណ្ដឹង : ចុងចម្លើយទទួលស្គាល់។

**ខ.២. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "មូលហេតុនៃការលែងលះគ្នា ( មាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ង នៃក្រមរដ្ឋប្បវេណី ) នៃចំណុច ខ.២." នៅក្នុងពាក្យបណ្ដឹង**

ខ.២.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.១." នៃពាក្យបណ្ដឹង : ចុងចម្លើយទទួលស្គាល់ថា ដើមចោទពុំមានសាច់ញាតិណាម្នាក់នៅរាជធានីភ្នំពេញឡើយ ហើយអង្គហេតុក្រៅពីនោះចុងចម្លើយមិនទទួលស្គាល់។ មូលហេតុគឺមានដូចបានសរសេរនៅក្នុង ចំណុច "គ. ការអះអាងរបស់ចុងចម្លើយ" ខាងក្រោម។

ខ.២.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.២." នៃពាក្យបណ្ដឹង : ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុ គឺមានដូចបានសរសេរ នៅក្នុងចំណុច "គ. ការអះអាងរបស់ចុងចម្លើយ" ខាងក្រោម។

ខ.២.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.៣." នៃពាក្យបណ្ដឹង : ចុងចម្លើយទទួលស្គាល់ថា នៅថ្ងៃទី ៤ ខែមករា ឆ្នាំ ២០២០ ដើមចោទបាននាំ សុជាតិ និង សុជាតា ត្រឡប់ទៅស្រុកកំណើតរបស់ដើមចោទវិញ ហើយចាប់ពីពេលនោះមកដើមចោទ និងចុងចម្លើយក៏បានបន្តរស់នៅបែកគ្នា រីឯអង្គហេតុក្រៅពីនោះ ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុ គឺមានដូចបានសរសេរនៅក្នុងចំណុច "គ.ការអះអាងរបស់ចុងចម្លើយ" ខាងក្រោម។



www.moj.gov.kh/kh/book-library

ខ.២.៤. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.៤." នៃពាក្យបណ្តឹង : ចុងចម្លើយមានវិវាទ។

**ខ.៣. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "ការសម្រេចអំពីអ្នកមានអំណាចមេបា (មាត្រា ១០៣៧ កថាខណ្ឌទី ១ និង ទី ៣ នៃ ក្រមរដ្ឋប្បវេណី) នៃ ចំណុច ខ.៣." នៅក្នុងពាក្យបណ្តឹង**

ខ.៣.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៣.១." នៃពាក្យបណ្តឹង : ចុងចម្លើយទទួលស្គាល់ថា សុជាតិ អាយុ ៣ឆ្នាំ និង សុជាតា អាយុ ១ ឆ្នាំ ហើយអង្គហេតុក្រៅពីនោះ ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុ គឺមានដូចបានសរសេរនៅក្នុងចំណុច "គ. ការអះអាងរបស់ចុងចម្លើយ" ខាងក្រោម។

ខ.៣.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៣.២." នៃពាក្យ បណ្តឹង : ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុ គឺមានដូចបាន សរសេរនៅក្នុងចំណុច "គ. ការអះអាងរបស់ចុងចម្លើយ" ខាងក្រោម។

ខ.៣.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៣.៣." នៃពាក្យបណ្តឹង : ចុងចម្លើយមានវិវាទ។

**ខ.៤. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "បន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) (មាត្រា ១០៤០ កថាខណ្ឌទី ១, ទី ២, ទី ៤ និង ទី ៦ នៃ ក្រមរដ្ឋប្បវេណី) នៃចំណុច ខ.៤." នៅក្នុងពាក្យបណ្តឹង**

ខ.៤.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៤.១." នៃពាក្យបណ្តឹង : ចុងចម្លើយទទួលស្គាល់ថា ដើមចោទគ្មានប្រាក់ចំណូល ហើយអង្គហេតុក្រៅពីនោះ ចុងចម្លើយមិនដឹង។

ខ.៤.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៤.២." នៃពាក្យបណ្តឹង : ចុងចម្លើយទទួលស្គាល់។

ខ.៤.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៤.៣." នៃពាក្យបណ្តឹង : ចុងចម្លើយមានវិវាទ។

**ខ.៥. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "ការទាមទារអាហារកិច្ច (មាត្រា ៧៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ) នៃចំណុច ខ.៥." នៅក្នុងពាក្យបណ្តឹង**

ខ.៥.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៥.១." នៃពាក្យបណ្តឹង : ចុងចម្លើយទទួលស្គាល់ថា ដើមចោទគ្មានប្រាក់ចំណូល ហើយអង្គហេតុក្រៅពីនោះ ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុនោះ គឺមានដូចបានសរសេរ នៅក្នុងចំណុច "គ.ការអះអាងរបស់ចុងចម្លើយ" ខាងក្រោម។

ខ.៥.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៥.២." នៃពាក្យបណ្តឹង : ចុងចម្លើយទទួលស្គាល់ថា ប្រាក់ចំណូលរបស់ចុងចម្លើយ នៅក្នុង១ឆ្នាំ បានប្រហែល ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាម៉េរិក ហើយអង្គហេតុ ក្រៅពីនោះចុងចម្លើយមិនទទួលស្គាល់ទេ។ ដើមចោទបានឡើយហត់នឹងការមើលថែទាំកូន ដូច្នេះគ្រាន់តែត្រឡប់ទៅស្រុកកំណើតវិញតែប៉ុណ្ណោះ។ ចុងចម្លើយមិនបានគិតថា ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទនិងចុងឆ្លើយបានបែកបាក់ទេ ប៉ុន្តែ បើសិនជាដើមចោទបានគិតថា ទំនាក់ទំនងអាពាហ៍ពិពាហ៍ជាមួយនឹងចុងឆ្លើយបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ កំហុសនោះគឺជាកំហុសរបស់ដើមចោទ។ ចុងចម្លើយ មិនមានកាតព្វកិច្ចចំពោះការបង់អាហារកិច្ចទេ។

ខ.៥.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៥.៣." នៃពាក្យបណ្តឹង : ចុងចម្លើយមានវិវាទ។

**ខ.៦. ការទទួលស្គាល់ ឬមិនទទួលស្គាល់អំពី "ការបែងចែងទ្រព្យសម្បត្តិ (កថាខណ្ឌ ទី ២ នៃមាត្រា ៩៨០ ក្រមរដ្ឋប្បវេណី) នៃចំណុច ខ.៦." នៅក្នុងពាក្យបណ្តឹង**



www.moj.gov.kh/kh/book-library

ខ.៦.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៦.១." នៃពាក្យ បណ្តឹង : ចុងចម្លើយទទួលស្គាល់។

ខ.៦.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៦.២." នៃពាក្យបណ្តឹង : ចុងចម្លើយមានវិវាទ។ ដើម្បីទទួលបាន "ដី L1" និង រថយន្តនៃរឿងក្តីនេះ" ចុងចម្លើយមិនត្រឹមតែបានប្រើប្រាស់ទ្រព្យសម្បត្តិរួមតែប៉ុណ្ណោះទេ ថែមទាំងបានប្រើប្រាស់នូវទ្រព្យសម្បត្តិដោយឡែក របស់ចុងចម្លើយមួយភាគផងដែរ ដូច្នេះ សូមតុលាការពិចារណាទៅលើទំហំនៃការបរិច្ចាគរបស់ចុងចម្លើយ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិទាំងនេះ នៅពេលដែលបែងចែកទ្រព្យសម្បត្តិរួម ( ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ" មាត្រា ៩៨០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ ចំណុច ខ នៃក្រមរដ្ឋប្បវេណី )។

## គ. ការអះអាងរបស់ចុងចម្លើយ

### គ.១. ពុំមានមូលហេតុនៃការលែងលះគ្នា (មាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ង នៃ ក្រមរដ្ឋប្បវេណី)

គ.១.១.ចាប់តាំងពីបានចាប់ផ្តើមរួមរស់ជីវភាពរួមគ្នាជាមួយដើមចោទដើម្បីរកប្រាក់ចំណូលឱ្យបានច្រើនបន្ថែមទៀត ភាគច្រើនចុងចម្លើយបានធ្វើការបន្ថែមម៉ោង និង បានចូលរួមយ៉ាងសកម្មចំពោះការជួបជុំជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុនជាដើម ដែលជាហេតុធ្វើឱ្យម៉ោងត្រឡប់មកផ្ទះវិញកាន់តែយប់ជ្រៅ។ ប៉ុន្តែ ដើមចោទបែរជាសង្ស័យថាចុងចម្លើយមិនស្មោះត្រង់ ហើយក្រោយពេលសុជាតាកើតមក ដើមចោទបែរជាគិតតែពីនិយាយរអ៊ូថា តើថ្ងៃនេះទើបមកពីផឹកជាមួយស្រីនៅកន្លែងណា? ជាដើម ហើយថ្ងៃដែលដើមចោទមិនបានរៀបចំបាយទឹកហូបចុកក៏កាន់តែច្រើនឡើងៗ។ បើទោះជាចុងចម្លើយបានធុញទ្រាន់ទៅនឹងអាកប្បកិរិយារបស់ដើមចោទ ដែលមិនបានយល់ពីការងាររបស់ចុងចម្លើយក៏ដោយ ប៉ុន្តែ ចុងចម្លើយបានធ្វើចិត្តឱ្យត្រជាក់ហើយគិតថា អាកប្បកិរិយារបស់ដើមចោទទៅជាបែបនេះ ក៏ព្រោះតែដើមចោទលែងមានពេលលំហែអារម្មណ៍ ដោយសារតែត្រូវធ្វើការងារ និង មើលថែទាំកូនទៀត ដូច្នេះចុងចម្លើយក៏បានសាកផ្តល់ជាគំនិតទៅដើមចោទថា ដើម្បីផ្លាស់ប្តូរអារម្មណ៍សាកទៅសម្រាកនៅស្រុកកំណើតមួយរយៈលមើល?" ជាដើម ។ (**ភស្តុតាង Y₁**)

គ.១.២.ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៩ ដោយសារតែចុងចម្លើយចូលរួមកម្មវិធីជប់លៀងគ្រីស្ទីម៉ាសជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុន ហេតុនេះ ក៏បានត្រឡប់ទៅផ្ទះវិញយឺត។ ពេលត្រឡប់ទៅដល់ផ្ទះវិញកូនទាំងពីរបានគេងលក់បាត់ទៅហើយ ប៉ុន្តែ ដោយសារចុងចម្លើយបានរៀបចំកាដូគ្រីស្តម៉ាសឱ្យទៅពួកគេ ហើយចង់ឱ្យកូនទាំង ២ ចាប់អារម្មណ៍ឃើញនៅពេលដែលក្រោកពីដំណេកថ្ងៃបន្ទាប់ ដូច្នេះចុងចម្លើយក៏បានគិតថាយកកាដូនោះទៅទុកនៅលើក្បាលដំណេករបស់ពួកគេ។ ពេលដែលចុងចម្លើយបានធ្វើបែបនេះ ស្រាប់តែដើមចោទបានខឹងស្រែកខ្លាំងៗថា "ធ្វើស្អីហ្នឹង?!" ហើយក៏បានយកដៃរុញមកចុងចម្លើយដែលបានខិតចូលទៅជិតក្បាលដំណេកកូនៗ។ ដោយសារតែ ចុងចម្លើយគិតថាដៃរបស់ដើមចោទអាចនឹងប៉ះត្រូវចំកូនជាមិនខាន ក៏បានហាមឃាត់ដើមចោទទាំងភ័យស្លន់ស្លោ ហើយដើម្បីកុំឱ្យកូនភ្ញាក់ ចុងចម្លើយក៏បានបីដើមចោទពីបន្ទប់គេងចេញមកក្រៅ។ ដើមចោទបានអះអាងថា បានរងនូវអំពើហិង្សាពីចុងចម្លើយ ប៉ុន្តែ អង្គហេតុបែបនេះ គឺគ្មានទាល់តែសោះឡើយ។ (**ភស្តុតាង Y₁**)

គ.១.៣.នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២០ ដើមចោទបានត្រឡប់ទៅស្រុកកំណើតវិញ ដោយបាននាំយកកូនទាំងពីរទៅជាមួយផងដែរ ទាំងមិនបាននិយាយពន្យល់អ្វីមកឱ្យចុងចម្លើយដឹងសោះ។



www.moj.gov.kh/kh/book-library

គ.១.៤. បើផ្អែកតាមដំណើររឿងដែលបានលើកឡើងខាងលើនេះ គឺពុំមានមូលហេតុនៃការលែងលះដូចដែលដើមចោទបានអះអាងទេ ។ បើទោះបីជារវល់នឹងការងារក៏ដោយ ក៏ចុងចម្លើយបានរក្សាអារម្មណ៍របស់ខ្លួន ហើយបានយកចិត្តទុកដាក់ទៅលើដើមចោទផងដែរ ដូច្នេះ ទំនាក់ទំនងអាពាហ៍ពិពាហ៍មិនទាន់បានបែកបាក់នៅឡើយទេ។ ផ្ទុយមកវិញ ដើមចោទបែរជាចាប់ផ្ដើមរស់នៅបែកគ្នាដោយចិត្តឯង ហេតុនេះ គួរតែដើមចោទទៅវិញទេ ដែលចង់ឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍ ជាមួយចុងចម្លើយមានការបែកបាក់នោះ។

**គ.២. អំពីការចាត់ចែងបន្ទាប់បន្សំ**

ដូចដែលបានអះអាងនៅក្នុងចំណុច គ.១" ខាងលើនេះ ដោយសារតែទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និង ចុងចម្លើយមិនទាន់បានបែកបាក់ទេ ដូច្នេះ ចុងចម្លើយយល់ថា បណ្ដឹងទាមទារឱ្យលែងលះរបស់ដើមចោទ នឹងមិនត្រូវបានទទួលស្គាល់ទេ។ ដូច្នេះ ចំពោះការចាត់ចែងបន្ទាប់បន្សំ ដែលបានលើកយកមកផ្អែកជាមុន ទៅលើកករណីដែលការទាមទាររបស់ដើមចោទត្រូវបានទទួលស្គាល់នោះ ក៏ចុងចម្លើយមិនអាចទទួលស្គាល់មួយណាបានផងដែរ។

ម្យ៉ាងវិញទៀត ដើមចោទជាមនុស្សមានសតិអារម្មណ៍មិននឹងនរ ហើយ ស្រែកខ្លាំងៗភ្លាមៗ មួយរំពេចទៅកាន់ចុងចម្លើយ ជាដើម។ ការចិញ្ចឹមបីបាច់របស់ដើមចោទចំពោះកូនទាំងពីរនឹងមិនអាចធ្វើឱ្យបានត្រឹមត្រូវឡើយ។ ដើមចោទមិនសមនឹងក្លាយទៅជាអ្នកមានអំណាច មេបាលើកូនទាំងពីរនេះទេ។

**ឃ. ភស្តុតាង**

១. កំណត់ត្រាដែលសាមីចុងចម្លើយបានបង្កើតឡើង ដោយផ្អែកតាមការចងចាំ (**ភស្តុតាង**Y₁)

២. ការសាកសួរសាមីចុងចម្លើយ

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្ដីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

**អ្នកតំណាងដោយអាណត្តិ**

B

ឯកសារភ្ជាប់

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ច្បាប់ដើម

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗ ខាងលើ "ចំនួន ២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ២ ច្បាប់"



www.moj.gov.kh/kh/book-library

៤. គំរូលិខិតសាលក្រម[36]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តបាត់ដំបង**

តុលាការរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី លេខ ........

ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០

សាលក្រមលេខ ........

ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២០

**សាលក្រម** [1]

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តបាត់ដំបង** [2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ
ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០[3] [4]

---

[1] ការសម្រេចសេចក្តី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (ម. ១៧៩ នៃ ក.ន.ណ.) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឱ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្តីដាក់នៅត្រង់ចំណុចចាប់ផ្តើម។ ដោយសារតែសាលក្រម និង ដីកាសម្រេចមានភាពខុសគ្នា ចំពោះវិធីក្នុងការធ្វើឧបាស្រ័យ ជាអាទិ៍។ ជាគោលការណ៍ បណ្តឹងឧបាស្រ័យចំពោះសាលក្រម គឺបណ្តឹងឧទ្ធរណ៍ ហើយបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច គឺបណ្តឹងជំទាស់ (ម.២៥៩ ក.១ នៃ ក.ន.ណ.)។

[2] នៅក្នុងលិខិតសាលក្រមរដ្ឋប្បវេណី ត្រូវតែសរសេរអំពីចំណុច ដែលចែងនៅក្នុងមាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ សាលក្រម និងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ម. ១៩៨ ក. ២ នៃ ក.ន.ណ.) ហេតុនេះ ចាំបាច់ត្រូវសរសេរឱ្យបានច្បាស់លាស់ អំពីពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ សាលក្រម គឺជាការសម្រេចសេចក្តីរបស់តុលាការដែលត្រូវបានធ្វើឡើង ដោយកំណត់ជាមូលដ្ឋានចម្បងនូវទំនាក់ទំនងអង្គហេតុគិតមកដល់ត្រឹមថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[4] ជាគោលការណ៍ ការប្រកាសសាលក្រម ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃ ដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ម. ១៨៧ នៃ ក.ន.ណ.) ។ ហើយការប្រកាសសាលក្រម ចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (ម. ១៨៨ ក. ១ នៃ ក.ន.ណ.) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឱ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

---

[36]. https://moj.gov.kh/files/user-folder/Justice_Library/Sample-Divorce/9-សាលក្រម.pdf



www.moj.gov.kh/kh/book-library

### ចៅក្រមជំនុំជម្រះ

### លោក J ជាចៅក្រមនៃសាលាដំបូងខេត្តបាត់ដំបង

### ក្រឡាបញ្ជី

### លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តបាត់ដំបង

**ដើមចោទ**

ឈ្មោះ : X

អាសយដ្ឋាន : ផ្ទះលេខ ០០ ផ្លូវលេខ ១០០ ភូមិ............ឃុំ.............ស្រុក.................ខេត្តបាត់ដំបង។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី : P

អាសយដ្ឋានការិយាល័យ : .......................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី : .......................

លេខទូរស័ព្ទ : .......................

**ចុងចម្លើយ**

ឈ្មោះ : Y

អាសយដ្ឋាន : ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី : B

អាសយដ្ឋានការិយាល័យ : .......................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី : .......................

លេខទូរស័ព្ទ : .......................



www.moj.gov.kh/kh/book-library

## អង្គហេតុ និង ចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទ ទាមទារឱ្យ តុលាការចេញ [5] :

(១) លែងលះដើមចោទ និង ចុងចម្លើយ។

(២) កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុសរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ (កើតនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦)។

(៣) កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតា (កើតនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៨)។

(៤) បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ក្នុង១ខែ ឱ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះ ចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតិ ដែលបានកត់ត្រានៅក្នុងចំណុច (២) ខាងលើនេះ ក្លាយជានីតិជន។

(៥) បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ក្នុង១ខែ ឱ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះ ចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតា ដែលបានកត់ត្រានៅក្នុងចំណុច (៣) ខាងលើនេះ ក្លាយជានីតិជន។

(៦) បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០ (មួយរយ) ដុល្លារអាម៉េរិក ក្នុង ១ខែ ឱ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ដើមចោទរៀបអាពាហ៍ពិពាហ៍ថ្មី។

(៧) បែងចែកទ្រព្យសម្បត្តិនីមួយៗដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួមនៃឧបសម្ព័ន្ធដូចខាងក្រោមនេះ :

---

[5] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ម្យ៉ាងទៀត ប្រសិនបើតុលាការចេញសាលក្រម ឬ សាលដីកាដែលទទួលស្គាល់បណ្តឹងទាមទារលែងលះ តុលាការនឹងត្រូវសម្រេចសេចក្តីអំពីការចាត់ចែងបន្ទាប់បន្សំ (កំណត់អ្នកមានអំណាចមេបា ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬ ការចាត់ចែងទាក់ទងនឹងការ បែងចែកទ្រព្យសម្បត្តិ) ដោយឆន្ទានុសិទ្ធិ ឬ តាមពាក្យសុំ ដូច្នេះហើយ ដើមចោទគប្បីសរសេរទុកជាមុនអំពីខ្លឹមសារនៃការចាត់ចែងបន្ទាប់បន្សំដែលទាមទារឱ្យតុលាការចេញ ទើបជាការប្រសើរ (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល) ។



www.moj.gov.kh/kh/book-library

ក. ដី ដែលកត់ត្រានៅក្នុងចំណុច ១. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅ ថា "ដី L1") ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយ ក្នុងចំណែកម្នាក់ៗ ចំនួន ១ ភាគ ២។

បង្គាប់ឱ្យលក់ដេញថ្លៃលើ "ដី L1" ហើយយកចំនួនទឹកប្រាក់ដែលបាន ដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះ មកបែងចែកឱ្យទៅដើមចោទ និង ចុងចម្លើយ ក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

ខ. ដី ដែលកត់ត្រានៅក្នុងចំណុច ២. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅ ហៅថា "ដី L2") ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយ ក្នុងចំណែក ម្នាក់ៗចំនួន ១ ភាគ ២។

បង្គាប់ឱ្យលក់ដេញថ្លៃលើ "ដី L 2" ហើយយកចំនួនទឹកប្រាក់ដែលបាន ដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះមកបែងចែកឱ្យទៅដើមចោទ និង ចុងចម្លើយ ក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

គ. ឡាន ដែលបានកត់ត្រានៅក្នុងចំណុច ៣. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "រថយន្តនៃរឿងក្តីនេះ") ជាកម្មសិទ្ធិរបស់ចុងចម្លើយ។

បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាម៉េរិក ឱ្យទៅដើមចោទ។

ឃ. ម៉ូតូ ដែលបានកត់ត្រានៅក្នុងចំណុច ៤. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ម៉ូតូនៃរឿងក្តីនេះ") ជាកម្មសិទ្ធិរបស់ដើមចោទ។

ង. ប្រាក់សន្សំ ដែលបានកត់ត្រានៅក្នុងចំណុច ៥. "បញ្ជីទ្រព្យសម្បត្តិរួម" នៃ ឧបសម្ព័ន្ធ (តទៅហៅថា "ប្រាក់សន្សំនៃរឿងក្តីនេះ") ជាកម្មសិទ្ធិចុងចម្លើយ។

បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ២៥០ (ពីររយហាសិប) ដុល្លារអាម៉េរិក ឱ្យទៅដើមចោទ។

(៨) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## ខ. ដំណើររឿងក្តី និង ចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្តី

នៅក្នុងរឿងក្តីនេះ ដើមចោទបានអះអាងថា ទំនាក់ទំនងអាពាហ៍ពិពាហ៍ ជាមួយចុងចម្លើយបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ដូច្នេះ មានមូលហេតុនៃការលែងលះ ដូចមានចែងនៅក្នុងមាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ង នៃក្រមរដ្ឋប្បវេណី ហើយក្រៅពីធ្វើការទាមទារអំពីការលែងលះទៅកាន់ចុងចម្លើយរួចហើយ ដើមចោទក៏ទាមទារនូវការកំណត់ថា ដើមចោទគឺជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់ ហើយថែមទាំងបានដាក់ពាក្យសុំទាមទារនូវការបង់សោហ៊ុយចិញ្ចឹមបីបាច់ថែរក្សាកូន ការបង់អាហារកិច្ច និង ការបែងចែកទ្រព្យសម្បត្តិ ដែលជាការចាត់ចែងបន្ទាប់បន្សំផងដែរ។


www.moj.gov.kh/kh/book-library

### ខ.២. អង្គហេតុដែលជាមូលដ្ឋានដើម្បីពិចារណាអំពីចំណុចវិវាទ [6]

ខ.២.១.នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៥ ដើមចោទ និង ចុងចម្លើយបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ ហើយបានចាប់ផ្តើមរួមរស់ជីវភាពជាមួយគ្នា នៅលំនៅឋានរបស់ចុងចម្លើយ។ (**ភស្តុតាង** $X_1$ $X_2$)

ខ.២.២.ដើមចោទមិនមានសាច់ញាតិនៅក្នុងរាជធានីភ្នំពេញទេ។ (**ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់** [7])

ខ.២.៣. ក្រោយពេលដែលបានចាប់ផ្តើមរួមរស់ជីវភាពជាមួយគ្នានិងដើមចោទ ចុងចម្លើយភាគច្រើនត្រឡប់មកផ្ទះវិញយប់ជ្រៅ។ (**ភស្តុតាង** $X_5$ $Y_1$)

ខ.២.៤. ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ដើមចោទ និង ចុងចម្លើយកើតបានកូនប្រុសឈ្មោះ សុក សុជាតិ (តទៅហៅថា “សុជាតិ)។ (**ភស្តុតាង** $X_3$)

ខ.២.៥. ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៨ ដើមចោទ និង ចុងចម្លើយកើតបានកូនស្រីឈ្មោះ សុក សុជាតា (តទៅហៅថា “សុជាតា)។ (**ភស្តុតាង** $X_4$)

ខ.២.៦. ថ្ងៃទី៤ ខែមករា ឆ្នាំ២០២០ ដើមចោទបាននាំសុជាតិ និង សុជាតា ត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ។ (**ភស្តុតាង** $X_6$)

---

[6] នៅក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ផ្នែកដែលទាក់ទងនឹងអង្គហេតុដែលភាគីបានសារភាព ចំពោះមុខតុលាការ នៅក្នុងមាត្រា ៩៦ កថាខណ្ឌទី ១ និង មាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ (ម. ១៣ ក. ១ នៃ ច.ន.ឋ.)។ ដូច្នេះ ទោះបីជាអង្គហេតុដែលគូភាគីមិនមានវិវាទក៏ដោយ ក៏តុលាការត្រូវតែទទួលស្គាល់អង្គហេតុនោះ ដោយ ផ្អែកតាមភស្តុតាងផងដែរ (ម. ១២៣ ក. ១ នៃ ក.ន.ណ.) ។

នៅក្នុងលិខិតសាលក្រមនៃបណ្តឹងរដ្ឋប្បវេណីធម្មតា តុលាការបានសរសេរអំពីអង្គហេតុដែលមិនមែនជាចំណុចវិវាទ ពោល គឺ "អង្គហេតុដែលគ្មានវិវាទ" មុននឹងការសរសេរអំពី "ចំណុចវិវាទ" (ម. ១៨៩ ក. ១ ច. ឃ នៃ ក.ន.ណ.)។ ប៉ុន្តែ នៅក្នុងលិខិតសាលក្រមនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការត្រូវតែសរសេរអំពីអង្គហេតុដែលជាចំណុចវិវាទ និង អង្គហេតុដែលមិនមែនជាចំណុចវិវាទ ហើយត្រូវតែទទួលស្គាល់នូវអង្គហេតុទាំងពីរនេះ ដោយផ្អែកតាមភស្តុតាង។ ដូច្នេះ នៅក្នុងលិខិតសាលក្រមនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការនឹងសរសេរអំពី "អង្គហេតុដែលជាមូលដ្ឋានដើម្បីពិចារណាអំពីចំណុចវិវាទ" ដោយផ្អែកតាមភស្តុតាង។

[7] ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬ មិនទទួលស្គាល់ថា ការអះអាងអំពីអង្គហេតុ មាន ឬ គ្មានភាពពិត ដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យភស្តុតាង និងដំណើរការនិងខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន (ម. ១៨៤ នៃក.ន.ណ.)



www.moj.gov.kh/kh/book-library

ខ.២.៧. នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០២០ ចុងចម្លើយបានឆ្លើយ (ឯកសារចម្លើយរបស់ចុងចម្លើយ) ថា "គ្មានមូលហេតុនៃការលែងលះគ្នាទេ" ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០២០ ចុងចម្លើយបានដកការឆ្លើយបែបនោះ និងបាននិយាយថា "ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយនឹងដើមចោទតទៅទៀតទេ"។ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ដើមចោទក៏បាននិយាយថា "ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយនឹងចុងចម្លើយដែរ"។ (អង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ[8])

## ខ.៣. ចំណុចវិវាទ និង ការអះអាងរបស់ភាគីចំពោះចំណុចវិវាទ

នៅក្នុងរឿងក្តីនេះ ដើមចោទ និងចុងចម្លើយបានលើកឡើងថា ភាគីទាំងសងខាងមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ទេ ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និង ចុងចម្លើយត្រូវបានបែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ។ ដូច្នេះ ដោយសារតែតុលាការទទួលស្គាល់អំពីមូលហេតុនៃការលែងលះដែលមានចែងនៅក្នុងមាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ង នៃក្រមរដ្ឋប្បវេណី ដូច្នេះ បណ្តឹងទាមទារលែងលះរបស់ដើមចោទ គឺមានមូលហេតុ ។

ហេតុនេះ ចំណុចវិវាទនៅក្នុងរឿងក្តីនេះ មានចំណុចដូចតទៅ :

ខ.៣.១. ការកំណត់អំពីអ្នកមានអំណាចមេបា

ខ.៣.១.១. ការអះអាងរបស់ដើមចោទ

ក្រោយពេលកើតសុជាតិ និង សុជាតា ដើមចោទបានបីបាច់រក្សារូបកាយរបស់កូននីមួយៗយ៉ាងជាប់លាប់រហូតមក។ ក្រោយពេលដែលដើមចោទបានរស់នៅបែកគ្នាជាមួយចុងចម្លើយក៏ដោយ ក៏កូនទាំងពីរនាក់នេះបានរស់នៅជាមួយគ្នានឹងដើមចោទ ហើយក៏បានធំលូតលាស់ផងដែរ។

---

[8] មាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង មាត្រា ១៣ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។ នៅក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រសិនបើជាអត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្តែងចំពោះតុលាការ នោះតុលាការមិនចាំបាច់ទទួលស្គាល់ដោយផ្អែកតាមភស្តុតាងឡើយ។

ចំណែកឯចុងចម្លើយវិញ កន្លងមកនេះបានលើកហេតុផលថា ខ្លួនរវល់ខ្លាំង ហើយមិនបានចូលរួមក្នុងការមើលថែទាំកូនទាំងពីរនាក់ ហើយក៏មិនបានបីបាច់រក្សារូបកាយរបស់កូនទាំងពីរនាក់ទាល់តែសោះ។

តុលាការសមតែកំណត់យកដើមចោទធ្វើជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់។



www.moj.gov.kh/kh/book-library

ខ.៣.១.២. ការអះអាងរបស់ចុងចម្លើយ

ដើម្បីតែការងារភាគច្រើនចុងចម្លើយបានត្រឡប់មកផ្ទះវិញយប់ជ្រៅ ប៉ុន្តែបើទោះបីជាពេលវេលាមានកម្រិតក៏ដោយ ក៏នៅក្នុងពេលវេលាទាំងនោះ ចុងចម្លើយបានផ្ដល់នូវការថែទាំទៅសុជាតិ និង សុជាតា យ៉ាងសមរម្យផងដែរ។ ការរៀបចំកាដូគ្រិស្ដម៉ាស ដែលចុងចម្លើយបានធ្វើឡើងសម្រាប់កូនទាំងពីរនាក់ ជាដើម ក៏អាចឆ្លុះបង្ហាញឱ្យឃើញពីការផ្ដល់នូវការថែរក្សានេះផងដែរ។

ចំណែកឯដើមចោទវិញ បែរជាខឹងភ្លាមៗមួយរំពេច ហើយស្រែកខ្លាំងៗ មកកាន់ចុងចម្លើយ ហើយក៏ជាមនុស្សមានសតិស្មារតីមិននឹងនរដែរ។ ដើមចោទ មិនអាចចិញ្ចឹមបីបាច់កូនទាំងពីរនាក់ឱ្យមានភាពត្រឹមត្រូវបានទេ។

តុលាការសមតែកំណត់យកចុងចម្លើយធ្វើជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់។

ខ.៣.២. បន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន)

ខ.៣.២.១. ការអះអាងរបស់ដើមចោទ

បច្ចុប្បន្ននេះ ដើមចោទមិនមានប្រាក់ចំណូលទេ រីឯចុងចម្លើយវិញមានប្រាក់ចំណូលក្នុង ១ឆ្នាំ ប្រហែល ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាម៉េរិក។

ដូច្នេះ ដើមចោទទាមទារឱ្យចុងចម្លើយទទួលបន្ទុកលើសោហ៊ុយ ដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនជាប្រាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ក្នុងកូនម្នាក់ៗ (២ នាក់ សរុបស្មើនឹង ៣០០ (បីរយ) ដុល្លារអាម៉េរិក) ជារៀងរាល់ខែ ក្នុងអំឡុងពេល គិតរហូតដល់កូនទាំងពីរនាក់ក្លាយជានីតិជន។

ខ.៣.២.២. ការអះអាងរបស់ចុងចម្លើយ

ប្រសិនបើដើមចោទជាអ្នកមានអំណាចមេបាលើសុជាតិ និង សុជាតា ហើយគ្រប់គ្រងថែរក្សាកូនទាំងពីរនាក់ នៅស្រុកកំណើតរបស់ដើមចោទ (នៅខេត្តបាត់ដំបង) នោះនឹងមានភាពខុសគ្នាពីការគ្រប់គ្រងថែរក្សាកូននៅក្នុងរាជធានីភ្នំពេញ ដូច្នេះ នឹងមិនមានការចំណាយសោហ៊ុយ ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ក្នុងកូនម្នាក់ៗ នៅក្នុង ១ ខែឡើយ ។ យ៉ាងច្រើន ចុងចម្លើយទទួលបន្ទុក ១០០ (មួយរយ) ដុល្លារអាម៉េរិក ក្នុងកូនម្នាក់ៗ នៅក្នុង ១ ខែ (២ នាក់ សរុបស្មើនឹង ២០០ (ពីររយ) ដុល្លារអាម៉េរិក សម្រាប់ដើមចោទ នោះនឹងមានភាពគ្រប់គ្រាន់ហើយ។

ខ.៣.៣. ការបង់អាហារកិច្ច

ខ.៣.៣.១. ការអះអាងរបស់ដើមចោទ

ចំពោះទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ ដើមចោទ និង ចុងចម្លើយ ដែលត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គឺមិនមែនជាកំហុសរបស់ដើមចោទទេ។ ដោយសារតែបច្ចុប្បន្ន ដើមចោទមិនមានប្រាក់ចំណូល ដូច្នេះ ទើបទាមទារឱ្យចុងចម្លើយបង់អាហារកិច្ច។ ដោយ


www.moj.gov.kh/kh/book-library

ផ្អែកលើប្រាក់ចំណូលរបស់ចុងចម្លើយ ក្នុង ១ ឆ្នាំ ប្រហែល ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាម៉េរិក និងរួមទាំងការសង្ឃឹមថា ចុងចម្លើយនឹងទទួលបន្ទុកលើសោហ៊ុយចិញ្ចឹមបីបាច់កូនសុជាតិ និង សុជាតា នោះ ចំនួនទឹកប្រាក់នៃអាហារកិច្ច ស័ក្តិសមតែកំណត់ថា ក្នុង១ខែ ចំនួន ១០០ (មួយរយ) ដុល្លារអាម៉េរិក។

ខ.៣.៣.២. ការអះអាងរបស់ចុងចម្លើយ

ចំពោះទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និង ចុងចម្លើយដែលត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គឺដើមចោទក៏មានកំហុសដែរ មិនមែនមានតែចុងចម្លើយនោះទេ។ ចុងចម្លើយទទួលយកនូវការលែងលះគ្នាពីចុងចម្លើយ ប៉ុន្តែមិនអាចទទួលយកនូវការបង់អាហារកិច្ចនោះទេ។

ខ .៣.៤. ការបែងចែកទ្រព្យសម្បត្តិ

ខ.៣.៤.១. ការអះអាងរបស់ដើមចោទ

រវាងដើមចោទ និង ចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ។ ដើមចោទមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិនោះ។

ចំពោះដី L1 និង ដី L2 ដើមចោទទាមទារឱ្យលក់ដេញថ្លៃហើយយកប្រាក់ ដែលបានពីការលក់នោះមកបែងចែក ទៅតាមចំណែក ដោយផ្អែកលើកម្មសិទ្ធិអវិភាគ ចំនួន ១ ភាគ ២ ដែលដើមចោទ និង ចុងចម្លើយម្នាក់ៗមាន។

ចំពោះម៉ូតូនៃរឿងក្តីនេះ បច្ចុប្បន្នដើមចោទកំពុងតែប្រើប្រាស់ ហើយវាក៏មានភាពចាំបាច់សម្រាប់ការទិញអីវ៉ាន់ប្រើប្រាស់ប្រចាំថ្ងៃ ដូច្នេះ ដើមចោទ ទាមទារយកមកធ្វើជាកម្មសិទ្ធិរបស់ដើមចោទ។

ខ.៣.៤.២. ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយទទួលស្គាល់ថា រវាងដើមចោទ និង ចុងចម្លើយមានទ្រព្យសម្បត្តិរួម ដូចបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ។ ដើមចោទមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិនោះ។ ប៉ុន្តែ ដីដែលបានកត់ត្រា នៅក្នុងចំណុច ១. នៃ ឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម" (តទៅហៅថា "ដី L1") និង រថយន្តដែលបានកត់ត្រា នៅក្នុងចំណុច ៣. នៃឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម" (តទៅហៅថា "រថយន្តនៃរឿងក្តីនេះ") គឺមិនមែនជាទ្រព្យសម្បត្តិរួម សម្រាប់ ធ្វើលទ្ធកម្មនោះទេ ទ្រព្យសម្បត្តិទាំងនោះគឺចុងចម្លើយមានតាំងពីមុន អាពាហ៍ពិពាហ៍ ហើយបាន និងកំពុងប្រើប្រាស់ជាទ្រព្យសម្បត្តិដោយឡែក។ នៅពេលដែលធ្វើការបែងចែកទ្រព្យសម្បត្តិរួម ដែលបានកត់ត្រា នៅក្នុងឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម" តុលាការគប្បីពិចារណា ទៅលើទំហំនៃការបរិច្ចាគរបស់ចុងចម្លើយ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិទាំងនេះ ("ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ" ម. ៩៨០ ក. ២ ច. ខ នៃ ក.រ.ណ.)។



www.moj.gov.kh/kh/book-library

ចំពោះដី L1 និង ដី L2 គឺត្រូវបានបង្កើតហ៊ីប៉ូតែក ដើម្បីធានានូវកាតព្វកិច្ចដោយសាមគ្គីភាពរវាងដើមចោទ និង ចុងចម្លើយ បន្ថែមពីនេះទៀត ដោយសារតែបច្ចុប្បន្ននេះ ដីទាំងពីរកំពុងតែបន្តឡើងថ្លៃ ហេតុនេះ មិនគួរលក់ដេញថ្លៃ នៅក្នុងពេលនេះទេ។ នាពេលបច្ចុប្បន្ននេះ រវាងដើមចោទ និងចុងចម្លើយមានចំណែកអវិភាគ ក្នុងម្នាក់ៗ ចំនួន ១ភាគ២ ដូច្នេះ ចាំពេលដែលកាតព្វកិច្ចបានសងរួចរាល់អស់ ហើយការចុះបញ្ជីបង្កើតហ៊ីប៉ូតែក ត្រូវបានលុបចោល ចាំធ្វើការពិចារណាអំពីវិធីបែងចែកទើបជាការប្រសើរ។

ចំពោះរថយន្តនៃរឿងក្តីនេះ ចុងចម្លើយកំពុងតែប្រើប្រាស់សម្រាប់ទៅធ្វើការ ដូច្នេះ ចុងចម្លើយទាមទារធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយ។

## **សំអាងហេតុ**

### **ក. ការវិនិច្ឆ័យចំពោះការកំណត់អំពីអ្នកមានអំណាចមេបា**[9]

#### **ក.១. ការទទួលស្គាល់អង្គហេតុ**

អង្គហេតុដែលតុលាការបានទទួលស្គាល់តាមរយៈភស្តុតាង ដូចបានកត់ត្រា គិតមកដល់ចំណុចចុងក្រោយខាងលើនេះ មានដូចតទៅ :

ក.១.១. ដើមចោទ និង ចុងចម្លើយបង្កើតបានកូនឈ្មោះសុជាតិនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ និង សុជាតានៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៨។ (**ភស្តុតាង** $X_3$ $X_4$)

---

[9] "អំពីមូលដ្ឋាននៃការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា"

តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើ "ផលប្រយោជន៍របស់កូន" (ម. ១០៣៧ ក. ៣ នៃក.រ.ណ.)។

នៅពេលដែលតុលាការធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន យោបល់របស់កូនត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ (ម. ២២ ក. ៤ នៃច.ន.ប.) ។

រដ្ឋភាគី ត្រូវធានាអះអាងដល់កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈទាំងនោះ ដោយសេរី លើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ។ ទស្សនៈទាំងនេះរបស់កុមារ ត្រូវបានយកទៅពិចារណាថ្លឹងថ្លែង ដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ ។ ក្នុងទិសដៅនេះ កុមារត្រូវបានផ្តល់ជាពិសេសនូវឱកាសស្តាប់ នីតិវិធីតុលាការ និង រដ្ឋបាល ដែលពាក់ព័ន្ធនឹងកុមារ ទោះដោយផ្ទាល់ ឬ តាមរយៈតំណាងម្នាក់ ឬ ស្ថាប័នសមស្របមួយ ស្របតាមបទប្បញ្ញត្តិនីតិវិធីនៃច្បាប់ជាតិ ។ (មាត្រា ១២ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ) ។ បន្ថែមពីនេះ ប្រទេសកម្ពុជាបានចូលជាភាគីនៃអនុសញ្ញានេះកាលពីឆ្នាំ ១៩៩២។

"ផលប្រយោជន៍របស់កូន" អាចគិតទៅដល់ ស្ថានភាពរបស់ខាងឪពុក ឬ ម្តាយ ស្ថានភាពរបស់កូន ។ ស្ថានភាពរបស់ឪពុក ឬ ម្តាយ អាចមានដូចជា លទ្ធភាពក្នុងការគ្រប់គ្រងកូន (អាយុ និង ស្ថានភាពសុខភាព ជាដើម) ស្ថានភាពសេដ្ឋកិច្ច (ប្រាក់ចំណូលប្រចាំឆ្នាំ មុខរបរ មាន ឬ គ្មានលំនៅឋាន ជាដើម) និងស្ថានភាពនៃការគ្រប់គ្រងកូន មាន ឬ គ្មានជំនួយពីសាច់ញាតិ ការផ្តល់ក្តីស្រលាញ់ចំពោះកូន ជាអាទិ៍ ដែលធ្លាប់មានកន្លងមក។ ស្ថានភាពរបស់កូន អាចមានដូចជា អាយុ ស្ថានភាពនៃការលូតលាស់រាងកាយ និង ចិត្តគំនិត ឆន្ទៈរបស់កូន ភាពស្អិតរមួតនៃចំណងរវាងឪពុក ឬម្តាយ និងសាច់ញាតិ ជាដើម។



www.moj.gov.kh/kh/book-library

ក.១.២. នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២០ ដើមចោទបាននាំសុជាតិ និង សុជាតា ត្រឡប់ទៅស្រុកកំណើតវិញ ហើយកំពុងតែស្នាក់នៅស្រុកកំណើតរួមគ្នាជាមួយនឹងឪពុកម្ដាយរបស់ដើមចោទរហូតមកដល់បច្ចុប្បន្ននេះ។ (**ភស្តុតាង** $X_6$)

ក.១.៣. ក្នុងអំឡុងពេលដែលគិតមកដល់ពេលដើមចោទបានចាប់ផ្ដើមរស់នៅបែកគ្នាជាមួយចុងចម្លើយ ដើមចោទបានបន្តនូវការគ្រប់គ្រងសុជាតិ និង សុជាតាតែម្នាក់ឯង រួមទាំងពេលដែលចុងចម្លើយបានត្រឡប់មកផ្ទះវិញយប់ជ្រៅក៏ដោយ។ (**ភស្តុតាង** $X_5$ $Y_1$ ដំណើរការ និង ខ្លឹមសារ នៃការទាញហេតុផលដោយផ្ទាល់មាត់) ជា អាយុ ស្ថានភាពនៃការលូតលាស់រាងកាយ និង ចិត្តគំនិត ឆន្ទៈរបស់កូន ភាពស្និតរមួតនៃចំណងរវាងឪពុក ឬម្ដាយ និងសាច់ញាតិ ជាដើម។

ក.១.៤. ដោយសារតែដើមចោទមិនអាចទទួលបាននូវការចូលរួមសហការ ចំពោះការមើលថែទាំកូនពីចុងចម្លើយ ដូច្នេះ ក៏ធ្លាប់បានធ្វើឱ្យមានការធ្វេសប្រហែសចំពោះការងារផ្ទះ និងធ្វើឱ្យមានជម្លោះពាក្យសំដីជាមួយចុងចម្លើយ ជាពិសេសគិតចាប់តាំងពីពេលដែលសុជាតាបានកើត។ (**ភស្តុតាង** $X_5$ $Y_1$ លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយ នីមួយៗ)

ក.១.៥. ..........................................................................................................................

ក.១.៦. ..........................................................................................................................

(សង្ខេប)

** នៅក្នុងរឿងក្ដីជាក់ស្ដែង គូភាគីទាំងសងខាងច្បាស់ជាមានការអះអាង យ៉ាងក្បោះក្បាយ អំពីមូលហេតុដែលស័ក្តិសមឱ្យខ្លួនអាចក្លាយទៅជាអ្នកមានអំណាចមេបា។*

*ក្នុងករណីដែលភាគីគ្រាន់តែអះអាងខ្លីៗ ដោយមូលហេតុបែបអត្តនោម័តថា ព្រោះតែខ្លួនស្រលាញ់កូននោះ តុលាការចាំបាច់ត្រូវប្រើប្រាស់សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍ ហើយឱ្យភាគីអះអាង អំពីមូលហេតុបែបសត្យានុម័ត ថា "តើហេតុអ្វីបានជាទាល់តែមានការមើលថែទាំកូនពីភាគីនោះ ទើបអាចមានលក្ខណៈវិជ្ជមាន សម្រាប់កូនជាងគេ? ហេតុអ្វីបានជាភាគីម្ខាងទៀតមិនអាចធ្វើបាន?"*

*តុលាការចាំបាច់ត្រូវកំណត់អំពីអ្នកមានអំណាចមេបា ដោយពិចារណាអំពីស្ថានភាពផ្សេងៗ ជាច្រើនដែលភាគីទាំងសងខាងបានអះអាង ហើយត្រូវគិតថា តើកំណត់យកឪពុក ឬ ម្ដាយ ធ្វើជាអ្នកមានអំណាចមេបា ទើបអាចផ្ដល់ "ផលប្រយោជន៍ដល់កូន"។*

*ហើយ តុលាការត្រូវសរសេរ អំពីអង្គហេតុដំបូងដើម្បីយកមកធ្វើការសម្រេចបែបនោះ និងភស្តុតាង ដាក់នៅក្នុងចំណុចចំហទាំងនេះ។*

**ក.២. សេចក្ដីសន្និដ្ឋាន**

ផ្អែកតាមការសរុបនូវអង្គហេតុដែលបានទទួលស្គាល់ នៅក្នុងចំណុច "ក.១" ខាងលើ តុលាការទទួលស្គាល់ថា ក្រោយពេលដែលសុជាតិ និងសុជាតាកើតមក ដើមចោទបានគ្រប់គ្រងកូនទាំងពីរនាក់រៀងរហូតមក ហើយក៏បានបន្តនូវ



www.moj.gov.kh/kh/book-library

ការគ្រប់គ្រងនោះផងដែរ បើទោះបីជាក្រោយពេលដែលបានរស់នៅបែកគ្នាជាមួយនឹងចុងចម្លើយក៏ដោយ។ ម្យ៉ាងទៀត តុលាការមិនទទួលស្គាល់ថា ស្ថានភាពនៃការគ្រប់គ្រងរបស់ដើមចោទទៅកាន់កូនទាំងពីរនាក់នេះ មិនមានបញ្ហាជាក់លាក់ណាមួយឡើយ។

យ៉ាងណាមិញ ចុងចម្លើយបានអះអាងថាដើមចោទបានខឹងភ្លាមៗ ហើយស្រែកខ្លាំងៗទៅកាន់ចុងចម្លើយ ហើយជាមនុស្សដែលមានសតិមិននឹងនរ ដូច្នេះទើបដើមចោទមិនអាចចិញ្ចឹមបីបាច់កូនទាំងពីរនាក់ឱ្យបានត្រឹមត្រូវទេ។ ជាការពិតណាស់ តុលាការទទួលស្គាល់ថា ដើមចោទធ្លាប់មានជម្លោះពាក្យសំដីជាមួយចុងចម្លើយ។ ប៉ុន្តែ តុលាការក៏មិនអាចទទួលស្គាល់រហូតទៅដល់អង្គហេតុដែលដើមចោទអាចខឹង ហើយស្រែកដាក់សុជាតិ និងសុជាតា នោះទេ ដូច្នេះ តុលាការមិនអាចទទួលស្គាល់ថា ជម្លោះពាក្យសំដីរវាងចុងចម្លើយគឺបានកើតឡើង ដោយសារតែដើមចោទមានស្មារតីមិននឹងនរហើយមូលហេតុនោះដោយសារតែដើមចោទមិនទទួលបានការសហការឱ្យបានពេញលេញពីចុងចម្លើយឡើយ។

ផ្ទុយមកវិញ ទោះជាយ៉ាងណាក៏ដោយ ក៏ចុងចម្លើយមានការស្រលាញ់ចំពោះកូនទាំងពីរនាក់ ប៉ុន្តែ ចុងចម្លើយមិនបង្ហាញឱ្យបានច្បាស់ថា តើខ្លួនចង់គ្រប់គ្រងថែរក្សាកូន ទាំងពីរនាក់នេះ ជាក់ស្តែង ដោយរបៀបណានោះទេ ខណៈពេលដែលភាគច្រើន ខ្លួនបានត្រឡប់មកផ្ទះវិញយប់ជ្រៅដោយសារតែការងារ។

ដូច្នេះ ផ្អែកតាមស្ថានភាពដែលដើមចោទកំពុងតែគ្រប់គ្រងកូនទាំងពីរនាក់នៅពេលបច្ចុប្បន្ននេះ គឺពុំមានបញ្ហាជាពិសេសណាមួយទេ ម្យ៉ាងទៀត ក៏មិនអាចនិយាយបានថា បើធ្វើការផ្លាស់ប្តូរស្ថានភាពនៃការគ្រប់គ្រងកូន ហើយកំណត់មកឱ្យចុងចម្លើយជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់វិញ នឹងអាចធ្វើឱ្យក្លាយទៅជាប្រយោជន៍ដល់កូនទាំងពីរនាក់នោះបានដែរ ដូច្នេះ គប្បីកំណត់យកដើមចោទធ្វើជាអ្នកមានអំណាចមេបា ទើបជាការប្រសើរ។

## ខ. ការវិនិច្ឆ័យចំពោះបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន)

### ខ.១. ការទទួលស្គាល់អង្គហេតុ

អង្គហេតុដែលតុលាការបានទទួលស្គាល់តាមរយៈ ភស្តុតាងដូចបានកត់ត្រា គិតមកដល់ចំណុចចុងក្រោយខាងលើនេះ មានដូចតទៅ :

ខ.១.១. បច្ចុប្បន្ននេះ ដើមចោទគ្មានប្រាក់ចំណូល ។ (លទ្ធផលនៃការសាកសួរ សាមីដើមចោទ)

ខ.១.២. ចុងចម្លើយកំពុងធ្វើការជាបុគ្គលិកក្រុមហ៊ុន ហើយមានប្រាក់ចំណូល ក្នុង ១ឆ្នាំ ប្រហែល ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។ (លទ្ធផលនៃការសាកសួរសាមីចុងចម្លើយ)

ខ.១.៣. ចុងចម្លើយត្រូវបង់ពន្ធប្រហែល ........... ដុល្លារអាមេរិក ហើយបង់ថ្លៃឈ្នួលផ្ទះប្រហែល ............... ដុល្លារអាមេរិក ពីប្រាក់ចំណូល ដែលបានកត់ត្រា នៅក្នុងចំណុច "ខ.១.២" ខាងលើនេះ ។ (លទ្ធផលនៃការសាកសួរសាមីចុងចម្លើយ)

ខ.១.៤. កាលពីអំឡុងពេលដែលរស់នៅជុំគ្នាជាមួយសុជាតិ និងសុជាតា នៅក្នុងលំនៅឋានរបស់ចុងចម្លើយ ចុងចម្លើយបានចំណាយសម្រាប់ថ្លៃជីវភាពរបស់កូនទាំងពីរនាក់ ចំនួន ៣.០០០ (បីពាន់) ដុល្លារ


www.moj.gov.kh/kh/book-library

អាម៉េរិក (ក្នុង ១ ខែ ប្រហែល ២៥០ (ពីររយហាសិប) ដុល្លារអាម៉េរិក) ពីចំនួនទឹកប្រាក់........ ដុល្លារអាម៉េរិក ដែលបាននៅសល់បន្ទាប់ពីដកថ្លៃចំណាយក្នុងចំណុច ខ.១.៣" ពីក្នុងប្រាក់ចំណូល នៃចំណុច "ខ.១.២" ខាងលើ ។ (លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយ)

ខ.១.៥. បច្ចុប្បន្ននេះ ដើមចោទកំពុងតែគ្រប់គ្រងសុជាតិ និង សុជាតា នៅស្រុកកំណើតរបស់ដើមចោទ (ខេត្ត បាត់ដំបង)។ (ភស្តុតាង $X_6$)

ខ.១.៦. ថ្លៃចំណាយសម្រាប់ជីវភាពនៅក្នុងខេត្តបាត់ដំបង ប្រហែលជាស្មើនឹង ៨០% នៃថ្លៃចំណាយសម្រាប់ ជីវភាពនៅក្នុងរាជធានីភ្នំពេញ។ (អង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ)

ខ.១.៧.........................................................................................................................

(សង្ខេប)

*ចំនួនទឹកប្រាក់នៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) ដំបូង ① ត្រូវកំណត់ ជាបណ្តោះអាសន្នថា ហើយធ្វើការគណនាថា បើសិនជាកូនរស់នៅជុំគ្នាជាមួយអ្នកដែលទទួលបន្ទុក (ឪពុក ឬ ម្តាយ ដែលមិនមែនជាអ្នកមានអំណាចមេបា) តើចំណាយសម្រាប់ជីវភាព ដែលត្រូវបានប្រើប្រាស់សម្រាប់កូន នៅក្នុងករណី នេះអស់ចំនួនប៉ុន្មាន ? យកចំនួន ដែលបានគណនានេះ មកបែងចែកទៅតាមភាគរយនៃប្រាក់ចំណូលរបស់អ្នកទទួល បន្ទុក (ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបា) និង អ្នកដែលទាមទារ (ឪពុក ឬ ម្តាយដែលជាអ្នកមាន អំណាចមេបា)។ នៅពេលនោះ ចំនួនទឹកប្រាក់ដែលបានមកពីការគណនា ធៀបទៅនឹងភាគរយនៃប្រាក់ចំណូលរបស់ អ្នកទទួលបន្ទុក នឹងក្លាយទៅជាសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) ដែលអ្នក ទទួលបន្ទុកនោះត្រូវទទួលបន្ទុក។

### ខ.២. សេចក្តីសន្និដ្ឋាន

តុលាការទទួលស្គាល់ថា ផ្អែកតាមខាងលើនេះ ប្រសិនបើកំណត់ជាបណ្តោះអាសន្នសិនថា បើចុងចម្លើយរស់ជុំ គ្នា នៅឯខេត្តបាត់ដំបងជាមួយនឹងសុជាតិ និង សុជាតា ចុងចម្លើយនឹងត្រូវចំណាយនូវថ្លៃជីវភាពចំនួនប្រហែល ២០០ (ពីររយ) ដុល្លារអាម៉េរិក ក្នុង ១ ខែ សម្រាប់កូនទាំងពីរ (៨០% នៃចំនួន ២៥០ (ពីររយហាសិប ដុល្លារអាម៉េរិក) ។ ដូច្នេះ ចុងចម្លើយត្រូវទទួលបន្ទុកនូវប្រាក់ចំនួន ១០០ (មួយរយ) ដុល្លារអាម៉េរិកក្នុង ១ខែ ចំពោះកូនម្នាក់ ដែលជាសោហ៊ុយ ដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទាំងពីរនាក់ (សោហ៊ុយចិញ្ចឹមបីបាច់កូន) ក្នុងអំឡុងពេល រហូតដល់កូនទាំងពីរ នាក់ក្លាយជានីតិជន ។

## គ. ការវិនិច្ឆ័យចំពោះការបង់អាហារកិច្ច

### គ.១. ការទទួលស្គាល់អង្គហេតុ

គ.១.១. នៅក្នុងកាលបរិច្ឆេទនៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ២ ចុងចម្លើយបាននិយាយ ថា "មិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយដើមចោទ តទៅទៀតទេ" ហើយនៅកាលបរិច្ឆេទដដែល



www.moj.gov.kh/kh/book-library

នោះ ដើមចោទក៏បាននិយាយដែរថា "មិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយតទៅទៀតទេ"។ (អង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ)

គ.១.២. ចាប់តាំងពីក្រោយពេលដែលចុងចម្លើយបានរួមរស់ជីវភាពរួមគ្នាជាមួយដើមចោទ ភាគច្រើនចុងចម្លើយបានត្រឡប់មកផ្ទះវិញយប់ជ្រៅ ហើយជាពិសេស នៅក្រោយពេលដែលបានកើតសុជាតា រួចមក ចុងចម្លើយធ្លាប់មានជម្លោះពាក្យសំដីជាមួយនឹងដើមចោទ ជុំវិញការមើលថែទាំកូន។ (**ភស្តុតាង X5 ភស្តុតាង** Y, លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)។

### គ.២. សេចក្តីសន្និដ្ឋាន

ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គឺដោយសារតែភាគីទាំងសងខាងដែលជាដើមចោទ និងចុងចម្លើយមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍។ មិនតែប៉ុណ្ណោះ ភាគីទាំងសងខាងមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ គឺដោយសារតែភាគីទាំងសងខាងមិនបានទាក់ទងនិយាយគ្នា ឱ្យបានគ្រប់គ្រាន់តែប៉ុណ្ណោះទេ ថែមទាំងបណ្តាលមកពីលទ្ធផលដែលដើមចោទមិនពេញចិត្តចំពោះចុងចម្លើយផងដែរ ដូច្នេះ គឺមិនអាចនិយាយបានថា ភាគីណាម្ខាងមានកំហុសតែម្នាក់ឯងបានទេ។

ហេតុនេះ ដោយសារតែមិនអាចនិយាយឱ្យដាច់ស្រេចថា ដើមចោទមិនមានកំហុសចំពោះការលែងលះទេ ដូច្នេះ តុលាការមិនអាចទទួលស្គាល់អំពីអាហារកិច្ច ដែលដើមចោទទាមទារទៅកាន់ចុងចម្លើយទេ។

## ឃ. ការវិនិច្ឆ័យចំពោះការបែងចែកទ្រព្យសម្បត្តិ

### ឃ.១. ការទទួលស្គាល់អង្គហេតុ

ឃ.១.១. រវាងដើមចោទ និង ចុងចម្លើយ មានទ្រព្យសម្បត្តិរួម ដែលបានកត់ត្រានៅក្នុងឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម"។ ម្យ៉ាងវិញទៀត ចំនួនទឹកប្រាក់នៃការវាយតម្លៃដែលបានធ្វើឡើងនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ អំពីទ្រព្យសម្បត្តិរួមនីមួយៗ មានដូចតទៅ (ភស្តុតាង $X_7$ $X_8$ $X_9$ $X_{10}$ $Y_2$ លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់) :

| | |
|---|---|
| ដី L1 | ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក |
| ដី L2 | ១០.០០០ (មួយម៉ឺន) ដុល្លារអាម៉េរិក |
| រថយន្តនៃរឿងក្តីនេះ | ១០.០០០ (មួយម៉ឺន) ដុល្លារអាម៉េរិក |
| ម៉ូតូនៃរឿងក្តីនេះ | ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាម៉េរិក |
| ប្រាក់សន្សំនៃរឿងក្តីនេះ | ៤០០ (បួនរយ) ដុល្លារអាម៉េរិក |

យ៉ាងណាមិញ ចំពោះប្រាក់សន្សំនៃរឿងក្តីនេះ នៅពេលដែលដើមចោទ និង ចុងចម្លើយបានចាប់ផ្តើមរស់នៅបែកគ្នា (ថ្ងៃទី៤ ខែមករា ឆ្នាំ២០២០) នៅសល់ ៥០០ (ប្រាំរយ) ដុល្លារអាម៉េរិក ប៉ុន្តែ



www.moj.gov.kh/kh/book-library

ដោយសារតែចុងចម្លើយបានដកប្រាក់សន្សំអស់មួយផ្នែក ដូច្នេះចំនួនទឹកប្រាក់ដែលនៅសល់នៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់មានចំនួន ៤០០ (បួនរយ) ដុល្លារអាម៉េរិក។

ឃ.១.២. ចំពោះដី L1 ដើមចោទ និងចុងចម្លើយបានទិញ នៅក្នុងតម្លៃទិញចូល ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាម៉េរិក នៅក្នុងនោះមានប្រាក់ ១.០០០ (មួយពាន់) ដុល្លារអាម៉េរិក (២០% នៃតម្លៃទិញចូល) ដែលបានដកចេញពីប្រាក់សន្សំ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ ហើយចំពោះប្រាក់ដែលខ្វះ ៤.០០០ (បួនពាន់) ដុល្លារអាម៉េរិក ដើមចោទ និង ចុងចម្លើយបានធ្វើកម្ចីរួមគ្នាដោយសាមគ្គីភាព។ ដី L1 ត្រូវបានបង្កើតហ៊ីប៉ូតែកដើម្បីកម្ចីនេះ ។ (លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)។

ឃ.១.៣. ចំពោះដី L2 ដើមចោទ និង ចុងចម្លើយបានទិញ នៅក្នុងតម្លៃទិញចូល ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាម៉េរិក នៅក្នុងនោះមានប្រាក់ដែលបានដកចេញពីប្រាក់សន្សំ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ និង ចុងចម្លើយ ក្នុងម្នាក់ៗ ចំនួន ៨០០ (ប្រាំបីរយ) ដុល្លារអាម៉េរិក (ម្នាក់ ១០% នៃតម្លៃទិញចូល) ហើយចំពោះប្រាក់ដែលខ្វះ ៦.៤០០ (ប្រាំមួយពាន់បួនរយ) ដុល្លារអាម៉េរិក ដើមចោទ និង ចុងចម្លើយបានធ្វើកម្ចីរួមគ្នាដោយសាមគ្គីភាព។ ដី L2 ត្រូវបានបង្កើតហ៊ីប៉ូតែកដើម្បីកម្ចីនេះ ។ (លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)

ឃ.១.៤. ចំពោះរថយន្តនៃរឿងក្តីនេះ ដើមចោទ និង ចុងចម្លើយបានទិញនៅក្នុងតម្លៃ ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាម៉េរិក នៅក្នុងនោះមានប្រាក់ចំនួន ៩.០០០ (ប្រាំបួនពាន់) ដុល្លារអាម៉េរិក (៦០% នៃតម្លៃទិញចូល) គឺជាតម្លៃតបដែលទទួលបាន ពីការលក់រថយន្តដែលទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ ហើយ ចំពោះប្រាក់ដែលខ្វះចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក ដើមចោទ និង ចុងចម្លើយបានដកចេញពីប្រាក់សន្សំ ដែលជាទ្រព្យសម្បត្តិរួម។ រថយន្តនៃរឿងក្តីនេះ ចុងចម្លើយកំពុងតែប្រើប្រាស់។ (លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)។

ឃ.១.៥. ចំពោះម៉ូតូនៃរឿងក្តីនេះ ដើមចោទ និង ចុងចម្លើយបានទិញ នៅក្នុងតម្លៃ ២.០០០ (ពីរពាន់) ដុល្លារអាម៉េរិក នៅក្នុងនោះមានប្រាក់ចំនួន ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាម៉េរិក (៧៥% នៃតម្លៃទិញចូល) គឺជាតម្លៃតបដែលទទួលបានពីការលក់ម៉ូតូ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ហើយចំពោះប្រាក់ដែលនៅខ្វះចំនួន ៥០០ (ប្រាំរយ) ដុល្លារអាម៉េរិក ដើមចោទ និង ចុងចម្លើយបានដកចេញពីប្រាក់សន្សំ ដែលជាទ្រព្យសម្បត្តិរួម។ ម៉ូតូនៃរឿងក្តីនេះ ដើមចោទកំពុងតែប្រើប្រាស់។ (លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)។



www.moj.gov.kh/kh/book-library

## ឃ.២. ការវិនិច្ឆ័យ

ឃ.២.១. អំពីទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ជាគោលការណ៍នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម (មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី) ហើយនៅក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម (មាត្រា ៩៨០ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមរដ្ឋប្បវេណី)។ ការណ៍ដែលលើកឡើងបែបនេះ គឺដោយសារតែប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នា ទៅវិញទៅមក (មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី) ហេតុនេះ គឺអាចមានការយល់ឃើញថា ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានតាមរយៈការសហការគ្នារវាងប្តីប្រពន្ធ ដូច្នេះ នៅពេលដែលប្តីប្រពន្ធលែងលះគ្នា ក៏គប្បីយកទ្រព្យសម្បត្តិនេះ មកជម្រះបញ្ជីផងដែរ។ ដូច្នេះ បើទោះបីជានៅមុនពេលដែលលែងលះគ្នាក៏ដោយ ក្នុង ករណីដែលប្តីប្រពន្ធមិនបានរួមរស់ជីវភាពជាមួយគ្នាបាត់ទៅហើយ ពោលគឺ បានរស់នៅបែកគ្នារួចហើយនោះ ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាននៅក្នុងអំឡុងពេលរស់នៅបែកគ្នា គឺមិនអាចនិយាយថា ជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាន តាមរយៈការសហការគ្នារវាងប្តីប្រពន្ធបានទេ ដូច្នេះ ទ្រព្យសម្បត្តិទាំងនោះ មិនគប្បីយកមកធ្វើជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិទេ។ ម្យ៉ាងទៀតជាមួយគ្នានេះ ទោះបីជាក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាងបានប្រើប្រាស់ទ្រព្យសម្បត្តិរួមសម្រាប់ជីវភាពរបស់ខ្លួន នៅក្រោយពេលដែលបានរស់នៅបែកគ្នាក៏ដោយ ក៏មិនអាចនិយាយបានថា ករណីនោះ គឺជាការយកមកប្រើប្រាស់សម្រាប់ការរួមរស់ជីវភាពជាមួយគ្នា របស់ប្តីប្រពន្ធបានដែរ ហេតុដូច្នេះ ទើបចាំបាច់ត្រូវយកទ្រព្យសម្បត្តិនៅមុនពេលដែលត្រូវបានប្តី និង ប្រពន្ធប្រើប្រាស់សម្រាប់ជីវភាព មកធ្វើជាមូលដ្ឋាននៃការបែងចែកទ្រព្យសម្បត្តិ។ ជាពិសេស ទ្រព្យសម្បត្តិរួមដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គួរតែជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាន គិតចាប់ពីពេលរៀបអាពាហ៍ពិពាហ៍ រហូតដល់ពេលដែលរស់នៅបែកគ្នា។

នៅក្នុងរឿងក្តីនេះ នៅមុនពេលនៃការរស់នៅបែកគ្នា ប្រាក់សន្សំនៃរឿងក្តីនេះបាននៅសល់ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាម៉េរិក ប៉ុន្តែ ក្រោយមក ដោយសារតែចុងចម្លើយបានដកយកប្រាក់សន្សំមួយផ្នែក ទើបធ្វើឱ្យចំនួនទឹកប្រាក់ដែលនៅសល់ នៅពេលដែលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ មានចំនួន ៤០០ (បួនរយ) ដុល្លារអាម៉េរិក ហេតុនេះនៅពេលដែលធ្វើការបែងចែកទ្រព្យសម្បត្តិរវាងដើមចោទ និង ចុងចម្លើយ គប្បីយកចំនួនទឹកប្រាក់ ៥០០ (ប្រាំរយ) ដុល្លារអាម៉េរិក ដែលបាននៅសល់ នៅពេលដែលរស់នៅបែកគ្នាដំបូង មកធ្វើជាមូលដ្ឋាន។

ឃ.២.២. អំពីតម្លៃនៃទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ



www.moj.gov.kh/kh/book-library

ជាបឋម ចំពោះដី L1 មានការវាយតម្លៃជាទឹកប្រាក់ស្មើនឹង ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក ដែលក្នុងនោះមានចំណែក ២០% ដែលស្មើនឹងទឹកប្រាក់ចំនួន ១.២០០ (មួយពាន់ពីររយ) ដុល្លារអាម៉េរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយឡែក របស់ចុងចម្លើយមកធ្វើជាដើមទុន។ ដូច្នេះ ចំនួននៃផ្នែកនេះគប្បីក្លាយទៅជារបស់ចុងចម្លើយវិញ ហើយផ្នែកដែលនៅសល់ចំនួន ៤.៨០០ (បួនពាន់ប្រាំបីរយ) ដុល្លារអាម៉េរិក គប្បីក្លាយទៅជាកម្មវត្ថុនៃការបែងចែក។

ជាបន្តទៀត ចំពោះដី L2 មានការវាយតម្លៃជាទឹកប្រាក់ស្មើនឹងចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាម៉េរិក ដែលក្នុងនោះមានចំណែក ១០% ដែលស្មើនឹង ១.០០០ (មួយពាន់) ដុល្លារអាម៉េរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ និង ចំណែក ១០% ដែលស្មើនឹង ១.០០០ (មួយពាន់) ដុល្លារអាម៉េរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ មកធ្វើជាដើមទុន ។ ដូច្នេះ ចំនួននៃផ្នែកនេះគប្បីក្លាយទៅជារបស់ដើមចោទ និង ចុងចម្លើយនីមួយៗវិញ ហើយផ្នែកដែលនៅសល់ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាម៉េរិក គប្បីក្លាយទៅជាកម្មវត្ថុនៃការបែងចែក។

ចំពោះរថយន្តនៃរឿងក្តីនេះ មានការវាយតម្លៃជាទឹកប្រាក់ស្មើនឹង ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាម៉េរិក ដែលក្នុងនោះមានចំណែក ៦០% ដែលស្មើនឹង ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិ ដោយឡែករបស់ចុងចម្លើយមកធ្វើជាដើមទុន។ ដូច្នេះ ចំនួននៃផ្នែកនេះគប្បីក្លាយទៅជារបស់ចុងចម្លើយវិញ ហើយផ្នែកដែលនៅសល់ចំនួន ៤.០០០ (បួនពាន់) ដុល្លារអាម៉េរិក គប្បីក្លាយទៅជាកម្មវត្ថុនៃការបែងចែក។

ចំពោះម៉ូតូនៃរឿងក្តីនេះ មានការវាយតម្លៃជាទឹកប្រាក់ចំនួន ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាម៉េរិក ដែលក្នុងនោះមានចំណែក ៧៥% ដែលស្មើនឹង ១.១២៥ (មួយពាន់មួយរយម្ភៃប្រាំ) ដុល្លារអាម៉េរិក គឺជាដើមទុនដែលបានយកមកពីទ្រព្យសម្បត្តិដោយឡែក របស់ដើមចោទ ។ ដូច្នេះ ផ្នែកនៃទឹកប្រាក់នេះ គួរតែជារបស់ដើមចោទវិញ ហើយទឹកប្រាក់ដែលនៅសល់ចំនួន ៣៧៥ (បីរយចិតសិបប្រាំ) ដុល្លារអាម៉េរិក គួរតែយកទៅធ្វើជាកម្មវត្ថុនៃការបែងចែក។

ហេតុដូច្នេះ តម្លៃរបស់ទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក មានសរុបចំនួន ១៧.៦៧៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំមួយរយចិតសិបប្រាំ) ដុល្លារអាម៉េរិក (៤.៨០០ (បួនពាន់ប្រាំបីរយ) "ដី L1" + ៨.០០០ (ប្រាំបីពាន់) "ដី L2" + ៤.០០០ (បួនពាន់) "រថយន្តនៃរឿងក្តីនេះ" + ៣៧៥ (បីរយចិតសិបប្រាំ) "ម៉ូតូនៃរឿងក្តីនេះ" + ៥០០ (ប្រាំរយ) "ប្រាក់សន្សំនៃរឿងក្តីនេះ" - ១៧.៦៧៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំមួយរយចិតសិបប្រាំ)។

នៅពេលដែលយកចំនួនទឹកប្រាក់ខាងលើនេះ មកបែងចែកឱ្យដើមចោទ និងចុងចម្លើយក្នុងម្នាក់ៗ ១ភាគ២ ដូច្នេះនាំឱ្យដើមចោទ និងចុងចម្លើយ ក្នុងម្នាក់ៗ មានសិទ្ធិទទួលបានចំនួនទឹកប្រាក់ ៨.៨៣៧,៥ (ប្រាំបីពាន់ប្រាំបីរយសាមសិបប្រាំពីរ ក្បៀសប្រាំ) ដុល្លារអាម៉េរិក។



www.moj.gov.kh/kh/book-library

ឃ.២.៣. អំពីវិធីនៃការបែងចែកទ្រព្យសម្បត្តិ

ជាបឋម បើមើលទៅលើការបង្កើតហ៊ីប៉ូតែកចំពោះដី L1 និង ដី L2 ដើម្បីធានានូវកាតព្វកិច្ចដោយសាមគ្គីភាពរបស់ដើមចោទ និង ចុងចម្លើយ គឺដីទាំងនេះមិនស័ក្តិសមយកមកធ្វើជាកម្មសិទ្ធិរបស់ដើមចោទ ឬ ចុងចម្លើយតែម្នាក់ឯងទេ ដូច្នេះ ដើមចោទ និង ចុងចម្លើយស័ក្តិសមតែមានកម្មសិទ្ធិអវិភាគក្នុងម្នាក់ៗចំនួន ១ ភាគ ២ ទៅលើដីទាំងនេះ។ ម្យ៉ាងទៀត តុលាការមិនទទួលស្គាល់ថា ក្នុងពេលបច្ចុប្បន្ននេះ គឺមានភាពចាំបាច់ ដែលត្រូវយកដីទាំងនេះមកលក់ដោយបង្ខំភ្លាមៗទេ។ ដូច្នេះ ចំពោះដី L1 នៅក្នុងចំណែកចំនួន ៤.៨០០ (បួនពាន់ប្រាំបីរយ) ដុល្លារអាម៉េរិក ដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក នៅក្នុងនោះគឺដើមចោទគប្បីទទួលបានចំណែកចំនួន ៣.០០០ (បីពាន់) ដុល្លារអាម៉េរិក ហើយចុងចម្លើយគប្បីទទួលបានចំណែកចំនួន ១.៨០០ (មួយពាន់ប្រាំបីរយ) ដុល្លារអាម៉េរិក (បើបូកទាំងតម្លៃនៃចំនួន ១.២០០ (មួយពាន់ពីររយ) ដុល្លារអាម៉េរិក ដែលយកទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយមកធ្វើជាដើមទុន ចំណែកដែលនឹងទទួលបានមានចំនួន ៣០០០ (បីពាន់) ដុល្លារអាម៉េរិក)។ ចំពោះដី L2 នៅក្នុងចំណែកចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាម៉េរិក ដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក នៅក្នុងនោះ គឺដើមចោទ និង ចុងចម្លើយគប្បីទទួលបានចំណែករៀងៗខ្លួន ចំនួន ៤.០០០ (បួនពាន់) ដុល្លារអាម៉េរិក។

ចំពោះរថយន្តនៃរឿងក្តីនេះ គប្បីយកទៅធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយ ដូច្នេះ ចំណែកទាំងអស់សរុបចំនួន ៤.០០០ (បួនពាន់) ដុល្លារអាម៉េរិក ដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គប្បីចុងចម្លើយជាអ្នកទទួលយក។ ចំពោះម៉ូតូនៃរឿងក្តីនេះ គប្បីយកទៅធ្វើជាកម្មសិទ្ធិរបស់ដើមចោទ ដូច្នេះ ចំណែកទាំងអស់សរុបចំនួន ៣៧៥ (បីរយចិតសិបប្រាំ) ដុល្លារអាម៉េរិក ដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គប្បីដើមចោទជាអ្នកទទួលយក។ ចំពោះប្រាក់សន្សំនៃរឿងក្តីនេះ គប្បីយកទៅធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយ ដោយសារតែចុងចម្លើយជាម្ចាស់ឈ្មោះគណនី។ ដូច្នេះ ចំណែកទាំងអស់សរុបចំនួន ៥០០ (ប្រាំរយ) ដុល្លារអាម៉េរិក ដែលត្រូវក្លាយជាកម្មវត្ថុនៃ ការបែងចែក គប្បីចុងចម្លើយជាអ្នកទទួលយក។

ហេតុដូច្នេះ ចំពោះតម្លៃរបស់ទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកមានសរុបចំនួន ១៧.៦៧៥ (មួយម៉ឺនប្រាំពីរពាន់ប្រាំមួយរយចិតសិបប្រាំ) ដុល្លារអាម៉េរិក ក្នុងនោះ ដើមចោទនឹងត្រូវទទួលបានចំនួន ៧.៣៧៥ (ប្រាំពីរពាន់បីរយចិតសិបប្រាំ) ដុល្លារអាម៉េរិក (៣.០០០ (បីពាន់) "ដីL1" + ៤.០០០ (បួនពាន់) "ដីL2" + ៣៧៥ (បីរយចិតសិបប្រាំ) "ម៉ូតូនៃរឿងក្តីនេះ" = ៧.៣៧៥ (ប្រាំពីរពាន់បីរយចិតសិបប្រាំ)) ហើយចុងចម្លើយទទួលបាន ១០.៣០០ (មួយម៉ឺនបីរយ) ដុល្លារអាម៉េរិក (១.៨០០ (មួយពាន់ប្រាំបីរយ) "ដី L1" + ៤.០០០ (បួនពាន់) "ដីL2" + ៤.០០០ (បួនពាន់) "រថយន្តនៃរឿងក្តីនេះ" + ៥០០ (ប្រាំរយ) "ប្រាក់សន្សំនៃរឿងក្តីនេះ" = ១០.៣០០ (មួយម៉ឺនបីរយ))។

ហេតុនេះហើយ ចំពោះចំនួនទឹកប្រាក់ ១.៤៦២,៥ (មួយពាន់បួនរយហុកសិបពីរ ក្បៀសប្រាំ) ដុល្លារអាម៉េរិក (៨.៨៣៧,៥ (ប្រាំបីពាន់ប្រាំបីរយសាមសិបប្រាំពីរ ក្បៀសប្រាំ) - ៧.៣៧៥ (ប្រាំពីរពាន់បី



www.moj.gov.kh/kh/book-library

រយចិតសិបប្រាំ) = ១.៤៦២,៥ (មួយពាន់បួនរយហុកសិបពីរ ក្បៀសប្រាំ)) ដែលមានគម្លាតខុសគ្នា ពីចំនួនទឹកប្រាក់ចំនួន ៨.៨៣៧,៥ (ប្រាំបីពាន់ប្រាំបីរយសាមសិបប្រាំពីរ ក្បៀសប្រាំ) ដុល្លារអាម៉េរិក ដែលដើមចោទអាចទទួលបានតាំងពីដើមនោះ គឺចុងចម្លើយចាំបាច់ត្រូវបង់ចំនួនទឹកប្រាក់ស្មើគ្នានេះ ឱ្យទៅដើមចោទ ដោយសារតែចំនួនដែលចុងចម្លើយនឹងត្រូវទទួលបាន គឺ ៨.៨៣៧,៥ (ប្រាំបីពាន់ប្រាំបីរយសាមសិបប្រាំពីរ ក្បៀសប្រាំ) ដុល្លារអាម៉េរិក ប៉ុន្តែជាក់ស្តែង ចុងចម្លើយបានទទួលចំនួន ១០.៣០០ (មួយម៉ឺនបីរយ) ដុល្លារអាម៉េរិក ដូច្នេះ ផ្នែកចំនួន ១.៤៦២,៥ (មួយពាន់បួនរយហុកសិបពីរ ក្បៀសប្រាំ) ដុល្លារអាម៉េរិក (១០.៣០០ (មួយម៉ឺនបីរយ) - ៨.៨៣៧,៥ (ប្រាំបីពាន់ប្រាំបីរយសាមសិបប្រាំពីរ ក្បៀសប្រាំ) = ១.៤៦២,៥ (មួយពាន់បួនរយហុកសិបពីរ ក្បៀសប្រាំ)) គឺជាចំនួនដែលទទួលបានលើស។

### ង. សេចក្តីសន្និដ្ឋាន

ដូចបានរៀបរាប់ខាងលើនេះ ចំពោះដី L1 និង ដី L2 ដើមចោទ និង ចុងចម្លើយ ក្នុងម្នាក់ៗ មានចំណែក ១ ភាគ ២ ហើយរថយន្តនៃរឿងក្តីនេះជាកម្មសិទ្ធិរបស់ចុងចម្លើយ ហើយម៉ូតូនៃរឿងក្តីនេះជាកម្មសិទ្ធិរបស់ដើមចោទ ហើយចុងចម្លើយត្រូវបង់ប្រាក់ឱ្យទៅដើមចោទចំនួន ១.៤៦២,៥ (មួយពាន់បួនរយហុកសិបពីរ ក្បៀសប្រាំ) ដុល្លារអាម៉េរិក ទើបជាការសមរម្យ។

### ច. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី

ស្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី តុលាការទទួលស្គាល់អំពីការទាមទាររបស់ដើមចោទ (បណ្តឹងទាមទារលែងលះ) ដោយសារតែនៅក្នុងនីតិវិធីបណ្តឹង ទាំងចុងចម្លើយក៏បានអះអាងថា ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយដើមចោទដែរ ដូច្នេះ មិនមែនមានន័យថា តុលាការបានទទួលស្គាល់អំពីមូលហេតុនៃការលែងលះ ដូចដើមចោទបានអះអាងនោះទេ។ ហេតុនេះ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី ក៏គប្បីឱ្យភាគីដើមចោទ ដែលឈ្នះក្តីទទួលបន្ទុកមួយផ្នែកដែរ (មាត្រា ៦៤ កថាខណ្ឌទី ២ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី)។ ចំពោះភាគនៃបន្ទុកដែលត្រូវទទួលនោះ បើពិចារណាទៅលើសំអាងហេតុដែលតុលាការបានទទួលស្គាល់នូវការទាមទារ គប្បីឱ្យដើមចោទ និង ចុងចម្លើយទទួលបន្ទុកម្នាក់ៗ ចំនួន ១ ភាគ ២។

## សេចក្តីសម្រេចបញ្ចប់

១. លែងលះដើមចោទ និង ចុងចម្លើយ។

២. កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុសរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ (កើតនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦)។

៣. កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតា (កើតនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៨)។



www.moj.gov.kh/kh/book-library

៤. បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០ (មួយរយ) ដុល្លារអាម៉េរិក ក្នុង ១ ខែ ឱ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេល គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតិ ដែលបានកត់ត្រានៅក្នុងចំណុច ២ ខាងលើនេះ ក្លាយជានីតិជន។

៥. បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០ (មួយរយ) ដុល្លារអាម៉េរិក ក្នុង ១ ខែ ឱ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេល គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ រហូតដល់ឈ្មោះ សុក សុជាតា ដែលបានកត់ត្រានៅក្នុងចំណុច ៣ ខាងលើនេះក្លាយជានីតិជន។

៦. បែងចែកទ្រព្យសម្បត្តិនីមួយៗ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធដូចខាងក្រោមនេះ :

ក. ដី ដែលកត់ត្រានៅក្នុងចំណុច ១. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយ ក្នុងចំណែកម្នាក់ៗ ចំនួន ១ ភាគ ២។

ខ. ដី ដែលកត់ត្រានៅក្នុងចំណុច ២. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយ ក្នុងចំណែកម្នាក់ៗ ចំនួន ១ ភាគ ២ ។

គ. ឡាន ដែលបានកត់ត្រានៅក្នុងចំណុច ៣. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាកម្មសិទ្ធិរបស់ចុងចម្លើយ។

ឃ. ម៉ូតូ ដែលបានកត់ត្រានៅក្នុងចំណុច ៤. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាកម្មសិទ្ធិរបស់ដើមចោទ។

ង. ប្រាក់សន្សំ ដែលបានកត់ត្រានៅក្នុងចំណុច ៥. "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាកម្មសិទ្ធិរបស់ចុងចម្លើយ។

ច. បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១.៤៦២,៥ (មួយពាន់បួនរយហុកសិបពីរក្បៀសប្រាំ) ដុល្លារអាម៉េរិក ឱ្យទៅដើមចោទ។

៧. ច្រានចោលពាក្យសុំដែលដើមចោទទាមទារទៅចុងចម្លើយឱ្យបង់អាហារកិច្ច។

៨. ប្រាក់ប្រដាប់ក្តី ត្រូវចែកជា ២ ចំណែក ដោយ ១ ផ្នែកគឺជាបន្ទុករបស់ដើមចោទ និងមួយផ្នែកដែលនៅសល់តែជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅក្នុងសាលសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើង នៅក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ខេត្តបាត់ដំបង ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

**ចៅក្រម**



www.moj.gov.kh/kh/book-library

ឧបសម្ព័ន្ធ

បញ្ជីទ្រព្យសម្បត្តិរួម

១. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ.......... ភូមិ........... ឃុំ.................ស្រុក................. ខេត្តបាត់ដំបង

"លេខក្បាលដី" ..........

២. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ.......... ភូមិ........... ឃុំ.................ស្រុក................. ខេត្តបាត់ដំបង

"លេខក្បាលដី"

៣. រថយន្ត

| | |
|---|---|
| "ប្រភេទ" | ទេសចរណ៍ |
| "ម៉ាក" | LEXUS RX300 |
| "ពណ៌" | ស |
| "កម្មសិទ្ធិករ" | ចុងចម្លើយ |
| "អាសយដ្ឋាន" | ផ្ទះលេខ ០០ ផ្លូវ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ |
| "ផ្លាកលេខ" | ......-..... |

៤. ម៉ូតូ

| | |
|---|---|
| "ប្រភេទ" | ស្រី |
| "ម៉ាក" | YAMAHA QBIX |
| "ពណ៌" | ខ្មៅ |
| "កម្មសិទ្ធិករ" | ដើមចោទ |
| "អាសយដ្ឋាន" | ផ្ទះលេខ ០០ ផ្លូវ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ |
| "ផ្លាកលេខ" | ......-..... |

៥. ប្រាក់សន្សំ

| | |
|---|---|
| "ស្ថាប័នហិរញ្ញវត្ថុ" | ធនាគារ.......... សាខា......... |
| "ប្រភេទ និង លេខគណនី" | ប្រាក់សន្សំធម្មតា xxx xxx xxx |
| "ឈ្មោះម្ចាស់គណនី" | ចុងចម្លើយ |



www.moj.gov.kh/kh/book-library

៥. គំរូដីកាសម្រេច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**..................

ដីកាសម្រេចលេខ ០០០ "ក"

ចុះថ្ងៃទី... ខែ... ឆ្នាំ...........

## ដីកាសម្រេចលែងលះ

យើង **ទ** ចៅក្រមសាលាដំបូង...........

– បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១០ ។

– បានឃើញ មាត្រា ៩៧៩ និងមាត្រាពាក់ព័ន្ធ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

– បានឃើញ សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ...... ចុះថ្ងៃទី... ខែ... ឆ្នាំ.....។

**អ្នកដាក់ពាក្យសុំ** :

ឈ្មោះ X ភេទស្រី កើតថ្ងៃទី..... ខែ.... ឆ្នាំ...... មានទីលំនៅបច្ចុប្បន្ន................។

**ភាគីម្ខាងទៀត**[37] :

ឈ្មោះ Y ភេទប្រុស កើតថ្ងៃទី..... ខែ.... ឆ្នាំ...... មានទីលំនៅបច្ចុប្បន្ន....................។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ**[38]:

១. ឱ្យអ្នកដាក់ពាក្យសុំ X និងភាគីម្ខាងទៀត Y លែងលះគ្នាតាមការព្រមព្រៀង។

២. កំណត់យក X គឺជាអ្នកមានអំណាចមេបាលើកូនឈ្មោះ A កើតថ្ងៃទី.... ខែ.... ឆ្នាំ.....[39]។

## សំអាងហេតុ

តាមលទ្ធផលនៃការពិនិត្យកស្តុតាង និងការធ្វើនីតិវិធីសាកសួរ តុលាការយល់ឃើញថា :

---

[37]. នៅក្នុងករណីដែលប្តីប្រពន្ធដាក់ពាក្យសុំរួមគ្នា X និង Y គឺជា "អ្នកដាក់ពាក្យសុំ" (មិនមានភាគីម្ខាងទៀតទេ)។ នៅក្នុងករណីដែលមានភាគីម្ខាងទៀត តុលាការត្រូវឆ្លងកាត់នីតិវិធីដែលអាចបញ្ជាក់ឆន្ទៈរបស់ភាគីម្ខាងទៀត មុននឹងចេញដីកាសម្រេច។

[38]. ផ្អែកតាមមាត្រា ២៦ កថាខណ្ឌទី២ ចំណុច ខ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង គប្បីប្រើពាក្យ "ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ" ឬ "ខ្លឹមសារនៃដីកាសម្រេច និងសកម្មភាពផ្សេងទៀតរបស់តុលាការ ដែលអ្នកដាក់ពាក្យសុំទាមទារ"។

[39]. ទោះបីជា អ្នកដាក់ពាក្យសុំ មិនបានទាមទារឱ្យតុលាការកំណត់អ្នកមានអំណាចមេបា នៅក្នុងពាក្យសុំ ក៏តុលាការត្រូវតែចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងការកំណត់អ្នកមានអំណាចមេបាដែរ ដើម្បីការពារប្រយោជន៍កូន ហើយការសម្រេចអំពីអ្នកមានអំណាចមេបា គឺចាំបាច់ត្រូវសម្រេចសេចក្តីជាមួយនឹងសេចក្តីសម្រេចលែងលះ។



www.moj.gov.kh/kh/book-library

ក. ផ្អែកតាមសំបុត្រអាពាហ៍ពិពាហ៍លេខ ០០ នៅក្នុងសៀវភៅអាពាហ៍ពិពាហ៍លេខ ០០/០០០០ ចុះថ្ងៃទី..... ខែ..... ឆ្នាំ.......... របស់មន្ត្រីអត្រានុកូលដ្ឋាន............... បានបង្ហាញថា អ្នកដាក់ពាក្យសុំឈ្មោះ X និងភាគីម្ខាងទៀតឈ្មោះ Y គឺជាប្តីប្រពន្ធស្របច្បាប់ពិតប្រាកដមែន។

ខ. អ្នកដាក់ពាក្យសុំឈ្មោះ X និងភាគីម្ខាងទៀតឈ្មោះ Y បានបង្ហាញឆន្ទៈព្រមព្រៀងគ្នា លែងលះដោយស្ម័គ្រចិត្ត និងដោយពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ព្រមទាំងគ្មានការបង្ខិតបង្ខំឡើយ។

គ. ផ្អែកតាម សំបុត្រកំណើតលេខ ០០ នៅក្នុងសៀវភៅកំណើតលេខ ០០/០០០០ ចុះថ្ងៃទី..... ខែ..... ឆ្នាំ.......... របស់មន្ត្រីអត្រានុកូលដ្ឋាន............... បានបង្ហាញថា អ្នកដាក់ពាក្យសុំឈ្មោះ X និងភាគីម្ខាងទៀតឈ្មោះ Y មានកូនឈ្មោះ A ភេទ ... កើតថ្ងៃទី... ខែ... ឆ្នាំ.......។

ឃ. អ្នកដាក់ពាក្យសុំឈ្មោះ X និងភាគីម្ខាងទៀតឈ្មោះ Y បានព្រមព្រៀងគ្នា កំណត់យកអ្នកដាក់ពាក្យសុំឈ្មោះ X ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ A ភេទ... កើតថ្ងៃទី... ខែ... ឆ្នាំ.......។

ង. ផ្អែកតាមសំអាងហេតុចំណុច ក, ចំណុច ខ,ចំណុច គ និងចំណុច ឃ ខាងលើ បានបញ្ជាក់ថា ការទាមទាររបស់អ្នកដាក់ពាក្យសុំឈ្មោះ X គឺមានមូលហេតុត្រឹមត្រូវ ផ្អែកតាមបញ្ញត្តិមាត្រា ៩៧៩ និងមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

ច. តាមបញ្ញត្តិនៃមាត្រា ២២ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បានកំណត់ថា ពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្តីភាគី គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

## សេចក្តីសម្រេចបញ្ចប់

១. ឱ្យអ្នកដាក់ពាក្យសុំឈ្មោះ X និងភាគីម្ខាងទៀតឈ្មោះ Y លែងលះគ្នា តាមការព្រមព្រៀង[40] ។[41]

២. កំណត់យក X គឺជាអ្នកមានអំណាចមេបាលើកូនឈ្មោះ A កើតថ្ងៃទី.... ខែ.... ឆ្នាំ......។

៣. សោហ៊ុយសម្រាប់នីតិវិធីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ[42]។

ថ្ងៃ............ ខែ..... ឆ្នាំ....... .....ស័ក ព.ស .......

......... ថ្ងៃទី...... ខែ........ ឆ្នាំ........

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា : **ច**

[40]. ការប្រើពាក្យ "តាមការព្រមព្រៀង" គឺដើម្បីបញ្ជាក់ថា តុលាការពិនិត្យ និងវិនិច្ឆ័យទៅលើឆន្ទៈព្រមព្រៀងគ្នារបស់គូភាគី ដោយមិនពិចារណាទៅលើមូលហេតុនៃការលែងលះ ដូចមានចែងនៅក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីទេ។ ប៉ុន្តែ ទោះបីជាមិនសរសេរពាក្យថា "តាមការព្រមព្រៀង" ក៏មិនផ្ទុយនឹងច្បាប់ដែរ ព្រោះយើងអាចដឹងបានថា ជាការលែងលះដោយការព្រមព្រៀង តាមរយៈដីកាសម្រេចផ្អែកតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ការសរសេរនៅក្នុងសំអាងហេតុ ខ និង ឃ ។

[41]. សេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចលែងលះ ចាំបាច់ត្រូវពិចារណាដូចគ្នា នឹងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមលែងលះដែរ ។ សូមអានគម្រោងមេរៀនផ្អែកទី ១ ចំណុច ១.១ ។

[42]. ករណីដែលប្តីប្រពន្ធទាំងសងខាង គឺជាអ្នកដាក់ពាក្យសុំ នាំឱ្យប្រាក់ប្រដាប់ក្តី គឺជា "បន្ទុករបស់អ្នកដាក់ពាក្យសុំទាំងសងខាង"



www.moj.gov.kh/kh/book-library

# ឧបសម្ព័ន្ធ



www.moj.gov.kh/kh/book-library

## ឧបសម្ព័ន្ធទី ១ :

## ការពន្យល់អំពីទ្រឹស្តី A និង ទ្រឹស្តី B នៃសិទ្ធិទាមទារលែងលះ

ពាក់ព័ន្ធនឹងការបកស្រាយមាត្រា៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី គឺមានទ្រឹស្តីចំនួន២ ដូចខាងក្រោម៖

① ទ្រឹស្តី A : មូលហេតុនៃការលែងលះ នៅក្នុងចំណុច ក ដល់ចំណុច ង ក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី គឺកំណត់អំពីសិទ្ធិទាមទារលែងលះ ដោយផ្អែកទៅលើមូលហេតុនៃការលែងលះ តាមចំណុចនីមួយៗ ។

【ទឡ្ហីករណ៍】 ក្រមរដ្ឋប្បវេណី គឺបញ្ញត្តអំពីលក្ខខណ្ឌចាំបាច់ដើម្បីកកើតសិទ្ធិណាមួយ ។ សិទ្ធិទាមទារ កើតឡើងដោយយកមាត្រានៃក្រមរដ្ឋប្បវេណីធ្វើជាមូលដ្ឋាន ។ ឧទាហរណ៍ សិទ្ធិទាមទារថ្លៃលក់ទិញ ត្រូវបានចែងនៅក្នុងកិច្ចសន្យាលក់ទិញ ដោយផ្អែកលើក្រមរដ្ឋប្បវេណីដែលជាមូលដ្ឋាន នាំឱ្យសិទ្ធិទាមទារថ្លៃលក់ទិញកើតឡើង តាមរយៈកិច្ចសន្យាលក់ទិញនេះ ។ ប្រសិនបើយកការពិចារណាបែបនេះ មកធ្វើជាមូលដ្ឋាន នោះមាត្រា៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី គឺបញ្ញត្តអំពីសិទ្ធិទាមទារលែងលះផ្សេងៗ គ្នា ផ្អែកតាមមូលហេតុនៃការលែងលះតាមចំណុចនីមួយៗ ។ ហេតុនេះ យើងអាចពិចារណាបានថា សិទ្ធិទាមទារលែងលះនីមួយៗ នឹងកើតឡើងផ្សេងៗគ្នា ផ្អែកតាមករណីដែលបានបំពេញលក្ខខណ្ឌ នៃមូលហេតុនៃការលែងលះ តាមចំណុចនីមួយៗនោះ ។ មូលហេតុនៃការលែងលះតាមចំណុចនីមួយៗ នៅក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បញ្ញត្តអំពីលក្ខខណ្ឌផ្សេងៗគ្នា ហេតុនេះ ការពិចារណាថា មាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ចែងពីសិទ្ធិទាមទារលែងលះផ្សេងៗគ្នា គឺជារឿងធម្មតា ។

【អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារគឺជាអ្វី?】

សេចក្តីសន្និដ្ឋាន :

មូលហេតុលែងលះក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី មិនត្រឹមតែជាអង្គហេតុដែលជាមូលហេតុនៃការទាមទារទេ ប៉ុន្តែថែមទាំងជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារផងដែរ ។

មានន័យថា អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺជាអង្គហេតុដែលបង្ហាញអំពីសិទ្ធិទាមទារលែងលះ ដោយផ្អែកទៅលើមូលហេតុនៃការលែងលះតាមចំណុចនីមួយៗនៃមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី និងអាពាហ៍ពិពាហ៍ស្របច្បាប់ តាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី ។ អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្ហាញអំពីមូលហេតុនៃការលែងលះតាមចំណុចនីមួយៗនៃមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ដែលបង្កើតឱ្យមានសិទ្ធិទាមទារលែងលះ ដោយផ្អែកលើមូលហេតុនៃការលែងលះនោះ ។

មូលហេតុ :

ទ្រឹស្តី A គឺជាទស្សនៈដែលយល់ឃើញថា មូលហេតុនៃការលែងលះក្នុងចំណុចនីមួយៗនៃមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បង្កើតឱ្យមានសិទ្ធិទាមទារលែងលះផ្សេងៗគ្នា ហេតុនេះដើម្បីអាចឱ្យបញ្ជាក់ និងញែកឱ្យដាច់ពីគ្នា ជាមួយនឹងសិទ្ធិទាមទារលែងលះដោយផ្អែកទៅលើមូលហេតុនៃការលែងលះដទៃទៀតបាន ចាំបាច់ត្រូវបង្ហាញមូលហេតុលែងលះឱ្យបានច្បាស់លាស់ ។



www.moj.gov.kh/kh/book-library

② ទ្រឹស្តី B : មូលហេតុនៃការលែងលះ នៅក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ ចាប់ពីចំណុច ក ដល់ចំណុច ង នៃក្រមរដ្ឋប្បវេណី គឺកំណត់អំពីសិទ្ធិទាមទារលែងលះតែមួយ ដោយផ្អែកទៅលើមូលហេតុនៃការលែងលះច្រើន (ចំណុច ក ដល់ចំណុច ង ខាងលើ) ។

【ទឡ្ហីករណ៍】 មូលហេតុនៃការលែងលះ ក្នុងចំណុច ក ដល់ ចំណុច ឃ នៃ មាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី សុទ្ធតែជាឧទាហរណ៍នៃមូលហេតុដែល "ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន" ។ មូលហេតុលែងលះ គឺត្រូវបានសង្ខេបជា "ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន"។

【អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារគឺជាអ្វី?】

សេចក្តីសន្និដ្ឋាន :

មូលហេតុនៃការលែងលះផ្អែកតាមចំណុចនីមួយៗ នៃមាត្រា ៩៧៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី គឺជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ ហើយមិនមែនជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារនោះទេ ។

មានន័យថា អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺជាអង្គហេតុដែលបង្ហាញពីអាពាហ៍ពិពាហ៍ស្របច្បាប់ ។ អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្ហាញអំពីចំណុចណាមួយនៃមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ។

មូលហេតុ :

ទ្រឹស្តី B គឺជាទស្សនៈដែលយល់ថា ទោះបីជាមូលហេតុលែងលះមួយណាក៏ដោយ ក៏សិទ្ធិទាមទារលែងលះមានតែមួយ ហេតុនេះ ដើម្បីញែកឱ្យដាច់ពីគ្នាជាមួយសិទ្ធិដទៃ គ្រាន់តែបញ្ជាក់ឱ្យបានច្បាស់លាស់ថា ទាមទារលែងលះគឺជាការគ្រប់គ្រាន់ហើយ ។

★ ទំនាក់ទំនងជាមួយឯកសារបង្រៀនដទៃទៀត

១. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្តឹង

កថាខណ្ឌទី១ នៃ កថាភាគទី២ ចំណុច២-(២)-ឃ នៅក្នុងទំព័រ ៥៦ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ : នីតិវិធីបណ្តឹង គឺជាការពន្យល់អំពីទ្រឹស្តី A (នៅប្រទេសជប៉ុន មានមាត្រានៃក្រមរដ្ឋប្បវេណីដែលមានទម្រង់ស្រដៀងគ្នានឹងបញ្ញត្តិមាត្រា៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាដែរ ហើយទស្សនៈនៃទ្រឹស្តី A គឺមានលក្ខណៈទូទៅនៅក្នុងប្រព័ន្ធតុលាការរបស់ប្រទេសជប៉ុន)។ មូលហេតុចម្បងដែលប្រទេសជប៉ុនពិចារណាយកទ្រឹស្តី A គឺដូចគ្នានឹងមូលហេតុដែលបានសរសេរ នៅក្នុង【ទឡ្ហីករណ៍】នៃចំណុច ① ទ្រឹស្តី A។ កថាខណ្ឌទី២ នៃកថាភាគទី២ ចំណុច២-(២)-ឃ នៅក្នុងទំព័រ ៥៦ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ : នីតិវិធីបណ្តឹង (ចាប់ពី "ប៉ុន្តែ"ទៅ) គឺជាការពន្យល់អំពីទ្រឹស្តី B ។

២. សៀវភៅស្តីពី ការពន្យល់អំពីនីតិវិធីជម្រះក្តីលើកទី ១ (បោះពុម្ពលើកទី ២)

នៅក្នុងផ្នែកទី ១ ចំណុច ១.២.១.២. លេខ ២ (២) ទំព័រទី ៤ ការណ៍ដែលសរសេរថា "មូលហេតុលែងលះនៅក្នុងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ" គឺជាសេចក្តីសន្និដ្ឋានផ្អែកតាមទ្រឹស្តី A។ <u>ការសរសេរនៅក្នុងផ្នែកទី ១ ចំណុច ១.១ សិទ្ធិទាមទារលែងលះ នៃសៀវភៅមេរៀនស្តីពីការលែងលះនេះ គឺប្រកាន់យកទ្រឹស្តី B ។</u>



www.moj.gov.kh/kh/book-library

# ការពិភាក្សា
# អំពីមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី




រៀបចំដោយក្រុមការងារគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ ជំហានទី៦
ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣

## មាតិកា

I. **ការពិចារណាអំពីទ្រឹស្តី A និងទ្រឹស្តី B នៅដំណាក់កាលពិនិត្យពាក្យបណ្តឹង**

II. **ការពិចារណាអំពីទ្រឹស្តី A និងទ្រឹស្តី B នៅដំណាក់កាលវិនិច្ឆ័យ និងសម្រេចសេចក្តី**

- របនាសម្ព័ន្ធក្នុងការវិនិច្ឆ័យ និងសម្រេចសេចក្តី ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី (CCP)
- របនាសម្ព័ន្ធក្នុងការវិនិច្ឆ័យ និងសម្រេចសេចក្តី ផ្អែកច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (LPS)
- ភាពខុសគ្នានៃលទ្ធផលផ្អែកលើទ្រឹស្តី A និងទ្រឹស្តី B

III. **ការកំណត់យកទ្រឹស្តី A ឬទ្រឹស្តី B មកអនុវត្តចំពោះមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី**

2


www.moj.gov.kh/kh/book-library

## I.ការពិចារណាអំពីទ្រឹស្តី A និងទ្រឹស្តី B នៅដំណាក់កាលពិនិត្យពាក្យបណ្ដឹង

CCP#75,78

ដើមចោទទាមទារលែងលះ ផ្អែកតាម
មាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច «ក»

ឧ①.ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍
នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ហើយ
នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ចុងចម្លើយបាន
រួមភេទជាមួយនឹងឈ្មោះ C ដែលជាមិត្តរួមការងារ
ហេតុនេះដើមចោទសុំទាមទារលែងលះ




ពាក្យបណ្ដឹងនេះ បានសរសេរនូវអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុ នៃការទាមទារ ហេតុនេះ ពុំមានភាពចាំបាច់ធ្វើការពិចារណាលើទ្រឹស្តី A ឬទ្រឹស្តី B នោះទេ

3

## I.ការពិចារណាអំពីទ្រឹស្តី A និងទ្រឹស្តី B នៅដំណាក់កាលពិនិត្យពាក្យបណ្ដឹង

CCP#75,78

ឧ②. ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍
នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩
ប៉ុន្តែដើមចោទសុំទាមទារលែងលះ




ចាំបាច់ត្រូវធ្វើការពិចារណាអំពី ទ្រឹស្តី A និងទ្រឹស្តី B

4



www.moj.gov.kh/kh/book-library

## ទ្រឹស្តី A

### មាត្រា ៩៧៨ មូលហេតុនៃការលែងលះនីមួយៗ

### មានសិទ្ធិទាមទារលែងលះចំនួន ១

| សិទ្ធិទាមទារលែងលះ | | មូលហេតុនៃការលែងលះ |
|---|---|---|
| ក សិទ្ធិទាមទារលែងលះ ផ្អែកលើអំពើផិត | → | ក បានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ |
| ខ សិទ្ធិទាមទារលែងលះ ផ្អែកលើការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ | → | ខ បានបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ |
| គ សិទ្ធិទាមទារលែងលះ ផ្អែកលើស្ថានភាពដែលមិនដឹងថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង១ឆ្នាំ | → | គ មិនដឹងថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង១ឆ្នាំ |
| ឃ សិទ្ធិទាមទារលែងលះ ផ្អែកលើស្ថានភាពដែលសហព័ទ្ធរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ ផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍ | → | ឃ បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ ផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍ |
| ង សិទ្ធិទាមទារលែងលះ ផ្អែកលើទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន | → | ង ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយគ្មានសង្ឃឹមថា នឹងអាចធ្វើបដិទានឡើងវិញបាន |

5

### មាត្រា ៩៧៨ មូលហេតុនៃការលែងលះនីមួយៗ

### មានសិទ្ធិទាមទារលែងលះចំនួន ១

| | |
|---|---|
| ក សិទ្ធិទាមទារលែងលះ ផ្អែកលើអំពើផិត | ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ចុងចម្លើយបានរួមភេទជាមួយឈ្មោះ C ដែលជាមិត្តរួមការងារ។ |
| ខ សិទ្ធិទាមទារលែងលះ ផ្អែកលើការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ | ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ចុងចម្លើយ បានចាកចេញពីផ្ទះ ដោយប្រមូលយកទ្រព្យសម្បត្តិមានតម្លៃទាំងអស់ទៅជាមួយ ដោយមិនបានជួយទំនុកបម្រុងគ្រួសារឡើយ។ |
| គ សិទ្ធិទាមទារលែងលះ ផ្អែកលើស្ថានភាពដែលមិនដឹងថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង១ឆ្នាំ | ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ចុងចម្លើយ បានចាកចេញពីផ្ទះ ទៅខេត្តបាត់ដំបង ចាប់តាំងពីថ្ងៃនោះមកអស់រយៈពេលជាង៣ឆ្នាំហើយ មិនឃើញចុងចម្លើយមកវិញទេ ហើយក៏មិនបានទទួលដំណឹងពីចុងចម្លើយដែរ។ |
| ឃ សិទ្ធិទាមទារលែងលះ ផ្អែកលើស្ថានភាពដែលសហព័ទ្ធរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ ផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍ | ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ចុងចម្លើយ បានចាកចេញពីផ្ទះដែលជាលំនៅឋានប្តីប្រពន្ធ ទៅរស់នៅផ្ទះជួល។ ១ខែក្រោយមក ចុងចម្លើយ បានត្រឡប់មកផ្ទះវិញក្នុងគោលបំណងសួរសុខទុក្ខកូនតែប៉ុណ្ណោះ ពោលគឺមិនស្នាក់នៅទេ។ គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០២១ រហូតមកទល់នឹងពេលនេះ អស់រយៈពេលជាង២ឆ្នាំហើយ ដែលដើមចោទ និងចុងចម្លើយរស់នៅបែកគ្នា និងពុំមានសម្ព័ន្ធភាពជាមួយគ្នា។ |
| ង សិទ្ធិទាមទារលែងលះ ផ្អែកលើទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន | ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ចុងចម្លើយ បានជេរដើមចោទថា មីស្រីល្ងង់ខ្លៅ មីអត់កំណើត ហើយថែមទាំងវាយដើមចោទ បែកក្បាល និងបាក់ខ្នង់ច្រមុះ ដែលបណ្តាលឱ្យដើមចោទ មិនអាចបន្តរួមរស់ជាមួយចុងចម្លើយតទៅទៀត។ |

6



www.moj.gov.kh/kh/book-library

## ទ្រឹស្ដី B

### មាត្រា៩៧៨ មានសិទ្ធិទាមទារលែងលះតែ១

| សិទ្ធិទាមទារលែងលះ | មូលហេតុនៃការលែងលះ |
| --- | --- |

**សិទ្ធិទាមទារលែងលះ**

- ក បានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ
- ខ បានបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ
- គ មិនដឹងថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង១ឆ្នាំ
- ឃ បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ ផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍
- ង ទំនាក់ទំនងអាពាហ៍ពិពាហ៍បែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានវិញបាន

7

### មាត្រា ៩៧៨ មានសិទ្ធិទាមទារលែងលះតែ១

**សិទ្ធិទាមទារលែងលះ**

- ក ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ចុងចម្លើយ បានរួមភេទជាមួយឈ្មោះ C ដែលជាមិត្តរួមការងារ។
- ខ ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ចុងចម្លើយ បានចាកចេញពីផ្ទះ ដោយប្រមូលយកទ្រព្យសម្បត្តិមានតម្លៃទាំងអស់ទៅជាមួយ ដោយមិនបានជួយទំនុកបម្រុងគ្រួសារឡើយ។
- គ ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ចុងចម្លើយ បានចាកចេញពីផ្ទះ ទៅខេត្តបាត់ដំបង ចាប់តាំងពីថ្ងៃនោះមកអស់រយៈពេលជាង៣ឆ្នាំហើយ មិនឃើញចុងចម្លើយមកវិញទេ ហើយក៏មិនបានទទួលដំណឹងពីចុងចម្លើយដែរ។
- ឃ ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ចុងចម្លើយ បានចាកចេញពីផ្ទះដែលជាលំនៅឋានប្ដីប្រពន្ធ ទៅរស់នៅផ្ទះជួល។ ១ខែក្រោយមក ចុងចម្លើយ បានត្រឡប់មកផ្ទះវិញក្នុងគោលបំណងសួរសុខទុក្ខកូនតែប៉ុណ្ណោះ ពោលគឺមិនស្នាក់នៅទេ។ គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០២១ រហូតមកទល់នឹងពេលនេះ អស់រយៈពេលជាង២ឆ្នាំហើយ ដែលដើមចោទ និងចុងចម្លើយរស់នៅបែកគ្នា និងពុំមានសម្ពន្ធភាពជាមួយគ្នា។
- ង ▪ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ចុងចម្លើយ បានជេរដើមចោទថា មីស្រីល្ងង់ខ្លៅ មីអត់កំណើត ហើយថែមទាំងវាយដើមចោទ បែកក្បាល និងបាក់ឆ្អឹងច្រមុះ ដែលបណ្ដាលឱ្យដើមចោទ មិនអាចបន្តរួមរស់ជាមួយចុងចម្លើយតទៅទៀត។

8



www.moj.gov.kh/kh/book-library

តាមទ្រឹស្តី A កំណត់យក មូលហេតុនៃការលែងលះនីមួយៗ មានសិទ្ធិទាមទារលែងលះចំនួន១ នាំឱ្យ ត្រូវសរសេរអំពីសិទ្ធិទាមទារលែងលះនីមួយៗឱ្យបានច្បាស់លាស់ ទើបមានភាពត្រឹមត្រូវ ឧ. ក្នុងករណី ដើមចោទទាមទារលែងលះផ្អែកលើអំពើផិត ត្រូវសរសេរថា «ចុងចម្លើយបានរួមភេទជាមួយនឹងឈ្មោះ C ដែលមិនមែនជាសហព័ទ្ធរបស់ខ្លួន» = បានសរសេរអំពីសិទ្ធិទាមទារលែងលះ (សូមមើលនៅស្លាយលេខ ១០)

តាមទ្រឹស្តី B កំណត់យក សិទ្ធិទាមទារលែងលះតែ១ នាំឱ្យសរសេរត្រឹមតែសិទ្ធិទាមទារលែងលះនោះមានភាពគ្រប់គ្រាន់ ឧ. ក្នុងករណីដើមចោទទាមទារលែងលះដោយមូលហេតុផិត ត្រឹមសរសេរថា «ដើមចោទទាមទារលែងលះ» = បានសរសេរអំពីសិទ្ធិទាមទារលែងលះ (សូមមើលនៅស្លាយលេខ១០)

9

## ទ្រឹស្តី A

មាត្រា ៩៧៨ មូលហេតុនៃការលែងលះនីមួយៗ
មានសិទ្ធិទាមទារលែងលះចំនួន១

ឧ. ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ប៉ុន្តែដើមចោទ សុំទាមទារលែងលះ

**មិនបានសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារឱ្យបានគ្រប់គ្រាន់ (សិទ្ធិទាមទារលែងលះ)** ❌

⊕ **អំពើផិត** →

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២
ចុងចម្លើយបានរួមភេទជាមួយនឹងឈ្មោះ C ដែលជាមិត្តរួមការងារ ហេតុនេះ ដើមចោទសុំទាមទារលែងលះ ✅ → **សិទ្ធិទាមទារលែងលះផ្អែកលើអំពើផិត**

## ទ្រឹស្តី B

មាត្រា ៩៧៨
មានសិទ្ធិទាមទារលែងលះតែ១

ឧ. ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ប៉ុន្តែដើមចោទ សុំទាមទារលែងលះ

**បានសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ (សិទ្ធិទាមទារលែងលះ)** ✅

10



www.moj.gov.kh/kh/book-library

## II.ការពិចារណាអំពីទ្រឹស្តី A និងទ្រឹស្តី B នៅដំណាក់កាលវិនិច្ឆ័យ និងសម្រេចសេចក្តី

● របនាសម្ព័ន្ធក្នុងការវិនិច្ឆ័យ និងសម្រេចសេចក្តី ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី (CCP)




11

## II.ការពិចារណាអំពីទ្រឹស្តី A និងទ្រឹស្តី B នៅដំណាក់កាលវិនិច្ឆ័យ និងសម្រេចសេចក្តី

● របនាសម្ព័ន្ធក្នុងការវិនិច្ឆ័យ និងសម្រេចសេចក្តី ផ្អែកតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (LPS)




12



www.moj.gov.kh/kh/book-library

## ភាពខុសគ្នានៃលទ្ធផលផ្អែកលើទ្រឹស្តី A និងទ្រឹស្តី B

ករណីសិក្សា៖ ភាគីទាមទារលែងលះ ដោយមូលហេតុសហព័ទ្ធបានប្រព្រឹត្តអំពើផិត

ឱ. ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ហើយនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ចុងចម្លើយបានរួមភេទជាមួយនឹងឈ្មោះ C ដែលជាមិត្តរួមការងារ ហេតុនេះដើមចោទទាមទារលែងលះ។

តុលាការបែរជារកឃើញ មូលហេតុនៃការលែងលះ ផ្អែកលើទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ឱ. ចុងចម្លើយ បានវាយដើមចោទបែកក្បាល និងមានការជេរប្រមាថ តើតុលាការត្រូវធ្វើដូចម្តេច?

13

**ទ្រឹស្តី A**

មាត្រា ៩៧៨ មូលហេតុនៃការលែងលះនីមួយៗ

<u>មានសិទ្ធិទាមទារលែងលះចំនួន១</u>




<u>តុលាការមិនអាចវិនិច្ឆ័យ និងសម្រេចអំពីសិទ្ធិទាមទារលែងលះ ផ្អែកលើចំណុច «ង» បានឡើយ</u>
ពីព្រោះ ជាចំណុចដែលដើមចោទមិនបានទាមទារ ហេតុនេះ ប្រសិនបើតុលាការវិនិច្ឆ័យ និងសម្រេចអំពីចំណុចនោះ នាំឱ្យផ្ទុយពីគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី

14



www.moj.gov.kh/kh/book-library









www.moj.gov.kh/kh/book-library

## ទ្រឹស្តី B

### មាត្រា ៩៧៨

### មានសិទ្ធិទាមទារលែងលះតែ១




ដោយសារតែទទួលស្គាល់ថា សិទ្ធិលែងលះតែមួយ គឺ«សិទ្ធិទាមទារលែងលះ» (សិទ្ធិនេះចែកដាច់ពីសិទ្ធិផ្សេងទៀត) ហេតុនេះ ទោះបីជាប្រើមូលហេតុនៃការលែងលះមួយណាក៏ដោយ ក៏សិទ្ធិទាមទារលែងលះមិនផ្លាស់ប្តូរ។ ក្នុងករណីនេះ តុលាការអាចទទួលស្គាល់អង្គហេតុដែលភាគីមិនបានអះអាងធ្វើជាមូលដ្ឋាននៃសាលក្រម (អង្គហេតុប្រើអំពើហិង្សា និងជេរប្រមាថ)។

17

### III. ការកំណត់យកទ្រឹស្តី A ឬទ្រឹស្តី B មកអនុវត្តចំពោះមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី

#### ● មូលដ្ឋាននៃទ្រឹស្តី A

▪ ផ្អែកតាមពាក្យពេចន៍នៅក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុចនីមួយៗបានបញ្ញត្តបែងចែកច្បាស់លាស់ជា៥ករណី ហេតុនេះ ការពិចារណាអំពីការកើតឡើងនៃសិទ្ធិនៅក្នុងច្បាប់សារជាតុនីមួយៗ គឺជារឿងធម្មតា។

▪ ចំណុច «ក» ដល់ចំណុច «ឃ» មិនអាចបកស្រាយថាជាឧទាហរណ៍មួយនៃ «ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន» ឡើយ។




18



www.moj.gov.kh/kh/book-library

III. **ការកំណត់យកទ្រឹស្តី A ឬទ្រឹស្តី B មកអនុវត្តចំពោះមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី**

● មូលដ្ឋាននៃទ្រឹស្តី B

▪ ប្រសិនបើពិចារណាបន្ថែមទៀតទៅលើខ្លឹមសារនៃចំណុចនីមួយៗនៃមាត្រា ៩៧៨ កថាខណ្ឌទី១ អាចនិយាយបានថា មូលហេតុនៃចំណុច «ក» ដល់ចំណុច «ឃ» ជាឧទាហរណ៍មួយនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាន។ ប្រសិនបើបែបនេះ ចំណុច «ក» ដល់ចំណុច «ង» សុទ្ធតែមានគោលបំណងចែងអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាន។ ហេតុនេះ គួរតែពិចារណាថា សិទ្ធិទាមទារលែងលះកើតឡើងដោយផ្អែកតាមទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថា នឹងអាចធ្វើបដិទានឡើងវិញបាន។




19

III. **ការកំណត់យកទ្រឹស្តី A ឬទ្រឹស្តី B មកអនុវត្តចំពោះមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី**

● ចំណុចគួរប្រុងប្រយ័ត្ន

១. ទ្រឹស្តី A បានកំណត់អំពី មូលហេតុនៃការលែងលះនីមួយៗមានសិទ្ធិលែងលះចំនួនមួយ ដែលមិនអនុញ្ញាតឱ្យតុលាការទទួលស្គាល់សិទ្ធិដែលដើមចោទមិនបានទាមទារក៏ពិតមែន ប៉ុន្តែតុលាការអាចប្រើសិទ្ធិឱ្យបំភ្លឺ ដែលជាមធ្យោបាយមួយក្នុងការឱ្យភាគីធ្វើការបន្ថែមការទាមទារហើយតុលាការអាចវិនិច្ឆ័យ និងសម្រេចសេចក្តីចំពោះសិទ្ធិនោះបាន ហេតុនេះ ពុំមានន័យថា «ប្រសិនបើកំណត់យកទ្រឹស្តី A នាំឱ្យភាគីមានការពិបាកក្នុងការលែងលះ» នោះទេ (មិនគួរក្លាយជាមូលហេតុក្នុងការកំណត់យកទ្រឹស្តី B)។

២. ប្រសិនបើ កំណត់យកទ្រឹស្តី B ក្នុងករណី ពាក្យបណ្តឹងសរសេរមូលហេតុលែងលះ មិនបានច្បាស់លាស់ តុលាការមិនគួរវិនិច្ឆ័យដោយមិនដឹងពីមូលហេតុច្បាស់លាស់នោះទេ ហេតុនេះ តុលាការគួរតែបញ្ជាក់ឱ្យបានច្បាស់លាស់ថា ដើមចោទធ្វើការទាមទារផ្អែកតាមមូលហេតុអ្វី។ ប៉ុន្តែយើងមិនគួរយកបញ្ហានោះ មកធ្វើជាមូលហេតុនៃការកំណត់យកទ្រឹស្តី A នោះទេ។

20



www.moj.gov.kh/kh/book-library

## ឧបសម្ព័ន្ធទី ២ :
## ការពន្យល់អំពីទ្រឹស្តីនៃការកំណត់អ្នកមានអំណាចមេបា
## បញ្ហាទី ១

នៅក្នុងការលែងលះតាមផ្លូវបណ្តឹង និង ការលែងលះដោយការព្រមព្រៀង ករណីដែលឪពុកម្តាយគ្មានវិវាទអំពីអ្នកមានអំណាចមេបា តើតុលាការគប្បីសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបានៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសេចក្តីសម្រេចដែរ ឬទេ ?

ឪពុកម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបា ដោយសហការគ្នា (ម. ១០៣៦ នៃ ក.រ.ណ.)។ ប៉ុន្តែ តាមរយៈការលែងលះ ឪពុកម្តាយ មិនអាចប្រើប្រាស់អំណាចមេបា ដោយសហការគ្នាទៀតបានទេ ហេតុនេះ អំណាចមេបាទោល ត្រូវបានយកមកប្រើប្រាស់ (ម. ១០៣៧ នៃក.រ.ណ.)។ ហេតុនេះ ដើម្បីការពារផលប្រយោជន៍របស់កូន គឺមានភាពចាំបាច់ណាស់ ក្នុងការសរសេរឱ្យបានច្បាស់លាស់នៅក្នុងសេចក្តីសម្រេចថា តើឪពុក ឬម្តាយ ដែលជាអ្នកមានអំណាចមេបា។ បញ្ហាគឺ តើតុលាការត្រូវសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបានៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសេចក្តីសម្រេចដែរ ឬទេ ?

តាមការបកស្រាយមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី និងមាត្រា២២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ព្រមទាំងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង គឺមានទ្រឹស្តីចំនួន២ (ពីរ) ដែលមានការយល់ឃើញផ្សេងពីគ្នា រួមមាន **ទ្រឹស្តី ក** និង **ទ្រឹស្តី ខ**។ **ទ្រឹស្តី ក** គឺតុលាការត្រូវកំណត់អ្នកមានអំណាចមេបា នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬដីកាសម្រេច ទោះបីជាឪពុកម្តាយបានពិភាក្សា និងព្រមព្រៀងគ្នាអំពីការកំណត់អំពីអ្នកមានអំណាចមេបាក៏ដោយ។ ផ្ទុយទៅវិញ **ទ្រឹស្តី ខ** គឺតុលាការមិនត្រូវកំណត់អំពីអ្នកមានអំណាចមេបា នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬដីកាសម្រេចទេ ក្នុងករណីដែលឪពុកម្តាយបានពិភាក្សា និងព្រមព្រៀងគ្នាអំពីការកំណត់អ្នកមានអំណាចមេបារួចរាល់ហើយ។

### ១. ករណីលែងលះតាមផ្លូវបណ្តឹង

① **ទ្រឹស្តី ក-១** : ករណីតុលាការចេញសាលក្រមទទួលស្គាល់ការលែងលះតាមផ្លូវបណ្តឹង ទោះបីជាឪពុកម្តាយគ្មានវិវាទអំពីការកំណត់អ្នកមានអំណាចមេបាក៏ដោយ ក៏តុលាការគប្បីសម្រេចអំពីការកំណត់អ្នកមានអំណាចមេបា នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម យោងតាមមាត្រា ២២ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ផ្អែកតាមមាត្រា១០៣៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី។

**【ទឡ្ហីករណ៍ទី ១】** ការបកស្រាយទាក់ទងនឹងទម្រង់ និងការកើតមានអានុភាពនៃការកំណត់អំពីអ្នកមានអំណាចមេបា :

ការព្រមព្រៀងអំពីអ្នកមានអំណាចមេបា គឺជាការព្រមព្រៀងដែលតម្រូវឱ្យមានភាពច្បាស់លាស់ និងពិតប្រាកដខ្ពស់ ដូច្នេះ គប្បីតម្រូវឱ្យមានទម្រង់ជាក់លាក់មួយ ដោយគ្រឹមតែជាការព្រមព្រៀងផ្ទាល់មាត់ គឺមិនមានលក្ខណៈគ្រប់គ្រាន់ទេ។ មាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី គឺជាបញ្ញត្តិផ្អែកលើការលែងលះតាមមាត្រា ៩៧៨ និងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ហើយទម្រង់នៃការលែងលះតាមមាត្រា ៩៧៨ និងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី សុទ្ធតែតម្រូវឱ្យមានសេចក្តីសម្រេច ក្នុងទម្រង់នៃការលែងលះ។ ហេតុនេះហើយ ការកំណត់អំពីអ្នកមានអំណាចមេបា ដែលត្រូវធ្វើក្នុងពេលព្រមគ្នាជាមួយនឹងការលែងលះ ក៏គប្បីធ្វើឡើងដោយទម្រង់នៃសេចក្តីសម្រេចដូចគ្នាជាមួយនឹងការលែងលះដែរ។ ជារួម គប្បីពិចារណាថា ការកំណត់អំពីអ្នកមានអំណាចមេបានឹងមានអានុភាពដោយការបញ្ជាក់ និងសម្រេចសេចក្តីពីតុលាការថា តើការព្រមព្រៀងនេះ ពិតជាឆន្ទៈពិតប្រាកដរបស់គូភាគីពុំមែនមានអានុភាពដោយសារការព្រមព្រៀងរបស់ឪពុកម្តាយតែមួយមុខនោះទេ។



www.moj.gov.kh/kh/book-library

**【ទុទ្ធីករណ៍ទី ២】** ការបកស្រាយពាក្យ "តាមការពិភាក្សារបស់ឪពុកម្តាយ" នៅក្នុងមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី :

ពាក្យថា "តាមការពិភាក្សារបស់ឪពុកម្តាយ" នៅក្នុងមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ត្រូវបានបកស្រាយថា សំដៅលើករណីដែលឪពុកម្តាយបានព្រមព្រៀងអំពីការលែងលះ និងបានពិភាក្សាគ្នាអំពីអ្នកមានអំណាចមេបា។ ករណីលែងលះតាមផ្លូវបណ្តឹង គឺជាករណីដែលគូភាគីមិនអាចព្រមព្រៀងគ្នាអំពីរឿងលែងលះផ្ទាល់តែម្តង។ ដូច្នេះ ករណីលែងលះតាមផ្លូវបណ្តឹង គឺមិនអាចមានស្ថានភាពដែលឪពុកម្តាយអាចពិភាក្សា និងព្រមព្រៀងគ្នា អំពីការកំណត់អ្នកមានអំណាចមេបាបានឡើយ។ ហេតុនេះ ពុំអាចសន្មតថា "ការពិភាក្សារបស់ឪពុកម្តាយ" បានសម្រេចនោះឡើយ។ ដូចនេះ ករណីលែងលះតាមផ្លូវបណ្តឹង ត្រូវយកមាត្រា ១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី មកអនុវត្ត ពុំមែនយកមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី មកអនុវត្តនោះឡើយ។

**【ទុទ្ធីករណ៍ទី ៣】** ការបកស្រាយមាត្រា១០៣៧ កថាខណ្ឌទី១ និងទី៣ នៃក្រមរដ្ឋប្បវេណី :

មាត្រា១០៣៧ កថាខណ្ឌទី១ និងទី៣ នៃក្រមរដ្ឋប្បវេណី គ្រាន់តែបញ្ញត្តពីរបៀបវិនិច្ឆ័យអំពីអ្នកមានអំណាចមេបា ដែលមាន ២ (ពីរ) របៀប ដូចខាងក្រោមតែប៉ុណ្ណោះ :

– របៀបវិនិច្ឆ័យ ស្របទៅតាមការពិភាក្សារបស់ភាគី (កថាខណ្ឌទី ១)

– របៀបវិនិច្ឆ័យ ដោយយក "ផលប្រយោជន៍របស់កូន" ធ្វើជាមូលដ្ឋាន (កថាខណ្ឌទី ៣)

សរុបមក មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី មិនមែនបញ្ញត្តអំពីសមត្ថកិច្ចតុលាការ ថាតើតុលាការមាន ឬមិនមានសិទ្ធិអំណាចក្នុងការកំណត់អំពីអ្នកមានអំណាចមេបា នៅក្នុងសេចក្តីសម្រេចនោះឡើយ។ ដូចនេះ ករណីមានការព្រមព្រៀងរបស់ឪពុកម្តាយ ទោះបីជាតុលាការបានសម្រេចអំពីការកំណត់អ្នកមានអំណាចមេបា នៅក្នុងសេចក្តីសម្រេចក៏ដោយ ក៏ការសម្រេចសេចក្តីនេះមិនផ្ទុយនឹងបញ្ញត្តិមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណីដែរ។

មាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី គប្បីពិចារណាថាតុលាការអាចសម្រេចសេចក្តីអំពីការកំណត់យក "អ្នកដែលត្រូវបានកំណត់តាមការពិភាក្សារបស់ឪពុកម្តាយ" (កថាខណ្ឌទី១) ឬ "អ្នកដែលត្រូវបានកំណត់ ដោយការពិចារណាទៅលើផលប្រយោជន៍របស់កូន" (កថាខណ្ឌទី ៣) ធ្វើជាអ្នកមានអំណាចមេបា ហើយគប្បីពិចារណាថា មាត្រា ១០៣៧ កថាខណ្ឌទី១ និង ទី៣ នៃក្រមរដ្ឋប្បវេណី គឺជាបញ្ញត្តិដែលចែងថា នៅពេលសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ប្រសិនបើមានអ្នកដែលត្រូវបានកំណត់តាមការពិភាក្សារបស់ឪពុកម្តាយ តុលាការត្រូវយកលទ្ធផលនៃការពិភាក្សានោះជាអាទិភាព ហើយតុលាការចាំបាច់ត្រូវសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ស្របទៅតាមលទ្ធផលនៃការពិភាក្សានោះ ។

**【ទុទ្ធីករណ៍ទី ៤】** ការបកស្រាយ មាត្រា ២២ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល :

ឃ្លាដែលចែងថា "ប្រសិនបើតុលាការចេញសាលក្រម ឬ សាលដីកាទទួលស្គាល់ការទាមទាររបស់ដើមចោទ នៅក្នុងបណ្តឹងទាមទារលុបចោលនូវចំណងអាពាហ៍ពិពាហ៍ ឬ លែងលះគ្នា តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ដោយឆន្ទានុសិទ្ធិ" មានន័យថា តុលាការដើរតួនាទីយ៉ាងសកម្មក្នុងការកំណត់អំពីអ្នកមានអំណាចមេបាលើកូនដែលជាអនីតិជន ដូច្នេះ ក្នុងករណីដែលសហព័ទ្ធមានកូនជាអនីតិជន តុលាការត្រូវតែកំណត់អ្នកមានអំណាចមេបាលើកូននោះ។ គោលគំនិតនៃមាត្រានេះគឺប្រសិនបើសហព័ទ្ធមានកូនដែលជាអនីតិជន ប៉ុន្តែ តុលាការបែរជាមិនកំណត់អ្នកមានអំណាចមេបា នោះគឺផ្ទុយនឹង មាត្រា ២២ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ បើយើងពិចារណា លើមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណីថា ជាករណីដែលតុលាការមានសមត្ថកិច្ច



www.moj.gov.kh/kh/book-library

កំណត់អ្នកមានអំណាចមេបា តែនៅក្នុងករណីដែលឪពុកម្ដាយគ្មានការព្រមព្រៀងនោះ គឺមិនសូវចុះសម្រុងនឹងខ្លឹមសារមាត្រា ២២ កថាខណ្ឌទី ១ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឡើយ។

**【គំនិតផ្ទុយចំពោះទ្រឹស្ដី ក】**

មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ដែលទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ និងមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ដែលទាក់ទងនឹងរបៀបកំណត់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន និង ការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន សុទ្ធតែបានប្រើពាក្យថា "តាមការពិភាក្សា" ដែលចំណុចនេះស្រដៀងគ្នានឹងទម្រង់នៃមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណីដែរ។ ទាក់ទងនឹងមាត្រា៩៨០ និងមាត្រា១០៤០នៃក្រមរដ្ឋប្បវេណីនេះ ត្រូវបានបកស្រាយថា អានុភាពនឹងកើតមានឡើង នៅពេលដែលមានត្រឹមតែការពិភាក្សារបស់សហព័ទ្ធតែប៉ុណ្ណោះ ហើយតុលាការមានសិទ្ធិអំណាចសម្រេចសេចក្ដី តែនៅក្នុងករណីដែលគ្មានការពិភាក្សាគ្នារបស់សហព័ទ្ធតែប៉ុណ្ណោះ។ នៅពេលដែលពាក្យពេចន៍ និងទម្រង់មានភាពស្រដៀងគ្នា ប៉ុន្តែ បែរជាយើងបកស្រាយមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ខុសពីមាត្រាទាំងពីរនេះទៅវិញ នឹងធ្វើឱ្យគ្មានសង្គតិភាពនៃការបកស្រាយបញ្ញត្តិមាត្រា។

**【គំនិតផ្ទុយពី គំនិតផ្ទុយចំពោះទ្រឹស្ដី ក】**

ការកំណត់អ្នកមានអំណាចមេបានៅពេលលែងលះ មានលក្ខណៈជាសារជារណៈខ្ពស់ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីបានបែងចែកចំណុចនេះដាច់ដោយឡែកពីចំណុចទាក់ទងទ្រព្យសម្បត្តិដូចជាការបែងចែកទ្រព្យសម្បត្តិជាអាទិ៍ (នៅក្នុងមាត្រា ១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ពុំបានប្រើពាក្យថា "តាមការទាមទារ" ឡើយ។)។ ដូចនេះ ក្រមរដ្ឋប្បវេណី បានសន្មតពីការកើតឡើងនៃគម្លាតរវាងការកំណត់អ្នកមានអំណាចមេបានៅពេលលែងលះ និងចំណុចផ្សេងទៀត ។

**② ទ្រឹស្ដី ខ-១** : ទោះបីជាក្នុងករណីឪពុកម្ដាយមានវិវាទអំពីការលែងលះក៏ដោយ ប៉ុន្តែ ប្រសិនបើពុំមានវិវាទអំពីការកំណត់អ្នកមានអំណាចមេបាទេ នោះការកំណត់អំពីអ្នកមានអំណាចមេបា នឹងត្រូវកំណត់តាមត្រឹមតែការពិភាក្សារបស់ឪពុកម្ដាយតែប៉ុណ្ណោះ ផ្អែកតាមបញ្ញត្តិមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។ តុលាការមិនត្រូវកំណត់អំពីអ្នកមានអំណាចមេបានៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមឡើយ។

**【ទស្សីករណ៍ទី១】** ការបកស្រាយទាក់ទងនឹងទម្រង់ និងការកើតមានអានុភាពនៃការកំណត់អ្នកមានអំណាចមេបា :

ក្រមរដ្ឋប្បវេណី ពុំបានបញ្ញត្តអំពីទម្រង់នៃការកំណត់អ្នកមានអំណាចមេបាថា ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយសេចក្ដីសម្រេចណាមួយ ឡើយ។ ហេតុនេះ ក្នុងករណីមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីត្រឹមតែការព្រមព្រៀងដោយផ្ទាល់មាត់របស់ឪពុកម្ដាយ នាំឱ្យការពិភាក្សាត្រូវបានបង្កើតឡើង ដោយពុំចាំបាច់ត្រូវការទម្រង់ផ្សេងទៀតនោះទេ។ ហេតុដូចនេះ ប្រសិនបើឪពុកម្ដាយបានព្រមព្រៀងគ្នាអំពីអ្នកមានអំណាចមេបានៅមុនពេល ឬនៅពេលលែងលះ នោះអានុភាពនៃការកំណត់អំពីអ្នកមានអំណាចមេបា នឹងកើតឡើងទន្ទឹមគ្នាជាមួយនឹងអានុភាពនៃសេចក្ដីសម្រេចលែងលះ។

ប្រសិនបើមានគោលបំណងចង់បន្សល់ទុកខ្លឹមសារនៃការពិភាក្សារបស់ឪពុកម្ដាយ ឱ្យបានច្បាស់លាស់ នោះពុំចាំបាច់សរសេរ នៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសេចក្ដីសម្រេចឡើយ។ នេះមានន័យថា បើជាការលែងលះតាមផ្លូវបណ្ដឹង ខ្លឹមសារនៃការព្រមព្រៀងគ្នានេះ គឺអាចសរសេរចូលនៅក្នុងចំណុចអង្គហេតុដែលគ្មានវិវាទនៃសាលក្រមបានដូចជា "ឪពុកឈ្មោះ ក និង ម្ដាយឈ្មោះ ខ បានព្រមព្រៀងកំណត់យក ម្ដាយឈ្មោះ ខ គឺជាអ្នកមានអំណាចមេបារបស់កូនឈ្មោះ គ"។ បើជាការលែងលះដោយការព្រមព្រៀង នោះការព្រមព្រៀងអំពីអ្នកមានអំណាចមេបា គឺជាលក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង ដូច្នេះ ចាំបាច់ត្រូវសរសេរអំពីការព្រមពៀងនេះ នៅក្នុងសំអាងហេតុនៃដីកាសម្រេច



www.moj.gov.kh/kh/book-library

ដូចជា "ឪពុកឈ្មោះ ក និង ម្តាយឈ្មោះ ខ បានព្រមព្រៀងកំណត់យក ម្តាយឈ្មោះ ខ គឺជាអ្នកមានអំណាចមេបារបស់កូនឈ្មោះ គ"។ ទោះបីជាករណីការលែងលះតាមផ្លូវបណ្តឹង ឬការលែងលះដោយការព្រមព្រៀង ការកំណត់អំពីអ្នកមានអំណាចមេបា មិនត្រូវសរសេរចូលក្នុងខ្លឹមសារនៃសេចក្តីសម្រេចទេ នៅក្នុងករណីដែលឪពុកម្តាយបានព្រមព្រៀងគ្នាអំពីការកំណត់អ្នកមានអំណាចមេបា។ ប្រសិនបើមានវិវាទនៅក្រោយពេលលែងលះថា តើឪពុក ឬម្តាយ ជាអ្នកមានអំណាចមេបានៅពេលលែងលះ ភាគីអាចដាក់ពាក្យបណ្តឹងទាមទារឱ្យប្រគល់កូន ឬដាក់ពាក្យសុំផ្លាស់ប្តូរអ្នកមានអំណាចមេបា ជាអាទិ៍ ដោយសំអាងលើចំណុចដែលបានសរសេរចូលនៅក្នុងអង្គហេតុដែលគ្មានវិវាទនៃសាលក្រម ឬសំអាងហេតុនៃដីកាសម្រេចអំពីការលែងលះ។

**【ទស្សីករណ៍ទី ២】** ការបកស្រាយពាក្យថា "តាមការពិភាក្សារបស់ឪពុកម្តាយ" នៅក្នុងមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី :

ពាក្យថា "តាមការពិភាក្សារបស់ឪពុកម្តាយ" នៅក្នុងមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី មានន័យថា លុះត្រាតែឪពុកម្តាយបានព្រមព្រៀងអំពីអ្នកមានអំណាចមេបា ហើយឃ្លានេះ គឺមិនមានពាក់ព័ន្ធនឹងឆន្ទៈព្រមព្រៀង ឬមិនព្រមព្រៀងគ្នា អំពីការលែងលះឡើយ។

**【ទស្សីករណ៍ទី ៣】** ការបកស្រាយមាត្រា ១០៣៧ កថាខណ្ឌទី១ និង ទី៣ នៃក្រមរដ្ឋប្បវេណី :

មាត្រា១០៣៧ កថាខណ្ឌទី១ និង ទី៣ នៃក្រមរដ្ឋប្បវេណី គឺជាបញ្ញត្តិដែលកំណត់អំពី សមត្ថកិច្ចរបស់តុលាការពោលគឺ តុលាការមានសិទ្ធិអំណាចក្នុងការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ផ្អែកតាមកថាខណ្ឌទី៣ តែប៉ុណ្ណោះ (ករណីការពិភាក្សារបស់ឪពុកម្តាយពុំបានសម្រេច ឬ ពុំអាចពិភាក្សាបាន)។

**【ទស្សីករណ៍ទី៤】** ការបកស្រាយកមាត្រា២២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល :

តុលាការត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការកំណត់អំពីអ្នកមានអំណាចមេបា តែនៅក្នុងករណីដែលគ្មានការពិភាក្សារបស់ឪពុកម្តាយប៉ុណ្ណោះ ពោលគឺ ករណីនៃមាត្រា១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។ បន្ទាប់ពីតុលាការមានសមត្ថកិច្ច ដោយផ្អែកតាមមាត្រា១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ទើបមាត្រា២២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវបានយកមកអនុវត្តតាមក្រោយ។ ច្បាប់សារជាតុ បានផ្តល់នូវសមត្ថកិច្ចដល់តុលាការ សម្រាប់ការអនុវត្តតាមច្បាប់នីតិវិធី ក្នុងករណីដែលច្បាប់សារជាតុ មិនបានផ្តល់សមត្ថកិច្ចដល់តុលាការ នោះតុលាការមិនអាចអនុវត្តសមត្ថកិច្ចជំនុំជម្រះនិងសម្រេចសេចក្តីតាមច្បាប់នីតិវិធីឡើយ។ ក្នុងករណីដែលឪពុកម្តាយគ្មានវិវាទអំពីអ្នកមានអំណាចមេបា គឺត្រូវនឹងករណី មាត្រា១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ដូចនេះ ផ្អែកតាមច្បាប់សារជាតុ តុលាការពុំត្រូវបានផ្តល់សិទ្ធិអំណាច ក្នុងការកំណត់អ្នកមានអំណាចមេបាឡើយ ដោយសារតែតុលាការពុំមានសិទ្ធិអំណាចតាមច្បាប់សារជាតុ ដូច្នេះមាត្រា២២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលជាច្បាប់នីតិវិធី គឺមិនត្រូវយកមកអនុវត្តបានឡើយ។

**២. ករណីការលែងលះដោយការព្រមព្រៀង**

**① ទ្រឹស្តី ក-២** : បន្ថែមពីលើការព្រមព្រៀងអំពីការលែងលះ (ករណីឪពុកម្តាយបានព្រមព្រៀងគ្នាអំពីអ្នកមានអំណាចមេបា) តុលាការគប្បីសម្រេចអំពីអ្នកមានអំណាចមេបា នៅក្នុងសេចក្តីសម្រេចបញ្ចប់ ព្រមគ្នាជាមួយនឹងដីកាសម្រេចលែងលះដោយការព្រមព្រៀង ដែលខ្លឹមសារនៃការសម្រេចនោះ គឺដូចគ្នាទៅនឹងខ្លឹមសារដែលត្រូវបានកំណត់តាមការពិភាក្សារបស់ឪពុកម្តាយ ផ្អែកតាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

ករណីដែលការពិភាក្សារបស់ឪពុកម្តាយ អំពីអ្នកមានអំណាចមេបា ពុំបានសម្រេច ឬ ពុំអាចពិភាក្សាបាន តាមច្បាប់សារជាតុ គឺពុំអាចលែងលះដោយការព្រមព្រៀងឡើយ (សូមអានគម្រោងមេរៀន ផ្នែកទី ១ ចំណុច ២) ។ ដូច



www.moj.gov.kh/kh/book-library

នេះ ករណីដែលមានវិវាទអំពីអ្នកមានអំណាចមេបាមិនអាចសម្រេចអំពីអ្នកមានអំណាចមេបា ផ្អែកតាមមាត្រា ១០៣៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី ព្រមគ្នាជាមួយនឹងដីកាសម្រេចលែងលះដោយការព្រមព្រៀងបានទេ ។

**【ទឡ្ហីករណ៍ទី ១】** ការបកស្រាយមាត្រា ១០៣៧ កថាខណ្ឌទី ១ និងទី ៣ នៃក្រមរដ្ឋប្បវេណី : ដូចគ្នាជាមួយនឹង ក-១ ។

**【ទឡ្ហីករណ៍ទី ២】** ការបកស្រាយទាក់ទងនឹងទម្រង់ និងការកើតមានអានុភាព នៃការកំណត់អ្នកមានអំណាចមេបា : ដូចគ្នាជាមួយនឹង ក-១ ។

**【ទឡ្ហីករណ៍ទី ៣】** ការបកស្រាយអំពីមូលហេតុនៃការមិនសរសេរ អំពីការកំណត់អ្នកមានអំណាចមេបានៅពេលលែងលះ នៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង :

យើងអាចពិចារណាបានថា មូលហេតុដែលការកំណត់អំពីអ្នកមានអំណាចមេបា នៃមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ពុំមានសរសេរនៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ពុំមែនដោយសារតែ មានគោលគំនិតថា ពុំអាចកំណត់អ្នកមានអំណាចមេបា តាមមាត្រាដដែលនេះបានទាំងស្រុងនោះទេ។ មូលហេតុដែលការកំណត់អ្នកមានអំណាចមេបា តាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ពុំមានសរសេរ នៅក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង គឺដោយសារតែមានគោលគំនិតថា នៅក្នុងករណីដែលមានវិវាទអំពីអ្នកមានអំណាចមេបា (ករណីមាត្រា ១០៣៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី) ត្រូវដោះស្រាយតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មិនមែនច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងឡើយ។

ដូចមានសរសេរនៅក្នុងផ្នែកទី ១ ចំណុច ២ នៃគម្រោងមេរៀន និង **【ទឡ្ហីករណ៍ទី ៣】** គឺ យោងតាមការបកស្រាយច្បាប់សារជាតុ អាចទាញបានថា ① ដើម្បីលែងលះដោយការព្រមព្រៀង ត្រូវតែមានការព្រមព្រៀងអំពីអ្នកមានអំណាចមេបា និង ② ការកំណត់អ្នកមានអំណាចមេបា ត្រូវតែធ្វើដោយសេចក្ដីសម្រេច។ មានន័យថា មូលដ្ឋាននៃការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា ជាមួយគ្នានឹងការសម្រេចអំពីការលែងលះដោយការព្រមព្រៀង គឺយោងតាមច្បាប់សារជាតុ។ មួយវិញទៀត ចំពោះមូលដ្ឋាននៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (ច្បាប់នីតិវិធី) យើងអាចពិចារណាបានដូចតទៅ : តាមច្បាប់សារជាតុ ការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា តាមមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី គឺត្រូវធ្វើជាមួយគ្នានឹងការសម្រេចអំពីការលែងលះដោយការព្រមព្រៀង ដូចនេះ ទោះបីជាគ្មានបញ្ញត្តិច្បាស់លាស់ ទាក់ទងនឹងការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា នៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងក៏ដោយ ក៏យើងមានបញ្ញត្តិផ្នែកទី ៤ ចំណុច ៥ នៃតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដែលជាមូលដ្ឋានដែរ ។

**② ទ្រឹស្ដី ខ-២** : (ករណីឪពុកម្ដាយបានពិភាក្សាគ្នាអំពីការអំណត់អ្នកមានអំណាចមេបា) អ្នកមានអំណាចមេបាត្រូវបានកំណត់ យោងតាមការពិភាក្សារបស់ឪពុកម្ដាយតែប៉ុណ្ណោះ ផ្អែកតាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។ តុលាការមិនត្រូវចេញសេចក្ដីសម្រេច អំពីការកំណត់អ្នកមានអំណាចមេបា នៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃដីកាសម្រេច ជាមួយគ្នានឹងដីកាសម្រេចអំពីការលែងលះដោយការព្រមព្រៀងឡើយ ។ (ករណីដែលការពិភាក្សារបស់ឪពុកម្ដាយ ស្ដីអំពីការកំណត់អ្នកមានអំណាចមេបា ពុំបានសម្រេច ឬ ពុំអាចពិភាក្សាបាន តាមច្បាប់សារជាតុ គឺពុំអាចលែងលះដោយការព្រមព្រៀងឡើយ ហេតុនេះ ដូចគ្នាជាមួយនឹង**ទស្សនៈ ក-២** ដែរ គឺមិនអាចកំណត់អ្នកមានអំណាចមេបា តាមមាត្រា ១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីបានឡើយ។ ម្យ៉ាងទៀត នៅក្នុងទស្សនៈ ខ-២ ក្រោយពីបានបកស្រាយតាមច្បាប់សារជាតុថា ការព្រមព្រៀងអំពីអ្នកមានអំណាចមេបា មិនមែនជាលក្ខខណ្ឌនៃការ



www.moj.gov.kh/kh/book-library

លែងលះដោយការព្រមព្រៀង ក៏មានទស្សនៈដែលពន្យល់ថា តាមច្បាប់នីតិវិធី ការព្រមព្រៀងអំពីអ្នកមានអំណាចមេបា គឺជាលក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង។ មូលហេតុដោយសារតែ **ទស្សនៈ ខ-២** ត្រូវបានបកស្រាយថា នៅក្នុងនីតិវិធិនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង តុលាការពុំអាចកំណត់អ្នកមានអំណាចមេបា ដែលមានចែងក្នុងមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ទាំងស្រុងតែម្ដង **【ទឡ្ហីករណ៍ទី ៥】** ដូច្នេះ ពុំអាចចេញសេចក្ដីសម្រេចអំពីអ្នកមានអំណាចមេបា ជាមួយគ្នានឹងការលែងលះដោយការព្រមព្រៀងឡើយ។)

**【ទឡ្ហីករណ៍ទី ១】** ការបកស្រាយទាក់ទងនឹងទម្រង់ និង ការកើតមានអានុភាព នៃការកំណត់អ្នកមានអំណាចមេបា : ដូចគ្នាជាមួយនឹង ខ-១ ។

**【ទឡ្ហីករណ៍ទី ២】** ការបកស្រាយមាត្រា ១០៣៧ កថាខណ្ឌទី១ និងទី៣ នៃក្រមរដ្ឋប្បវេណី : ដូចគ្នាជាមួយនឹង ខ-១ ។

**【ទឡ្ហីករណ៍ទី ៣】** ការបកស្រាយអំពីមូលហេតុនៃការមិនសរសេរ ការកំណត់អ្នកមានអំណាចមេបានៅពេលលែងលះ នៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង :

មានន័យថា តុលាការមិនអាចកំណត់អ្នកមានអំណាចមេបា តាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី នៅក្នុងដីកាសម្រេចនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងឡើយ។ ប្រសិនបើនីតិករនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង យល់ថាចាំបាច់ត្រូវតែសម្រេចសេចក្ដីអំពីអ្នកមានអំណាចមេបានៅក្នុងករណីចេញដីកាសម្រេចលែងលះនោះ នីតិករប្រាកដជាចែងនូវបទប្បញ្ញត្តិ ដូចគ្នានឹងមាត្រា២២ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលហើយ។

## បញ្ហាទី ២

ភាគីនៃអាពាហ៍ពិពាហ៍បានព្រមព្រៀងគ្នាអំពីការលែងលះ ប៉ុន្តែមានវិវាទអំពីអ្នកមានអំណាចមេបា តើតុលាការអាចសម្រេចអំពីការកំណត់អ្នកមានអំណាចមេបា នៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ជាមួយគ្នានឹងការសម្រេចអំពីការលែងលះដោយការព្រមព្រៀងដែរ ឬទេ? ឬម្យ៉ាងទៀត ក្នុងករណីនេះ តុលាការមិនអាចចេញដីកាសម្រេចអំពីការលែងលះដោយការព្រមព្រៀងបានទេ ហើយគប្បីតែកំណត់អ្នកមានអំណាចមេបា តាមរយៈសាលក្រម ដោយឱ្យភាគីដាក់ពាក្យបណ្ដឹងលែងលះ ឬ?

❁ បញ្ហាទី ២ ជាបញ្ហាដែលកើតឡើងក្នុងករណីជ្រើសរើស**ទ្រឹស្ដី ក-២** នៅក្នុងបញ្ហាទី ១ ប៉ុន្តែប្រសិនបើជ្រើសរើស**ទ្រឹស្ដី ខ** នៅក្នុងបញ្ហាទី១ នោះនឹងមិនមានបញ្ហានៃការបកស្រាយនេះទេ។ ទាំង**ទ្រឹស្ដី ក** និង **ទ្រឹស្ដី ខ** នៅក្នុងបញ្ហាទី១ គឺយល់ស្របដូចគ្នា ចំពោះការសម្រេចអំពីការកំណត់អ្នកមានអំណាចមេបាក្នុងករណីមិនមានការព្រមព្រៀងអំពីអ្នកមានអំណាចមេបា ហើយក៏មិនមានភាពផ្ទុយគ្នាចំពោះគំនិតនោះទេ។ បន្ថែមពីលើនេះ **ទ្រឹស្ដី ខ** ជាទ្រឹស្ដីដែលយល់ថា ការកំណត់អំពីអ្នកមានអំណាចមេបា តាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី នៅក្នុងនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង មិនអាចធ្វើទៅរួចជាដាច់ខាត (**ទ្រឹស្ដី ខ-២ 【ទឡ្ហីករណ៍ទី ៣】**)។ ហេតុនេះ ប្រសិនបើផ្អែកតាម**ទ្រឹស្ដី ខ** ហើយនៅក្នុងករណីដែលមានវិវាទអំពីអ្នកមានអំណាចមេបា តុលាការអាចកំណត់អំពីអ្នកមានអំណាចមេបាបាន លុះត្រាតែធ្វើឡើងតាមរយៈសាលក្រម នៅក្នុងនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលតែប៉ុណ្ណោះ។

**① ទ្រឹស្ដី ក-២-①** (ទ្រឹស្ដីដែលយល់ថា មិនអាចកំណត់អ្នកមានអំណាចមេបា នៅក្នុងនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ប្រសិនបើមានវិវាទអំពីអ្នកមានអំណាចមេបា) :

ទោះបីជាភាគីនៃអាពាហ៍ពិពាហ៍ព្រមព្រៀងអំពីការលែងលះក៏ដោយ ប្រសិនបើមានវិវាទអំពីអ្នកមានអំណាចមេបា គឺពុំអាចលែងលះដោយការព្រមព្រៀងបានឡើយ។ ហេតុនេះ តុលាការក៏មិនអាចចេញដីកាសម្រេចអំពីការ



www.moj.gov.kh/kh/book-library

កំណត់អ្នកមានអំណាចមេបា នៅក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងបានទេ។ ករណីនេះ ភាគីត្រូវដាក់ពាក្យបណ្តឹងលែងលះ ហើយតុលាការត្រូវកំណត់អ្នកមានអំណាចមេបា តាមរយៈសាលក្រម។

**【ទឡ្ហីយករណ៍】** :

យោងតាមការបកស្រាយនៃច្បាប់សារជាតុ (ម. ៩៧៩ នៃ ក.រ.ណ.) លក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀងគឺ ចាំបាច់ត្រូវមានការព្រមព្រៀងអំពីអ្នកមានអំណាចមេបា (សូមអានផ្នែកទី ១ ចំណុច ២ នៃគម្រោងមេរៀន) ហេតុនេះ ប្រសិនបើមានវិវាទអំពីអ្នកមានអំណាចមេបា មិនអាចលែងលះដោយការព្រមព្រៀងតាមច្បាប់សារជាតុបានឡើយ។ ម្យ៉ាងទៀត ការលែងលះ និង ការកំណត់អ្នកមានអំណាចមេបា ចាំបាច់ត្រូវធ្វើឡើងព្រមគ្នាគ្រប់ពេល។ ហេតុដូច្នេះ ករណីមានវិវាទអំពីអ្នកមានអំណាចមេបានៅពេលលែងលះ គឺមិនអាចលែងលះដោយការព្រមព្រៀងបានទេ ហេតុនេះតុលាការក៏មិនអាចកំណត់អំពីអ្នកមានអំណាចមេបា នៅក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងផងដែរ។

【តារាងនីតិវិធី】 ផ្អែកតាម**ទ្រឹស្តី ក-១, ទ្រឹស្តី ក-២-①** និង**ទ្រឹស្តី ខ** :

| **ល.រ** | **ស្ថានភាព** | **នីតិវិធី** | |
|---|---|---|---|
| | | នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល | នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង |
| **១** | មានការព្រមព្រៀងលែងលះ និង ការព្រមព្រៀងកំណត់អ្នកមានអំណាចមេបា | | ✓ |
| **២** | មានការព្រមព្រៀងលែងលះ និង គ្មានការព្រមព្រៀងកំណត់អ្នកមានអំណាចមេបា | ✓ | |

**② ទ្រឹស្តី ក-២-②** (ទ្រឹស្តីដែលយល់ថា ទោះមានវិវាទអំពីការកំណត់អ្នកមានអំណាចមេបាក៏ដោយ តុលាការអាចកំណត់អ្នកមានអំណាចមេបា នៅក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ជាមួយនឹងការលែងលះដោយការព្រមព្រៀងបាន) :

ករណីភាគីនៃអាពាហ៍ពិពាហ៍បានព្រមព្រៀងគ្នាអំពីការលែងលះ តុលាការអាចសម្រេចអំពីការលែងលះដោយការព្រមព្រៀងបាន ទោះបីជាមានវិវាទអំពីអ្នកមានអំណាចមេបាក៏ដោយ។ តុលាការ អាចសម្រេចអំពីការកំណត់អ្នកមានអំណាចមេបា នៅក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងជាមួយនឹងដីកាសម្រេចលែងលះដោយការព្រមព្រៀងបាន។

**【ទឡ្ហីយករណ៍】** :


www.moj.gov.kh/kh/book-library

តាមការបកស្រាយពាក្យពេចន៍នៃច្បាប់សារធាតុ (ម. ៩៧៩ នៃ ក.រ.ណ.) ពុំអាចបកស្រាយថា "លក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង គឺចាំបាច់ត្រូវតែមានការព្រមព្រៀងអំពីអ្នកមានអំណាចមេបា" ឡើយ ហើយក៏ពុំអាចបកស្រាយតាមទឡ្ហីករណ៍នៃ**ទ្រឹស្តី ក** បានដែរ ។

ការបកស្រាយនេះ គឺខុសពីគោលជំហរនៃ**ទ្រឹស្តី ក-២** នៃគម្រោងមេរៀន ដែលប្រកាន់យកការព្រមព្រៀងអំពីអ្នកមានអំណាចមេបា គឺជាលក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង។ ក៏ប៉ុន្តែប្រសិនបើប្រកាន់យកការបកស្រាយប្រដូចនឹង**ទ្រឹស្តី ក-២** ជាពិសេស**ទឡ្ហីករណ៍ទី ៣** ជាលទ្ធផល តុលាការ អាចកំណត់អ្នកមានអំណាចមេបា នៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងបាន ជាមួយនឹងដីកាសម្រេចលែងលះដោយការព្រមព្រៀង ។

ទោះបីជាមានវិវាទអំពីការកំណត់អ្នកមានអំណាចមេបាក៏ដោយ ប្រសិនបើមានការព្រមព្រៀងអំពីការលែងលះ ហើយភាគីបានដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង នោះតុលាការក៏អាចសម្រេចអំពីការកំណត់អ្នកមានអំណាចមេបា នៅក្នុងនីតិវិធីនៃការលែងលះដោយការព្រមព្រៀងបានដែរ។ ការធ្វើបែបនេះ អាចដោះស្រាយវិវាទបានឆាប់រហ័សជាង។ បន្ថែមពីលើនេះមានការយល់ឃើញថាការទាមទារចម្បងគឺជាការទាមទារលែងលះ ហើយការទាមទារបន្ទាប់បន្សំគឺការស្នើសុំកំណត់អំពីអ្នកមានអំណាចមេបា ហេតុនេះនៅពេលដែលការលែងលះដោយការព្រមព្រៀង អាចធ្វើឡើងនៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហេតុនេះការទាមទារបន្ទាប់បន្សំដែលជាការស្នើសុំកំណត់អ្នកមានអំណាចមេបាគប្បីត្រូវបានធ្វើឡើងនៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងផងដែរ។ ប្រសិនបើគ្រាន់តែភាគីមានវិវាទពីការកំណត់អ្នកមានអំណាចមេបា ហើយបែរជាតម្រូវឱ្យភាគីដកពាក្យសុំ ទៅដាក់ពាក្យបណ្តឹងលែងលះ តាមនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល គឺមិនមានភាពប្រាកដ ហើយបង្កការលំបាកដល់ភាគី។

**【តារាងនីតិវិធី】 ផ្អែកតាមទ្រឹស្តី ក-២-②** :

| **ល.រ** | **ស្ថានភាព** | **នីតិវិធី** | |
|---|---|---|---|
| | | នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល | នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង |
| **១** | មានការព្រមព្រៀងលែងលះ និង ការព្រមព្រៀងកំណត់អ្នកមានអំណាចមេបា | | ✓ |
| **២** | មានការព្រមព្រៀងលែងលះ និង គ្មានការព្រមព្រៀងកំណត់អ្នកមានអំណាចមេបា | | ✓ |


www.moj.gov.kh/kh/book-library

❖ ទំនាក់ទំនងជាមួយនឹងឯកសារបង្រៀនផ្សេងទៀត

**សៀវភៅមេរៀននេះ ត្រូវបានតាក់តែងឡើងដោយផ្អែកតាមទ្រឹស្តីក ដែលមានទ្រឹស្តី ក-១, ទ្រឹស្តី ក-២-①**។ ការពន្យល់របស់ទម្រង់គំរូ នៅក្នុងជំពូកទី៤ នៃឯកសារបង្រៀននេះ ត្រូវបានសរសេរដោយឈរលើគោលជំហរនៃ **ទ្រឹស្តី ក-១** និង **ក-២-①** ។



www.moj.gov.kh/kh/book-library

## ឧបសម្ព័ន្ធទី ៣ :

## រូបមន្តគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

## ករណីប្រទេសជប៉ុន

I. របៀបគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (១) ករណីប្រទេសជប៉ុន

1. យកចំនួនទឹកប្រាក់នៃចំណូលជាក់ស្តែងរបស់ភាគីសងខាងនៃអ្នកមានអំណាចមេបា ( B ) និងឪពុក ឬម្តាយដែលមិនមានជាអ្នកមានអំណាចមេបា (A) ធ្វើជាមូលដ្ឋាន។

ឧទាហរណ៍ : ចំណូលរបស់ A ប្រចាំខែចំនួន ១២០០ ដុល្លារអាម៉េរិក ចំណូលរបស់ B ចំនួន ៦០០ ដុល្លារអាម៉េរិក

2. ធ្វើការត្រូវគណនាថា ដោយសន្មត ឬ ស្រមើស្រម៉ៃថា ប្រសិនបើឪពុក ឬម្តាយដែលមិនមែនជាអ្នកមានអំណាចមេបានៅតែបន្តរស់នៅជាមួយកូនបន្ទាប់ពីលែងលះរួច តើចំនួនទឹកប្រាក់ប៉ុន្មាន នៅក្នុងចំណោមប្រាក់ចំណូលសរុបនៃចំណូលរបស់ខ្លួន និងចំណូលរបស់ឪពុក ឬម្តាយម្ខាងទៀត ដែលត្រូវយកមកប្រើប្រាស់សម្រាប់កូន។

ឧទាហរណ៍ : នៅក្នុងចំណោមចំណូលសរុបរបស់ A និង B គឺ ១៨០០ ដុល្លារអាម៉េរិក ហើយចំនួនទឹកប្រាក់ ដែលត្រូវយកមកប្រើប្រាស់សម្រាប់ C ជាប្រចាំខែគឺ ៥០០ ដុល្លារអាម៉េរិក។

3. ចំនួនទឹកប្រាក់ដែលប្រើប្រាស់សម្រាប់កូន ដែលបានគណនាឃើញនៅចំណុច 2 ខាងលើ យកមកបែងចែកតាមសមាមាត្រភាគរយនៃចំណូលរបស់អ្នកមានអំណាចមេបា និងឪពុក ឬម្តាយដែលមិនមានជាអ្នកមានអំណាចមេបា ។ ជារួម ដើម្បីជានាចំនួនទឹកប្រាក់ចាំបាច់សម្រាប់កូន គេធ្វើការគណនាថា ឪពុកម្តាយចាំបាច់ត្រូវទទួលបន្ទុកប៉ុន្មានក្នុងម្នាក់ ទៅតាមសមាមាត្រភាគរយនៃចំណូល។

ឧទាហរណ៍ :

សោហ៊ុយចាំបាច់ ដែល A ត្រូវទទួលបន្ទុក : 500×(1200÷(1200+600))=333.33

សោហ៊ុយចាំបាច់ ដែល B ត្រូវទទួលបន្ទុក : 500×(600÷(1200+600))=166.66

4. ចំនួនទឹកប្រាក់ដែល ឪពុក ឬម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាត្រូវទទួលបន្ទុកនោះ ត្រូវបង់ឱ្យអ្នកមានអំណាចមេបា។

ឧទាហរណ៍ : A ត្រូវបង់ឱ្យ B 333.3 ដុល្លារអាម៉េរិកជាប្រចាំខែ។

នៅប្រទេសជប៉ុន ផ្អែកតាមទស្សនៈជាមូលដ្ឋាននៃការគណនាខាងលើ ត្រូវពិចារណាដល់ចំនួនទឹកប្រាក់នៃពន្ធ ជាអាទិ៍ រួចប្រើប្រាស់តារាងគណនាដែលមានភាពស្មុគស្មាញដែលត្រូវបានបង្កើតឡើងដោយក្រុមការងារស្រាវជ្រាវរបស់ចៅក្រម ផ្អែកតាមទ្រឹស្តី និងឯកសារស្ថិតិ ជាអាទិ៍ដែលយោងតាមច្បាប់ស្តីពីពន្ធ ជាអាទិ៍។

II. របៀបគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (2) ករណីប្រទេសជប៉ុន

1. សាវតានៃការបង្កើត "តារាងគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន"នៅប្រទេសជប៉ុន
   - គោលការណ៍ទូទៅនៃវិធីគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូននៅប្រទេសជប៉ុន
     A) ដកថ្លៃពន្ធ សោហ៊ុយចាំបាច់ដើម្បីទទួលប្រាក់ចំណូល និងសោហ៊ុយចាំបាច់ពិសេសសម្រាប់ជីវភាពពីចំណូលសរុបរបស់អ្នកមានករណីយកិច្ច (អ្នកត្រូវបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន) និងអ្នកមានសិទ្ធិ (អ្នកទទួលសោហ៊ុយចាំបាច់ដើម្បីគ្រង់គ្រងថែរក្សាកូន) (ហៅថា "ចំណូលមូលដ្ឋាន")។
     B) កំណត់សោហ៊ុយជីវភាពអប្បបរមានីមួយៗរបស់អ្នកមានករណីយកិច្ច អ្នកមានសិទ្ធិ និងកូន។



www.moj.gov.kh/kh/book-library

C) កំណត់សមត្ថភាពទទួលបន្ទុករបស់អ្នកមានករណីយកិច្ច និងអ្នកមានសិទ្ធិ។

D) បែងចែកចំណូលមូលដ្ឋានរបស់អ្នកមានករណីយកិច្ចទៅតាមសមាមាត្រនៃចំណាយជីវភាពអប្បបរមារបស់អ្នកមានករណីយកិច្ច និងកូន ។ តាមរយៈការបែងចែកនេះ តុលាការត្រូវគណនាសោហ៊ុយជីវភាពដែលជាសោហ៊ុយសម្រាប់កូន ដោយគិតសន្មតក្នុងករណីដែលអ្នកមានករណីយកិច្ចរស់នៅជុំគ្នាជាមួយកូន។

E) បែងចែកសោហ៊ុយជីវភាពរបស់កូនទៅតាមសមាមាត្រនៃចំណូលមូលដ្ឋានរបស់អ្នកមានករណីយកិច្ច និងអ្នកមានសិទ្ធិទាំងសងខាង។

- ការគណនាខាងលើ ចាំបាច់ត្រូវឆ្លងកាត់ការគណនាដែលមានលក្ខណៈស្មុគស្មាញ ហេតុនេះ ភាគីពិបាកក្នុងការប៉ាន់ស្មានទុកជាមុនអំពីលទ្ធផលនៃការគណនានោះ ។ ម្យ៉ាងទៀត ដោយសារតែថ្លៃពន្ធ និងថ្លៃចំណាយផ្សេងៗដែលត្រូវពិចារណា ត្រូវបានកំណត់តាមទិដ្ឋភាពនៃតម្លៃជាក់ស្តែង ធ្វើឱ្យមានវិវាទអំពីទំហំនិងតម្លៃនៃចំណាយទាំងនោះ និងធ្វើឱ្យការវិនិច្ឆ័យសេចក្តីត្រូវចំណាយពេលវេលាយូរផងដែរ។
- ដោយហេតុនេះហើយ តាមរយៈការស្រាវជ្រាវរបស់ក្រុមដែលមានចៅក្រមជាដើមជាសមាជិក ធ្វើឱ្យមានការគណនាតម្លៃសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងរក្សាកូនតាមស្តង់ដារទូទៅដែលឆ្លើយតបទៅនឹងចំណូលរបស់ឪពុកម្តាយ និងអាយុរបស់កូនជាដើម រួចចងក្រងជា "តារាងគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន" ។ "តារាងគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន" គឺជាតារាងសង្ខេបនៃលទ្ធផលដែលបានគណនាដោយប្រើគោលគំនិតដែលមានពន្យល់នៅក្នុងចំណុច 2 ខាងក្រោម។ ហេតុនេះ គោលគំនិតនៅក្នុងចំណុច 2 គឺជាចំណុចសំខាន់។

2. គោលគំនិតដែលជាមូលដ្ឋាននៃ "តារាងគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន"

2.1 ការសន្មតទី១ : ការគណនាចំណូលជាមូលដ្ឋានតាមស្តង់ដារទូទៅ

ចំណូលជាមូលដ្ឋានតាមស្តង់ដារទូទៅ

＝តម្លៃដែលបានដកសមាមាត្រស្តង់ដារទូទៅនៃចំណុច①②③ខាងក្រោមពីតម្លៃចំណូលសរុប

① សមាមាត្រស្តង់ដារទូទៅនៃពន្ធដារជាដើម (ពន្ធលើប្រាក់ចំណូល ពន្ធពលរដ្ឋ ប្រាក់ធានារ៉ាប់រងសង្គម) ធៀបទៅនឹងចំណូលប្រចាំឆ្នាំ

- គណនាឱ្យបានសមហេតុផលទៅតាមច្បាប់ស្តីពីពន្ធដារជាដើម។
- ករណីអ្នកជាប់ពន្ធលើប្រាក់បៀវត្សន៍ ភាគច្រើន 8～35%នៃប្រាក់ចំណូលប្រចាំឆ្នាំ(ចំណូលប្រចាំឆ្នាំកាន់តែខ្ពស់ សមាមាត្រនៃប្រាក់ពន្ធទៅនឹងចំណូលប្រចាំឆ្នាំកាន់តែខ្ពស់)

② សមាមាត្រស្តង់ដារទូទៅនៃសោហ៊ុយចាំបាច់ដើម្បីទទួលបានចំណូល (សំលៀកបំពាក់ សោហ៊ុយធ្វើដំណើរនិងទូរគមនាគមន៍ សៀវភៅ ចំណាយកំប៉ិកកំប៉ុក សោហ៊ុយផ្សេងៗសម្រាប់ទំនាក់ទំនង ជាដើម) ធៀបទៅនឹងចំណូលប្រចាំឆ្នាំ

- ប៉ាន់ស្មានដោយផ្អែកលើទិន្នន័យស្ថិតិជាមធ្យម ("ចំណូលនិងចំណាយប្រចាំខែជាមធ្យមក្នុងមួយគ្រួសារតាមកម្រិតចំណូលប្រចាំឆ្នាំ") រយៈពេល 5 ឆ្នាំចុងក្រោយ។
- សម្រាប់បុគ្គលដែលធ្វើការយកប្រាក់ខែ សមាមាត្រនៃសោហ៊ុយនេះធៀបទៅនឹងចំណូលប្រចាំឆ្នាំគឺប្រហែល 18-13% (ប្រាក់ចំណូលប្រចាំឆ្នាំកាន់តែទាប សមាមាត្រនៃសោហ៊ុយនេះធៀបទៅនឹងចំណូលប្រចាំឆ្នាំកាន់តែខ្ពស់)។

③ សមាមាត្រស្តង់ដារទូទៅនៃការចំណាយដែលចាំបាច់ជាពិសេសសម្រាប់ជីវិតប្រចាំថ្ងៃ (សោហ៊ុយចាំបាច់



www.moj.gov.kh/kh/book-library

សម្រាប់លំនៅឋាន ការធានារ៉ាប់រង និងថ្លៃព្យាបាល ជាអាទិ៍) ធៀបទៅនឹងប្រាក់ចំណូលប្រចាំឆ្នាំ

➢ ប៉ាន់ស្មានដោយផ្អែកលើទិន្នន័យស្ថិតិជាមធ្យម ("ចំណូលនិងចំណាយប្រចាំខែជាមធ្យមក្នុងមួយគ្រួសារតាមកម្រិតចំណូលប្រចាំឆ្នាំ") រយៈពេល5 ឆ្នាំចុងក្រោយ។

➢ សម្រាប់បុគ្គលដែលធ្វើការយកប្រាក់ខែ ភាគរយនៃសោហ៊ុយនេះធៀបទៅនឹងចំណូលប្រចាំឆ្នាំ គឺប្រហែល 20-14% (ប្រាក់ចំណូលប្រឆ្នាំចាំឆ្នាំកាន់តែទាប សមាមាត្រនៃសោហ៊ុយនេះធៀបទៅនឹងចំណូលប្រចាំកាន់តែខ្ពស់)។

➡ចំណូលមូលដ្ឋានសម្រាប់ករណីអ្នកធ្វើការយកប្រាក់ខែគឺភាគច្រើន 54～38%នៃចំណូលប្រចាំឆ្នាំ [100% － (①8%～35%＋②18%～13%＋③20%～14%) ] ＝54%～38%។

2.2 ការសន្មតទី២ : ការគណនាសន្ទស្សន៍ថ្លៃចំណាយសម្រាប់ជីវភាពរបស់កូន

សន្ទស្សន៍ថ្លៃចំណាយសម្រាប់ជីវភាពរបស់កូន

＝សន្ទស្សន៍ដើម្បីគណនាថ្លៃចំណាយជីវភាពស្តង់ដារទូទៅសម្រាប់កូន។

បន្ថែមការចំណាយលើការអប់រំស្តង់ដារទូទៅទៅលើការចំណាយចាំបាច់អប្បបរមាសម្រាប់ជីវភាព។ បន្ទាប់មក សន្ទស្សន៍សោហ៊ុយជីវភាពសម្រាប់មនុស្សពេញវ័យត្រូវបានកំណត់ជា 100 ហើយសន្ទស្សន៍សម្រាប់កូនត្រូវបានកំណត់ដោយការធៀបជាមួយសន្ទស្សន៍នេះ។

➢ ការចំណាយចាំបាច់អប្បបរមាសម្រាប់ជីវភាពត្រូវគណនាដោយប្រើស្តង់ដារនៃការធានាសុខុមាលភាព[43]។

➢ ការចំណាយលើការអប់រំស្តង់ដារទូទៅត្រូវគណនាដោយផ្អែកលើ "តារាងស្ថិតិនៃការស្ទង់មតិលើការចំណាយលើការសិក្សារបស់កុមារ" ដែលបង្កើតឡើងដោយក្រុមស្រាវជ្រាវ។

➡សន្ទស្សន៍ថ្លៃចំណាយជីវភាពសម្រាប់កូនគឺ

ករណីកូនអាយុ 0～14 ឆ្នាំ តួលេខសន្ទស្សន៍គឺ 62។

ករណីកូនអាយុ 15～19 ឆ្នាំ តួលេខសន្ទស្សន៍គឺ 85

2.3 ការគណនាសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូន

- សន្មតថាអ្នកមានកាតព្វកិច្ច (ម្តាយ ឬឪពុកដែលត្រូវទទួលបន្ទុកលើការចំណាយចាំបាច់សម្រាប់ការគ្រប់គ្រងថែរក្សាកូន) រស់នៅជាមួយកូន ត្រូវគណនាតម្លៃនៃការចំណាយសម្រាប់ជីវភាពដែលត្រូវចាយលើកូនពីប្រាក់ចំណូលមូលដ្ឋានរបស់អ្នកមានកាតព្វកិច្ច ដោយប្រើសន្ទស្សន៍ថ្លៃចំណាយសម្រាប់ជីវភាព។ បន្ទាប់មក តម្លៃនៃការចំណាយសម្រាប់ជីវភាពដែលត្រូវចាយលើកូន ត្រូវបែងចែកតាមសមាមាត្រដោយផ្អែកលើប្រាក់ចំណូលមូលដ្ឋានរៀងៗខ្លួនរបស់អ្នកមានសិទ្ធិ (ម្តាយ ឬឪពុកដែលត្រូវទទួលចំណាយចាំបាច់សម្រាប់ការគ្រប់គ្រងថែរក្សាកូន) និងអ្នកមានកាតព្វកិច្ច ដើម្បីគណនាតម្លៃនៃការចំណាយចាំបាច់សម្រាប់ការគ្រប់គ្រងថែរក្សាកូនដែលអ្នកមានកាតព្វកិច្ចត្រូវបង់។[44]

【រូបមន្តគណនា】

---

[43] ការធានាសុខមាលភាព គឺជាប្រព័ន្ធផ្តល់ជំនួយដែលរដ្ឋផ្តល់ប្រាក់ឧបត្ថមលើសោហ៊ុយចំណាយចាំបាច់ដើម្បីរក្សាជីវភាពក្នុងកម្រិតអប្បបរមាចំពោះប្រជាពលរដ្ឋដែលមានជីវភាពក្រលំបាក។ ស្តង់ដារនៃការការធានាសុខមាលភាព ជាចំនួនទឹកប្រាក់នៃសោហ៊ុយចាំបាច់ដើម្បីរក្សាជីវភាពក្នុងកម្រិតអប្បបរមា និងត្រូវកំណត់ដោយរដ្ឋ។

[44] នៅប្រទេសជប៉ុន នៅពេលគណនាសោហ៊ុយចាំបាច់ដើម្បីគ្រង់គ្រងថែរក្សាកូន តុលាការពិចារណាអំពីថ្លៃពន្ធ ការចំណាយអប្បបរមាចាំបាច់ជាពិសេសសម្រាប់មុខរបរ និងជីវភាព ជាដើម។ មានវិធីជាច្រើនក្នុងការពិចារណាថាតើវិសាលភាពនៃថ្លៃពន្ធ និងការចំណាយនានាគួរគិតត្រឹមកម្រិតណា ដូច្នេះការពន្យល់ ដោយប្រើពាក្យយ៉ាងសាមញ្ញថា "ផ្អែកលើចំនួនទឹកប្រាក់នៃចំណូលជាក់ស្តែង" ។



www.moj.gov.kh/kh/book-library

① ការគណនាចំណូលមូលដ្ឋានស្តង់ដារទូទៅ (2.1) :

(ចំណូលប្រចាំឆ្នាំ) × (54～38%)

② ការគណនាសោហ៊ុយចាំបាច់សម្រាប់ជីវភាពកូនដែលត្រូវបង់ដោយគិតសន្មតក្នុងករណីដែលអ្នកមានករណីយកិច្ចរស់នៅជុំគ្នាជាមួយកូន :

(ចំណូលមូលដ្ឋានរបស់អ្នកមានករណីយកិច្ច) × (សន្ទស្សន៍នៃសោហ៊ុយជីវភាពរបស់កូន) : (សន្ទស្សន៍សោហ៊ុយជីវភាពរបស់អ្នកមានករណីយកិច្ច+សន្ទស្សន៍នៃសោហ៊ុយជីវភាពរបស់កូន)

③ ចែកសោហ៊ុយជីវភាពរបស់កូន (②) ទៅនឹងចំណូលមូលដ្ឋានរបស់អ្នកមានករណីយកិច្ច និងអ្នកមានសិទ្ធិ (①) ហើយគណនាតាមការគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដែលត្រូវបង់ដោយអ្នកមានករណីយកិច្ចទៅអ្នកមានសិទ្ធិ :

② × (ចំណូលមូលដ្ឋានរបស់អ្នកមានករណីយកិច្ច) : (ចំណូលមូលដ្ឋានរបស់អ្នកមានករណីយកិច្ច+ចំណូលមូលដ្ឋានរបស់អ្នកមានសិទ្ធិ)

3. 「តារាងគណនាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន」

- លទ្ធផលនៃការគណនាក្នុង 2.3 ត្រូវបានសង្ខេបជាទម្រង់តារាងក្នុង "តារាងគណនាសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូន"។ "តារាងគណនាសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូន" ត្រូវបានបែងចែកជា ៩ប្រភេទ ឆ្លើយតបទៅនឹងចំនួនកូន (ប្រភេទកូន១ ដល់ប្រភេទកូន៣) និងអាយុរបស់កូន (ប្រភេទកូនអាយុ 0～14ឆ្នាំ និង 15～19 ឆ្នាំ)។

  【ឧទាហរណ៍】"តារាងសម្រាប់ករណីកូនមាន៣នាក់ កូនទី១ និងកូនទី២ មានអាយុលើស១៥ឆ្នាំ និងកូនទី៣មានអាយុ 0～14ឆ្នាំ」

  https://www.courts.go.jp/vc-files/courts/file5/youiku-8.pdf

  (តារាងលេខ ៨ នៃតារាងគណនាសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូន "របាយការណ៍ស្តីពីការស្រាវជ្រាវលើការគណនាការចំណាយចាំបាច់ដើម្បីការគ្រប់គ្រងថែរក្សាកូន និងការចំណាយលើអាពាហ៍ពិពាហ៍" នៅក្នុងគេហទំព័ររបស់តុលាការកំពូល)

- នៅក្នុងតារាងនេះ ចំណូលប្រចាំឆ្នាំរបស់អ្នកមានករណីយកិច្ចត្រូវបានបង្ហាញនៅលើអ័ក្សឈរ ហើយចំណូលប្រចាំឆ្នាំរបស់អ្នកមានសិទ្ធិត្រូវបានបង្ហាញនៅលើអ័ក្សដេក ។ ជ្រើសរើសចំណូលប្រចាំឆ្នាំសម្រាប់ភាគីនីមួយៗ ហើយមើលចំណុចប្រសព្វនៃអ័ក្សទាំងពីរ អ្នកនឹងឃើញតម្លៃដែលជាលទ្ធផលដែលបានគណនាដោយប្រើ [រូបមន្ត] ខាងលើ ([ឧទាហរណ៍] "100,000 ទៅ 120,000 យ៉េន")។ នេះជាគោលការណ៍ណែនាំសម្រាប់គណនាចំនួនទឹកប្រាក់នៃសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដែលអ្នកមានករណីយកិច្ចត្រូវបង់ទៅអ្នកមានសិទ្ធិ។
- ចំនួនទឹកប្រាក់ចុងក្រោយ នឹងត្រូវបានកំណត់ដោយតុលាការក្នុងកម្រិតនេះដោយពិចារណាអំពីកាលៈទេសៈផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានពន្យល់ក្នុងចំណុច 2 ខាងលើ អ្នកស្រាវជ្រាវបានពិចារណាអំពីកាលៈទេសៈផ្សេងៗនៅពេលបង្កើតតារាងនេះរួចហើយ ដូច្នេះ តុលាការអាចសម្រេចក្នុងចំនួនទឹកប្រាក់ខុសពីតារាងនេះ លុះត្រាតែមានកាលៈទេសៈពិសេស។
- ករណីខ្លះតុលាការអាចគណនាជាលក្ខណៈដោយឡែកតាមគោលគំនិតដែលជាគោលការណ៍នៅក្នុងចំណុច 1 ទៅតាមករណីជាក់ស្តែងនីមួយៗ។



www.moj.gov.kh/kh/book-library

## ឧបសម្ព័ន្ធទី ៤ :
## អានុភាពនៃដីកាសម្រេច
## តើអានុភាពដីកាសម្រេច កើតមាននៅពេលណា?

ជាគោលការណ៍ ដីកាសម្រេចនឹងមានអានុភាព នៅពេលដែលបានជូនដំណឹងតាមវិធីដែលទទួលស្គាល់ថាសមរម្យ (ម. ២១៣ ក. ១ នៃ ក.ន.ណ.)។

ក៏ប៉ុន្តែ ច្បាប់ក៏មានករណីដែលចែងពិសេសអំពីវិធីបង្កើតអានុភាពនៃដីកាសម្រេចដែរ គឺដីកាសម្រេច ពុំមានអានុភាព បើមិនទាន់ចូលជាស្ថាពរ ឧ. ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ (ម. ៤៥០ ក. ៥ នៃ ក.ន.ណ.), ដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យលក់ (ម. ៤៤៤. ក. ៤ នៃ ក.ន.ណ.) និង ដីកាសម្រេចនៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ម. ៣, ម. ៤ និង ម. ៣៧ ក. ៣ នៃ ច.ន.ម.)។

បន្ថែមពីលើនេះ ក្រមនីតិវិធីរដ្ឋប្បវេណី ក៏បញ្ញត្តពិសេសពាក់ព័ន្ធនឹងការបញ្ជូនដីកាសម្រេចផង ដូចជា ដីកាសម្រេចដាស់តឿន (ម. ៣២៥ ក. ១ នៃ ក.ន.ណ. "ត្រូវបញ្ជូនទៅកូនបំណុល"), ដីកាសម្រេចរក្សាការពារ (ម. ៥៤៣ នៃ ក.ន.ណ.), ដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ (ម. ៥៥៧ ក. ៣, ក. ៧ និង ក. ៨ នៃ ក.ន.ណ.)។

## តើការជូនដំណឹង អាចធ្វើបានតាមវិធីណាខ្លះ?

ជាគោលការណ៍ ការជូនដំណឹងអាចធ្វើបានតាមវិធី ដែលអាចទទួលស្គាល់ថាសមរម្យ (ម. ២១៣ ក. ១ នៃ ក .ន.ណ.)។ មានន័យថា ការជូនដំណឹង អាចធ្វើបានតាមវិធីដែលតុលាការអាចទទួលស្គាល់ថាសមរម្យ ដែលមានដូចជា ការបញ្ជូន ឬ ការផ្ញើជូនដីកាសម្រេច ឬ ការប្រកាសដោយផ្ទាល់មាត់ ជាអាទិ៍។ ក៏ប៉ុន្តែ ក៏មានករណីដែលច្បាប់បញ្ញត្តថាត្រូវជូនដំណឹង តាមរយៈការបញ្ជូន ឬ ការផ្ញើជូនដីកាសម្រេចដែរ។ ឧទាហរណ៍ ដីកាសម្រេចនៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង គឺត្រូវជូនដំណឹងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេច (ម. ៣៦ នៃ ច.ន.ម.)។



www.moj.gov.kh/kh/book-library

## ឧបសម្ព័ន្ធទី ៥ :

## ការពន្យល់អំពីទស្សនៈនៃការទាមទារអាហារកិច្ច

មានទស្សនៈចំនួន ២ (ពីរ) ទាក់ទងនឹងបញ្ហាថាតើគេអាចទាមទារអាហារកិច្ចនៅក្នុងបណ្តឹងរួមគ្នាជាមួយនឹងការទាមទារលែងលះឬទេដូចខាងក្រោម :

① ទស្សនៈដែលយល់ឃើញថា មិនអាចដាក់ពាក្យបណ្តឹងរួមគ្នាជាមួយការទាមទារលែងលះ : ការទាមទារអាហារកិច្ចមិនមែនជាការទាមទារសំណងការខូចខាតទេ ហេតុនេះវាមិនមែនជាការទាមទារដូចដែលមានចែងនៅក្នុងមាត្រា ១១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានខ្លឹមសារថា "ការទាមទារពាក់ព័ន្ធនឹងសំណងការខូចខាត ដែលកើតមានឡើងដោយអង្គហេតុ ដែលជាមូលហេតុនៃការទាម ទារទាក់ទងនឹងឋានៈបុគ្គលនោះ" នោះទេ។ ម្យ៉ាងទៀត ការទាមទារអាហារកិច្ច ក៏មិនមែនជាការចាត់ចែងបន្ទាប់បន្សំដែលមានចែងនៅក្នុង មាត្រា ២២ កថាខណ្ឌទី ១ នៃ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែរ។

② ទស្សនៈដែលយល់ឃើញថា អាចដាក់ពាក្យបណ្តឹងទាមទាររួមគ្នាជាមួយការទាមទារលែងលះ : តាមរយៈការបកស្រាយពាក្យ "ការទាមទារពាក់ព័ន្ធនឹងសំណងការខូចខាត ដែលកើតមានឡើងដោយអង្គហេតុ ដែលជាមូលហេតុនៃការទាមទារទាក់ទងនឹងឋានៈបុគ្គលនោះ" ដែលមានចែងនៅក្នុងមាត្រា១១ នៃ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល គេអាចទាមទាររួមគ្នាជាមួយនឹងការទាមទារលែងលះបាន។ នេះមានន័យថា នៅក្នុងទំនាក់ទំនងការទាមទារលែងលះ (ការទាមទារទាក់ទងនឹងនីតិវិធីទាក់ទងនឹងឋានៈបុគ្គល) ការទាមទារអាហារកិច្ច អាចបកស្រាយថាត្រូវបានរាប់បញ្ចូលក្នុង "ការទាមទារពាក់ព័ន្ធនឹងសំណងការខូចខាត ដែលកើតមានឡើងដោយអង្គហេតុ ដែលជាមូលហេតុនៃការទាមទារទាក់ទងនឹងឋានៈបុគ្គលនោះ"។ ការពន្យល់ត្រង់ចំណុចនេះអាចធ្វើឡើងដូចខាងក្រោម :

បណ្តឹងទាក់ទងនឹងឋានៈបុគ្គល (នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល) និង ការទាមទារពាក់ព័ន្ធ (នីតិវិធីរដ្ឋប្បវេណី) ជានីតិវិធីប្រភេទផ្សេងគ្នា ហេតុនេះយោងតាមមាត្រា ៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនអាចរួមបញ្ចូលគ្នានៅក្នុងបណ្តឹងតែមួយបានទេ ។ ប៉ុន្តែ ការទាមទារពាក់ព័ន្ធជាមូលដ្ឋាននៃមូលហេតុនៃការទាមទារនៅក្នុងនីតិវិធីទាក់ទងនឹងឋានៈបុគ្គល ហើយនៅក្នុងការវិនិច្ឆ័យទៅលើការទាមទារទាំងពីរនេះមានទំនាក់ទំនងគ្នាជិតស្និទ្ធក្នុងការអះអាង និងការបញ្ជាក់ភស្តុតាង ដូច្នេះហើយការអនុញ្ញាតឱ្យបញ្ចូលគ្នានូវការទាមទារពាក់ព័ន្ធជាមួយនឹងការទាមទារនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឬការអនុញ្ញាតឱ្យប្តឹងតបគឺអាចសម្រួលក្នុងការបញ្ជាក់ភស្តុតាង ព្រមទាំងស្របទៅនឹងសេដ្ឋកិច្ចក្នុងការធ្វើបណ្តឹងផងដែរ។ ហេតុនេះ មាត្រា១១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវចាត់ទុកថាជាបទប្បញ្ញត្តិលើកលែងនៃមាត្រា ៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងទទួលស្គាល់ការទាមទារពាក់ព័ន្ធអាចរួមបញ្ចូលគ្នាជាមួយនឹងការទាមទារលែងលះបាន។ ម្យ៉ាងទៀត ប្រសិនបើពិចារណាលើការទាមទារអាហារកិច្ច កម្មវត្ថុនៃការវិនិច្ឆ័យអំពីការទាមទារអាហារកិច្ច គឺចំណុចស្តីពីអត្ថិភាព ឬនត្ថិភាពនៃកំហុសរបស់អ្នកទាមទារ នៅក្នុងការលែងលះ និង ភាពចាំបាច់នៅក្នុងការបង់ថ្លៃអាហារកិច្ច ជាដើម (កម្រិតសេដ្ឋកិច្ចរបស់ប្តីប្រពន្ធ ឬកម្រិតនៃភាពក្រីក្រជាដើម)។ ចំណុចទាំងនេះអាចនិយាយបានថា មានទំនាក់ទំនងគ្នាជិតស្និទ្ធក្នុងការអះអាង និងការបញ្ជាក់ភស្តុតាង ដោយហេតុថាមានចំណុចដូចគ្នាជាច្រើន ដូចជាមានមូលហេតុនៃការលែងលះ ដែលមានចែងក្នុង មាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី និងមានមូលហេតុនៃការច្រានចោលការទាមទារលែងលះ ដែលមានចែងនៅក្នុង មាត្រា ៩៧៨ កថាខណ្ឌទី ២ និងទី ៣ នៃ



www.moj.gov.kh/kh/book-library

ក្រមរដ្ឋប្បវេណី។ លើសពីនេះ នៅពេលតាក់តែងក្រមរដ្ឋប្បវេណី អាហារកិច្ចត្រូវបានពិចារណាថាអាចដោះស្រាយបានតាមរយៈប្រាក់សំណងជំងឺចិត្ត (ការទាមទារសំណងការខូចខាតដោយអំពើអនីត្យានុកូល) (សេចក្តីកំណត់មាត្រា ៧៨ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី)។ បើពិចារណាត្រង់ចំណុចនេះ ការអនុញ្ញាតឱ្យបណ្តឹងទាមទារអាហារកិច្ច អាចធ្វើឡើងរួមគ្នាជាមួយនឹងការទាមទារលែងលះ គឺស៊ីសង្វាក់គ្នាជាមួយគោលគំនិតនៃ មាត្រា ១១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ ហេតុនេះ តាមរយៈការបកស្រាយមាត្រា ១១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល គេអាចរួមបញ្ចូលការទាមទារអាហារកិច្ច ជាមួយនឹងការទាមទារលែងលះបាន។



www.moj.gov.kh/kh/book-library

# ឯកសារយោង

ក. បទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណី, ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី, ព្រះរាជក្រម លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦
- ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, ព្រះរាជក្រម លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០
- ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, ព្រះរាជក្រម លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០
- ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី, ព្រះរាជក្រម លេខ នស/រកម/០៥១១/០០៧, ០៩ ឧសភា ២០១០
- ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់ លេខ ០៥៦ ក្រ., ២៦ កក្កដា ១៩៨៩
- ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៥៩ ប្រក.ដ.ន.ស/១១, ០៣ ឧសភា ២០១១

ខ. ស្នាដៃសៀវភៅ អត្ថបទ ឯកសារវគ្គបណ្ដុះបណ្ដាល

- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមវិធីរដ្ឋប្បវេណី ភាគ ៥
- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល
- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង
- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី
- សៀវភៅស្ដីពីសេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ : នីតិវិធីបណ្ដឹង, បោះពុម្ព ឆ្នាំ២០០៨
- សៀវភៅស្ដីពីសេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ១, បោះពុម្ពលើកទី១ ខែមេសា ឆ្នាំ២០១៣
- សៀវភៅស្ដីពីការពន្យល់អំពីការជម្រះក្ដីលើកទី ១, បោះពុម្ពលើកទី ២, ខែវិច្ឆិកា ឆ្នាំ២០០៩

គ. គេហទំព័រ

- ឯកសារសិក្ខាសាលាស្ដីពី "ទម្រង់គំរូ និងការដាក់បង្ហាញសាលក្រម/សាលដីកា" (ករណីទាមទារលែងលះ និងបែងចែកទ្រព្យរួម) , គេហទំព័រ https://www.jica.go.jp/Resource/project/english/cambodia/025/materials/index.html
- ទម្រង់លិខិតគំរូដែលប្រើប្រាស់ក្នុងរឿងក្ដីរដ្ឋប្បវេណី, គេហទំព័រ https://www.moj.gov.kh/kh/sample-civil-documents



www.moj.gov.kh/kh/book-library

ហាមលក់

www.moj.gov.kh/kh/book-library

## （表８）養育費・子３人表（第１子及び第２子15歳以上，第３子０～14歳）

